WorldFish CENTER

Sida

# ឆ្ពោះទៅវិធានគ្រប់គ្រងជ្រោយនៃអភិបាលកិច្ចតំបន់ដីសើម៖

## ក្របខណ្ឌច្បាប់ និងស្ថាប័ន និងការវាយតំលៃសេដ្ឋកិច្ច

## នៃធនធានតំបន់ដីសើមក្នុងប្រទេសកម្ពុជា

លោក នៅ ធួក លោក ម៉ម កុសល លោក ម៉ៅ កុសល លោក គីម សួ និង លោក ស្រ៊ុន លឹមសុង



សម្របសម្រួលបកប្រែ និង បោះពុម្ពផ្សាយដោយ

**វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍នេសាទទឹកសាប**

**២០០៥**

# ឆ្ពោះទៅវិធានគ្រប់ជ្រុងជ្រោយនៃអភិបាលកិច្ចតំបន់ដីសើមៈ

# ក្របខណ្ឌច្បាប់ និងស្ថាប័ន និងការវាយតំលៃសេដ្ឋកិច្ច

# នៃធនធានតំបន់ដីសើមក្នុងប្រទេសកម្ពុជា

សម្របសម្រួលបកប្រែ និង បោះពុម្ពផ្សាយដោយ

**វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍នេសាទទឹកសាប**

២០០៥

ដឹកនាំសរសេរសំរួលបកប្រែ និង បោះពុម្ពផ្សាយដោយ: **លោក ស្រ៊ុន លីមសុង**
*វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍នេសាទទឹកសាប*

អនុវត្តការសម្របសម្រួលបកប្រែ និងរចនាគម្រប
ព្រមទាំងរៀបចំទំព័រដោយ: **លោក ឈាង សុផា**
*វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍នេសាទទឹកសាប*

បកប្រែជាភាសាខ្មែរដោយ: **លោក ម៉ម កុសល**
*ក្រសួងបរិស្ថាន*

ដោយមានការរួមវិភាគទានពី: **កញ្ញា អ៊ី ឡារី លោក ហង់ ទ្រី លោក ស៊ុន សុផល**
**លោក ឱក ផុន លោក ធឿង ម៉ៅ**
**លោក ម៉ៅ ចាន់សាម៉ន និង លោក គុយ ស៊ា**

ពិនិត្យ និង កែសំរួលដោយ: **លោក ឈាង សុផា**
*វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍នេសាទទឹកសាប*

រៀបរៀងដោយ: **លោក នៅ បោន័រ លោក ម៉ម កុសល**
**លោក ម៉ៅ កុសល លោក គីម សួ**
**និងលោក ស្រ៊ុន លីមសុង**

រូបក្របដោយ: **គំរោងគ្រប់គ្រងនេសាទទឹកសាបកម្ពុជា**

បោះពុម្ពនៅរោងពុម្ព: **សុខលាភ បោះពុម្ព**
*ខែមិថុនា ឆ្នាំ២០០៥*

ឧបត្ថម្ភថវិកាដោយ: **WorldFish Center**

The views and opinions expressed in this publication are not necessarily those of the Department of Fisheries, the WorldFish Center, or Sida.

This is a Khmer translation of a chapter in an edited volume of country reports:

Neou Bonheur, Mam Kosal, Mao Kosal, Kim Sour and Srun Lim Song. 2005. Towards a Holistic Approach to Wetlands Governance: The Legal and Institutional Framework and Economic Valuation of Wetland Resources in Cambodia. In Oh, E., Ratner, B., Bush, S., Kolandai, K., and Too, T. (eds.) Wetlands governance in the Mekong Region: Country Reports on the Legal-institutional Framework and Economic Valuation of Aquatic Resources. WorldFish Center, Penang, Malaysia.

The report is available from the Department of Fisheries and the WorldFish Center.

បើមានចំណាប់អារម្មណ៍ចំពោះឯកសារនេះ សូមទំនាក់ទំនង: វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍នេសាទទឹកសាប (IFReDI)
#១៨៦ មហាវិថីព្រះនរោត្តម ខណ្ឌចំការមន ប្រអប់សំបុត្រ ៥៨២ រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ២២០ ៤១៧
Email : IFReDI@online.com.kh

## មាតិកា


**១.សេចក្តីផ្តើម** ........ ១

**២.ទិដ្ឋាន និងវិធីសាស្ត្រដែលបានប្រើប្រាស់** ........ ២

២.១ ប្រវត្តិនៃការសិក្សាស្រាវជ្រាវ ........ ២

*២.១.១ គោលបំណង* ........ ២

*២.១.២ ក្រុមសិក្សាស្រាវជ្រាវ* ........ ២

*២.១.៣ ទីតាំងសិក្សាស្រាវជ្រាវ* ........ ៣

*២.១.៤ វិធាននៃការស្រាវជ្រាវ* ........ ៣

*២.១.៥ ការលំបាក* ........ ៥

២.២ ចំណុចខ្វះខាតនៃទិន្នន័យដែលប្រើប្រាស់សំរាប់ធ្វើការវាយតំលៃសេដ្ឋកិច្ចតំបន់ដីសើម ........ ៥

*២.២.១ ចំណុចខ្វះខាតជាទូទៅ* ........ ៥

*២.២.២ វត្តមាន និងគុណភាពនៃទិន្នន័យតាមវិស័យ* ........ ៥

**៣.តំបន់ដីសើមក្នុងប្រទេសកម្ពុជា** ........ ៨

៣.១ ទស្សនៈទានអំពីតំបន់ដីសើមក្នុងប្រទេសកម្ពុជា ........ ៨

៣.២ លក្ខណៈនៃតំបន់ដីសើម ........ ៨

៣.៣ របាយ និងប្រភេទតំបន់ដីសើមក្នុងប្រទេសកម្ពុជា ........ ៩

៣.៤ តំបន់ដីសើម និងការប្រើប្រាស់ដី ........ ១១

*៣.៤.១ របាយប្រជាជនក្នុងតំបន់ដីសើម* ........ ១១

*៣.៤.២ ការគំរាមកំហែងចំពោះតំបន់ដីសើម* ........ ១២

**៤.ក្របខណ្ឌស្ថាប័ន និងច្បាប់** ........ ១៥

៤.១ ក្របខ័ណ្ឌស្ថាប័ន ........ ១៥

*៤.១.១ ស្ថានភាពនៃការចាត់ចែងស្ថាប័ន* ........ ១៥

*៤.១.២ បញ្ហាស្ថាប័នទាក់ទងនឹងការគ្រប់គ្រងតំបន់ដីសើម* ........ ២២

៤.២ ក្របខ័ណ្ឌច្បាប់ ........ ២៧

*៤.២.១ ជលផល* ........ ២៧

*៤.២.២ ការប្រើប្រាស់ដី* ........ ៣២

៤.២.៣ ការអភិរក្ស និងការពារបរិស្ថាន ........ ៣២

**៥.ការវាយតំលៃសេដ្ឋកិច្ចតំបន់ដីសើម** ........ ៣៥

**៥.១ តំលៃ និងការវាយតំលៃតំបន់ដីសើម** ........ ៣៥

**៥.២ មុខងារ និងការប្រើប្រាស់តំបន់ដីសើម** ........ ៣៧

*៥.២.១ ការប្រើប្រាស់តំបន់ដីសើមចំបងៗតាមវិស័យ* ........ ៣៧

*៥.២.២ ការប្រើប្រាស់ និងតួនាទីផ្សេងៗទៀតនៃតំបន់ដីសើម* ........ ៤០

**៥.៣ ការប្រើប្រាស់ និងតួនាទីតំបន់ដីសើមដែលមានសារៈសំខាន់បំផុត សំរាប់ជីវភាពរស់នៅរបស់ជនក្រីក្រ** ........ ៥២

*៥.៣.១ តំលៃតំបន់ដីសើមដែលមានសារៈសំខាន់ចំពោះអ្នកប្រើប្រាស់ក្នុងមូលដ្ឋាន ប៉ុន្តែលំបាកសំដែងជាតំលៃសេដ្ឋកិច្ចនិងមិនសូវមានការកោតសរសើរ* ........ ៥៥

*៥.៣.២ វិធីសាស្ត្រគួរទុកចិត្តបានសំរាប់វាយតំលៃសារៈសំខាន់នៃធនធានតំបន់ដីសើម ចំពោះជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ* ........ ៥៨

**៦.សេចក្តីសន្និដ្ឋានអំពីគោលនយោបាយ និងអនុសាសន៍** ........ ៥៨

**៦.១ សេចក្តីសន្និដ្ឋាន** ........ ៥៨

*៦.១.១ ក្របខ័ណ្ឌស្ថាប័ន និងច្បាប់* ........ ៥៨

*៦.១.២ ការវាយតំលៃសេដ្ឋកិច្ចនៃតំបន់ដីសើម* ........ ៥៩

**៦.២ អនុសាសន៍** ........ ៦០

*៦.២.១ ប្រកាន់យកយុទ្ធសាស្ត្រជាតិស៊ីសង្វាក់គ្នាសំរាប់គ្រប់គ្រងតំបន់ដីសើម* ........ ៦០

*៦.២.២ កែលំអក្របខ័ណ្ឌច្បាប់សំរាប់គាំទ្រវិធានការចំរុះគ្រប់គ្រងធនធានតំបន់ដីសើម* ........ ៦០

*៦.២.៣ កែលំអការចែករំលែកការទទួលខុសត្រូវក្នុងចំណោមស្ថាប័នរដ្ឋាភិបាល* ........ ៦២

*៦.២.៤ កែលំអយន្តការនានាដើម្បីគ្រប់គ្រងឱ្យបានល្អជាងមុននូវភាពប្រកួតប្រជែង និងការប្រើប្រាស់តំបន់ដីសើម ប្រកបដោយការសំរបសំរួលរវាងអ្នកពាក់ព័ន្ធ* ........ ៦៣

*៦.២.៥ ការគាំទ្រដើម្បីប្រមូល និងផ្សព្វផ្សាយព័ត៌មានឱ្យបានប្រសើរជាងមុនអំពីតំលៃប្រើប្រាស់ច្រើនយ៉ាងនៃតំបន់ដីសើម* ........ ៦៥

**ឯកសារយោង** ........ ៦៦

**តារាងៈ**


តារាងទី ១: វិសាលភាពនៃប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើមក្នុងប្រទេសកម្ពុជា ................១០

តារាងទី ២: ការចាត់ចែងស្ថាប័ន និងក្របខ័ណ្ឌច្បាប់..............................................១៦

តារាងទី ៣: ផ្ទៃដីដាំដំណាំចំបង១ (គិតជាពាន់ហិកតា) ............................................៣៩

តារាងទី ៤: ផលិតផលប្រចាំឆ្នាំនៃដំណាំចំបង១ (គិតជា ពាន់តោន)..........................៤១

តារាងទី ៥: ការរួមវិភាគទាននៃផលនេសាទពីវាលស្រែនៅក្នុងរបបអាហារ..................៤៣

តារាងទី ៦: ផលិតផលវារីវប្បកម្មទឹកសាប (ត្រីគិតជាតោន និងក្រពើគិតជាក្បាល).......៤៥

តារាងទី ៧: ផ្ទៃដីស្រែស្រោចស្រពក្នុងខេត្តមួយចំនួននៅជុំវិញបឹងទន្លេសាប ................៤៦

តារាងទី ៨: ចំនួនទូក និងនាវាដែលបានចុះបញ្ជី និងធ្វើដំណើរក្នុងផ្លូវទឹកសាប ..............៤៩

តារាងទី ៩: ផលិតផលប្រចាំឆ្នាំនៃសត្វចិញ្ចឹម (គិតជាលានក្បាល) ...............................៥១

តារាងទី ១០: តំលៃនៃធនធានតំបន់ដីសើមក្នុងឃុំព្រះវិកិល ចុងឃ្នាស និងអង្គរបុរី .........៥៥


**ប្រអប់ៈ**


ប្រអប់ទី ១: និយមន័យតំបន់ដីសើមតាមអនុសញ្ញារ៉ាមសារ (UNESCO 1994)............៩

ប្រអប់ទី ២: សេចក្តីព្រាងផែនការសកម្មភាពតំបន់ដីសើមជាតិ (1999)........................២២

ប្រអប់ទី ៣: យន្តការសំរបសំរួលសំរាប់ជបនីយជីវមណ្ឌលបឹងទន្លេសាប.........................២៣

ប្រអប់ទី ៤: ករណីសិក្សាមួយអំពីទំនាស់ប្រើប្រាស់ធនធានតំបន់ដីសើមនៅកំពង់ក្រសាំង
ស្រុកបុរីជលសា ខេត្តតាកែវ .................................................................២៦

ប្រអប់ទី ៥: អង្គការសហគមន៍នេសាទនៅក្នុងខេត្តស្ទឹងត្រែង...........................................៣១

ប្រអប់ទី ៦: អង្គការសហគមន៍នេសាទអន្លង់សំណរ ក្នុងស្រុកជីក្រែង
ខេត្តសៀមរាប - ប្រវត្តិអំពីជោគជ័យ ......................................................៣១

ប្រអប់ទី ៧: ជបនីយ៍ជីវមណ្ឌលបឹងទន្លេសាប ជាវិធានមួយសំរាប់លើកកំពស់
ការអភិរក្សតំបន់ដីសើម ......................................................................៣៣

ប្រអប់ទី ៨: អត្ថប្រយោជន៍នានានៃតំបន់ដីសើម.........................................................៣៦

ប្រអប់ទី ៩: សក្តានុពលអេកូទេសចរណ៍ផ្សោតនៅអន្លង់ឈើទាល ខេត្តស្ទឹងត្រែង...........៤៧

ប្រអប់ទី ១០: ប្រភេទសត្វជិតផុតពូជក្នុងតំបន់ដីសើមប្រទេសកម្ពុជា............................៥០

## ១. សេចក្តីផ្តើម

ប្រទេសកម្ពុជាសំបូរដោយតំបន់ដីសើម និងធនធានតំបន់ដីសើម។ តំបន់ដីសើមគ្របដណ្តប់លើវិសាលភាពធំជាង ៣០%នៃផ្ទៃដីប្រទេស (MoE 1999)។ ដោយសារផ្ទៃដីភាគច្រើននៃប្រទេសកម្ពុជាស្ថិតក្នុងទីទំនាប ហេតុនេះផ្ទៃដីមួយភាគធំត្រូវលិចទឹកជាទៀងទាត់ ជាពិសេសនៅរដូវវស្សា។ បឹងទន្លេសាប ទន្លេមេគង្គ និងទំនាបទន្លេបាសាក់ គឺជាភូមិភាគធំបងបីនៃតំបន់ដីសើមទឹកសាបក្នុងប្រទេសកម្ពុជា។ លើសពីនេះ មានតំបន់ដីសើមតូចៗជាច្រើនផ្សេងទៀត ដូចជាតំបន់ដីសើមនៅភាគខាងលើនៃស្ទឹងសែន និងនៅតាមដែនានានៃទន្លេមេគង្គភាគឦសាននៃប្រទេសកម្ពុជា។ ប្រជាជនកម្ពុជាភាគច្រើនរស់នៅក្នុងតំបន់ទំនាបកណ្តាលនៃប្រទេស ដែលជាតំបន់ដីសើម និងពឹងផ្អែកយ៉ាងសំខាន់លើតំបន់ដីសើម និងធនធានតំបន់ដីសើមសំរាប់ការចិញ្ចឹមជីវិត និងប្រាក់ចំណូលរបស់ខ្លួន។

ជាប្រទេសដែលពឹងផ្អែកជាសំខាន់លើកសិកម្ម ប្រទេសកម្ពុជាពឹងផ្អែកជាបឋមលើការដាំដំណាំ និងការប្រមូលផលធនធានធម្មជាតិពីធម្មជាតិ។ ទោះបីតំបន់ដីសើម និងធនធាននៃតំបន់នេះផ្តល់ផលិតផល និងសេវាជាច្រើនសំរាប់ប្រជាពលរដ្ឋ និងសេដ្ឋកិច្ចជាតិ ព្រមទាំងសេដ្ឋកិច្ចមូលដ្ឋានក្តី ផលិតផលជាច្រើនត្រូវបានដកហូតសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន និងពុំបានរាប់បញ្ចូលទៅក្នុងសេដ្ឋកិច្ចទីផ្សារឡើយ។ ជាលទ្ធផល ការព្យាយាមកំណត់និយមន័យ និងតំលៃនៃការប្រើប្រាស់ និងមុខងាររបស់តំបន់ដីសើមក្នុងបរិបទនៃប្រទេសកម្ពុជាគឺជាការលំបាក។

តំបន់ដីសើមក្នុងប្រទេសកម្ពុជាផ្តល់ជាមូលដ្ឋានគ្រឹះនៃធនធានសំបូរបែបសំរាប់សេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចមូលដ្ឋាន។ តំបន់ដីសើមទ្រទ្រង់ការប្រើប្រាស់ច្រើនបែបខុសៗគ្នា ជាអាទិ៍ ផ្គត់ផ្គង់ទឹក ស្រោចស្រព វារីអគ្គិសនី ជលផល កសិកម្ម ការបរបាញ់សត្វព្រៃ ថាមពលអុស នាវាចរ ការកំសាន្ត និងការតាំងទីលំនៅ។ តំបន់ដីសើមមានសារៈសំខាន់ខាងផ្នែកវប្បធម៌ និងសេដ្ឋកិច្ច សំរាប់ប្រជាជនភាគច្រើន ជាពិសេសសហគមន៍ជនបទដែលពឹងផ្អែកលើតំបន់ដីសើមសំរាប់ការរស់នៅ។ ដោយសារតំលៃសេដ្ឋកិច្ចច្រើនបែប តំបន់ដីសើមមិនគ្រាន់តែជាប្រភពនៃទ្រព្យសម្បត្តិប៉ុណ្ណោះទេ ប៉ុន្តែវាការជាប្រភពនៃទំនាស់ផងដែរ រវាងអ្នកប្រើប្រាស់ និងអ្នកគ្រប់គ្រងធនធាននៅមូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់។ ការប្រកួតប្រជែងក្នុងការប្រើប្រាស់ធនធានកំពុងកើនឡើង នៅពេលចំនួនប្រជាពលរដ្ឋបានកើនឡើង ឯការព្យាយាមរក្សាតុល្យភាពនៃការប្រើប្រាស់ត្រូវប្រទះឧបសគ្គដោយសារចំណេះដឹងទាប កម្រិតនៃគោលនយោបាយស៊ីសង្វាក់គ្នា និងវិធានគ្រប់គ្រងចំរុះ និងកម្រិតនៃការចូលរួមពីសំណាក់សាធារណជន។

ដោយសារមានការប្រើប្រាស់ច្រើនបែប ការគ្រប់គ្រងតំបន់ដីសើមច្រើនតែស្ថិតក្រោមការចាប់អារម្មណ៍នៃអ្នកពាក់ព័ន្ធជាច្រើន រួមទាំងស្ថាប័នសាធារណៈ អ្នកកសាងគោលនយោបាយ សហគមន៍មូលដ្ឋាន ផលិតករ អង្គការមិនមែនរដ្ឋាភិបាល និងក្រុមអ្នកតស៊ូមតិ។ តួនាទីពឹងពាក់គ្នាទៅវិញទៅមកនៃក្រុមទាំងនេះបង្កើតជាក្របខ័ណ្ឌស្ថាប័ន និងច្បាប់ដ៏សាំញ៉ាំ ដែលដឹកនាំការអភិរក្ស និងគ្រប់គ្រងធនធានតំបន់ដីសើម។ ការយល់ដឹងអំពីចំណុចខ្លាំង និងចំណុចខ្សោយនៃក្របខ័ណ្ឌស្ថាប័ន និងច្បាប់នេះជាប្រការសំខាន់ខ្លាំងណាស់សំរាប់អ្នកពាក់ព័ន្ធទាំងអស់ ដែលមានបំណងការពារ និងប្រើប្រាស់ធនធានតំបន់ដីសើមតាមរូបភាពដែលមានលក្ខណៈសំរបសំរួលរវាងគ្នា។

របាយការណ៍នេះត្រូវបានរៀបរៀងឡើងដើម្បីបំពេញតំរូវការ យ៉ាងហោចណាស់បានផ្នែកខ្លះ ក្នុងការបំភ្លឺបន្ថែមនូវវិធានអភិបាលកិច្ចតំបន់ដីសើមក្នុងប្រទេសកម្ពុជា ។ យើងសង្ឃឹមថារបាយការណ៍នេះនឹងរួមវិភាគទានអោយបានប្រសើរលើការគ្រប់គ្រងតំបន់ដីសើម តាមរយៈការផ្តល់ជូននូវសេចក្តីពន្យល់បំភ្លឺឱ្យបានច្បាស់លាស់អំពីប្រព័ន្ធច្បាប់ និងស្ថាប័នដែលពាក់ព័ន្ធ ព្រមទាំងការបង្ហាញអំពីតំលៃសេដ្ឋកិច្ច និងធនធាននៃតំបន់ដីសើម។ យើងសង្ឃឹមផងដែរថា ចំណេះដឹងដែលកើតចេញពីរបាយការណ៍នេះនឹងអាចចែករំលែកជាមួយប្រទេសផ្សេងទៀតក្នុងតំបន់ ដើម្បីរៀបចំវិធានរួមសំរាប់លើកកំពស់ការគ្រប់គ្រងតំបន់ដីសើមនៅក្នុងតំបន់នេះ ។

របាយការណ៍នេះចែកចេញជាប្រាំមួយផ្នែក ។ បន្ទាប់ពីសេចក្តីផ្តើមនេះ ផ្នែកទីពីរអធិប្បាយជូនអំពីវិធាននៃការស្រាវជ្រាវនេះ និងវិធីសាស្ត្រដែលបានប្រើប្រាស់ ។ ផ្នែកទីបីបង្ហាញទិដ្ឋភាពរួមនៃតំបន់ដីសើមក្នុងប្រទេសកម្ពុជា។ ផ្នែកទីបួនធ្វើការពិនិត្យឡើងវិញ និងវិភាគបញ្ហាស្ថាប័ននិងច្បាប់ដែលពាក់ព័ន្ធនឹងតំបន់ដីសើមនៅក្នុងអាងទន្លេមេគង្គ។ ផ្នែកនេះត្រូវបានរៀបរៀងឡើងដោយផ្អែកលើការរួមវិភាគទានដោយមន្ត្រីពីមន្ទីរ និងអង្គការនានានៅថ្នាក់ជាតិ និងថ្នាក់ខេត្ត។ ផ្នែកទីប្រាំបរិយាយអំពីមុខងារនានា និងការប្រើប្រាស់តំបន់ដីសើមក្នុងប្រទេសកម្ពុជា និងបង្ហាញជូនអំពីការព្យាយាមដើម្បីប៉ាន់ប្រមាណតំលៃសេដ្ឋកិច្ចនៃមុខងារ និងការប្រើប្រាស់ទាំងនោះ។ ទីបំផុត ផ្នែកទីប្រាំមួយបង្ហាញជូនអំពីសេចក្តីសន្និដ្ឋានទូទៅ និងលើកឡើងនូវអនុសាសន៍ដែលបានពីការស្រាវជ្រាវនេះ ។

## ២. វិធាន និងវិធីសាស្ត្រដែលបានប្រើប្រាស់

### ២.១ ប្រវត្តិនៃការសិក្សាស្រាវជ្រាវ

របាយការណ៍នេះបង្ហាញជូនអំពីការរកឃើញតាមរយៈការអនុវត្តក្នុងប្រទេសកម្ពុជានូវគំរោង "ក្របខ័ណ្ឌច្បាប់ និងស្ថាប័ន និងការវាយតំលៃសេដ្ឋកិច្ចនៃធនធាន និងបរិស្ថានក្នុងអាងទន្លេមេគង្គ - វិធានតំបន់ដីសើម" (ដែលហៅកាត់ថា វិធានតំបន់ដីសើមទន្លេមេគង្គ) ដែលបានធ្វើឡើងពីខែកក្កដា ឆ្នាំ ២០០២ ដល់ខែសីហា ឆ្នាំ២០០៣។ នាយកដ្ឋានជលផលគឺជាស្ថាប័នសំរបសំរួលគំរោងនេះក្នុងប្រទេសកម្ពុជា ដោយមាន លោក ស្រ៊ុន លឹមសុង ជាអ្នកសំរបសំរួលគំរោងថ្នាក់ជាតិ និងលោក គឹម សូ ជាមន្ត្រីទំនាក់ទំនង ។

#### ២.១.១ គោលបំណង

ការសិក្សានេះមានគោលបំណងលើកកំពស់ជីវិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា ដោយគាំទ្រការអភិវឌ្ឍន៍ដែលមានលក្ខណៈស៊ីគ្នាជាមួយបរិស្ថាន និងរក្សានិរន្តរភាព ព្រមទាំងលើកកំពស់តំលៃ និងមុខងាររបស់តំបន់ដីសើមក្នុងប្រទេសកម្ពុជា។ គោលបំណងចំពោះមុខនៃគំរោងនេះ គឺការធ្វើឱ្យប្រសើរឡើងនូវក្របខ័ណ្ឌច្បាប់ និងស្ថាប័នជាតិ និងបង្កើនសមត្ថភាពក្នុងមូលដ្ឋានដើម្បីគ្រប់គ្រងតំបន់ដីសើម និងធនធានក្នុងតំបន់ដីសើម ព្រមទាំងបរិស្ថាន នៅក្នុងប្រទេសកម្ពុជា។

#### ២.១.២ ក្រុមសិក្សាស្រាវជ្រាវ

ក្រុមការងារថ្នាក់ជាតិមួយក្រុម និងក្រុមការងារថ្នាក់ខេត្តបីក្រុមត្រូវបានបង្កើតឡើងដើម្បីអនុវត្តការសិក្សានេះ (សូមអានរូបទី ១)។ ក្រុមការងារថ្នាក់ជាតិត្រូវបានចែកចេញជាពីរក្រុមគឺៈ ក្រុមការងារក្របខ័ណ្ឌច្បាប់ និងស្ថាប័ន ដែលមានសមាជិកប្រាំរូប និងក្រុមការងារវាយតំលៃសេដ្ឋកិច្ច ដែលមានសមាជិកប្រាំមួយរូប។ ក្រុមការងារថ្នាក់ខេត្ត ត្រូវបានបង្កើត

ឡើងនៅក្នុងខេត្តចំនួនបី ដែលត្រូវបានជ្រើសរើសជាទីតាំងសិក្សាស្រាវជ្រាវ ពោលគឺ ខេត្តសៀមរាប តាកែវ និងស្ទឹងត្រែង។ ក្រុមការងារថ្នាក់ខេត្តនីមួយៗក្នុងចំណោមក្រុមទាំងបីមានសមាជិកពី ប្រាំបួន ទៅដប់រូប ដែលជាមន្ត្រីមកពីមន្ទីរ ឬការិយាល័យថ្នាក់ខេត្ត ដែលទទួលបន្ទុកផ្នែក កសិកម្ម ជលផល ទេសចរណ៍ សាធារណការ និងដឹកជញ្ជូន បរិស្ថាន ផែនការ និងកិច្ចការនារី។




រូបទី ១. ក្រុមការងារនៅក្នុងការស្រាវជ្រាវ

### *២.១.៣ ទីតាំងសិក្សាស្រាវជ្រាវ*

ទីតាំងសិក្សាចំនួនបីកន្លែងត្រូវបានជ្រើសរើសជាតំណាងប្រភេទខុសគ្នានៃតំបន់ដីសើមក្នុងប្រទេសកម្ពុជា ដែលទីតាំងនីមួយៗមានស្ថានភាពភូមិសាស្ត្រ និងជលសាស្ត្រដោយឡែកពីគ្នា។ ទីតាំងទាំងនោះគឺ ទីមួយនៅដងទន្លេមេគង្គភាគខាងលើ ក្នុងខេត្តស្ទឹងត្រែង ជិតព្រំប្រទល់កម្ពុជា-ឡាវ ទីពីរគឺទំនាបលិចទឹកក្នុងខេត្តតាកែវដែលងាយរងឥទ្ធិពលពីការជ្រាបចូលនៃទឹកសមុទ្រ និងទីបី គឺទំនាបបឹងទន្លេសាបក្នុងខេត្តសៀមរាប។ ដោយស្ថិតនៅក្នុងខេត្តបីខុសប្លែកពីគ្នា ទីតាំងទាំងបីនេះមានលក្ខណៈជាតំណាងឱ្យតំបន់ដីសើមក្នុងភូមិភាគបីបែបនៃដែនទឹកសាបក្នុងប្រទេស ដូចដែលបានបរិយាយខាងលើ ពោលគឺ ទន្លេមេគង្គ (ខេត្តស្ទឹងត្រែង) ទំនាបទន្លេបាសាក់ (ខេត្តតាកែវ) និងបឹងទន្លេសាប (ខេត្តសៀមរាប)។

### *២.១.៤ វិធាននៃការស្រាវជ្រាវ*

ការសិក្សានេះរួមមានការប្រមូល និងចងក្រងទិន្នន័យអំពីក្របខ័ណ្ឌច្បាប់ និងស្ថាប័ន ពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ដីសើម និងអំពីការវាយតំលៃសេដ្ឋកិច្ចតំបន់ដីសើម។ បន្ទាប់មក ទិន្នន័យទទួលបានពីក្រុមការងារទាំងអស់ត្រូវបានសង្ខេប មុនពេលធ្វើការវិភាគរួមគ្នាដោយក្រុមការងារថ្នាក់ខេត្ត ដោយមានការជួយណែនាំពីប្រធានក្រុមការងារទាំងពីរនៅថ្នាក់ជាតិ។ របាយការណ៍នេះគឺជាសេចក្តីសំយោគលទ្ធផលនៃការរកឃើញនោះ។

សិក្ខាសាលាជាច្រើនលើកដែលបានចាត់ចែងឡើងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត នៅក្នុងគំរោងនេះ បានផ្តល់ឱកាសយ៉ាងច្រើនដើម្បីកសាងសមត្ថភាពស្រាវជ្រាវសំរាប់សមាជិកនានានៃក្រុមការងារទាំងនេះ។ ឧទាហរណ៍ដែលគួរឱ្យកត់សំគាល់មួយ គឺ ការបណ្តុះបណ្តាលមួយ ដែលសមាជិកក្រុមការងារបានទទួលការបង្ហាត់បង្ហាញពីអ្នកជំនាញការថ្នាក់តំបន់អំពីរបៀបវាយតំលៃជនបទដោយមានការចូលរួម (PRA) និង ការវាយតំលៃជនបទដោយរហ័ស (RRA) ដែលបន្ទាប់មកសមាជិកក្រុម

នានា បានយកវិធីសាស្ត្រនេះទៅប្រើប្រាស់ដោយខ្លួនឯងនៅក្នុងទីតាំងសិក្សាទាំងបីកន្លែង។

### *២.១.៥ ការលំបាក*

ការលំបាកជាទូទៅដែលបានប្រឈមក្នុងការអនុវត្តគំរោងនេះមានជាអាទិ៍:

១. ទិន្នន័យនានាដែលមាននៅក្នុងប្រទេសមានគុណភាពទាប ។ ទោះបីបានពីប្រភពផ្លូវការក្តី ភាគច្រើននៃទិន្នន័យដែលប្រមូលបាន គឺជាទិន្នន័យបានពីការប៉ាន់ប្រមាណ។ ចំណុចខ្វះខាតនៃទិន្នន័យដែលប្រើប្រាស់សំរាប់ផ្នែកវាយតំលៃសេដ្ឋកិច្ច មានអធិប្បាយលំអិតជាបន្ថែមនៅក្នុងផ្នែកបន្ទាប់ ។

២. ចំណេះដឹង និងជំនាញរបស់ក្រុមការងារថ្នាក់ខេត្តមានកំរិតទាប។ សមាជិកក្រុមទាំងនេះមានការយល់ដឹងភាសាអង់គ្លេសកំរិតទាប ជាហេតុធ្វើឱ្យពួកគេលំបាកវិភាគឯកសារដែលសរសេរជាភាសាអង់គ្លេស និងស្វែងយល់ពីទស្សនៈទានទាក់ទងនឹងតំបន់ដីសើម ដែលភាគច្រើនមានសរសេរតែជាភាសាអង់គ្លេស ។

៣. ការលំបាកពន្យល់ប្រាប់ប្រជាពលរដ្ឋអំពីគោលបំណងនៃការសិក្សានេះ។ ប្រជាពលរដ្ឋជាច្រើនលំបាកឆ្លើយចំពោះសំណួរអំពីការឱ្យតំលៃ ឬទទួលស្គាល់ផលប្រយោជន៍នៃធនធានជាច្រើនពីតំបន់ដីសើម ដោយហេតុថាធនធានទាំងនេះភាគច្រើនជារបស់តូចៗ និងធ្វើឡើងដោយការស្មានៗ (ឧទាហរណ៍: វារីរុក្ខជាតិ និងសត្វល្អិត)។ លើសពីនេះលក្ខណៈស្មុគស្មាញនៃច្បាប់ និងបទប្បញ្ញត្តិនានារបស់រដ្ឋាភិបាលជាហេតុនាំឱ្យពួកគេលំបាកធ្វើការវិភាគ។

## ២.២ ចំណុចខ្វះខាតនៃទិន្នន័យដែលប្រើប្រាស់សំរាប់ធ្វើការវាយតំលៃសេដ្ឋកិច្ចតំបន់ដីសើម

### *២.២.១ ចំណុចខ្វះខាតជាទូទៅ*

ការប្រមូលទិន្នន័យផ្សេងៗទាក់ទងនឹងតំបន់ដីសើមមិនមានលក្ខណៈជាប់លាប់ទេ ដោយសារទំនាស់សង្គមរយៈពេលយ៉ាងយូរនៅក្នុងប្រទេស។ ប៉ុន្តែ ការប្រមូលទិន្នន័យបានបន្តធ្វើឡើងយ៉ាងទូលំទូលាយសំរាប់ផ្នែកផលិតកម្មមួយចំនួនចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៨០ ហើយលទ្ធផលទាំងនោះមានចុះផ្សាយជាតារាងស្ថិតិ និងរបាយការណ៍របស់រដ្ឋាភិបាល។ ភាគច្រើននៃទិន្នន័យក្នុងរបាយការណ៍នានានៅថ្នាក់ជាតិសំរាប់អំឡុងពេលនោះច្រើនតែបានពីការប៉ាន់ស្មាន និងពីអ្នកផ្តល់ព័ត៌មាននៅតាមលំដាប់ផ្សេងៗពីមូលដ្ឋាន។ នៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ទិន្នន័យនានាត្រូវបានកែតំរូវ បញ្ចូលបន្ថែម ចាត់ចែងតាមតំរូវការ និងកែសំរួលតាមការចាំបាច់។ ទីបំផុត ទិន្នន័យសរុបត្រូវបានរៀបចំ និងប្រមូលផ្តុំនៅថ្នាក់ជាតិ។

តំបន់ភូមិសាស្ត្រមួយចំនួនមិនអាចចូលដល់ដោយមូលហេតុអសន្តិសុខ ហេតុនេះទិន្នន័យទាំងនោះមិនឆ្លុះបញ្ចាំងតួលេខពីក្នុងប្រទេសទាំងមូលឡើយ។ ទោះបីទិន្នន័យខ្លះៗមានលក្ខណៈលំអិតក្តី ទិន្នន័យមួយចំនួនត្រូវបានចាត់ទុកថាគ្មានលក្ខណៈប្រាកដនិយម។ ជាទូទៅ គ្មានការធ្វើបច្ចុប្បន្នភាពទិន្នន័យ និងព័ត៌មានឡើយ លើសពីនេះរាល់កំណត់ត្រានានាមិនបានរក្សាទុក និងថែទាំឱ្យបានត្រឹមត្រូវឡើយ។ កង្វះការកំណត់ច្បាស់លាស់អំពីការទទួលខុសត្រូវ ការផ្ទេរភារៈកិច្ច និងកង្វះវិធីសាស្ត្រដែលមានលក្ខណៈស្តង់ដា និងដែលអាចទុកចិត្តបាន គឺជាចំណែកមួយនៃមូលហេតុចំបងៗនៃការកត់ត្រា និងថែទាំទិន្នន័យមិនបានល្អនៅថ្នាក់ខេត្ត ។ ចំណេះដឹងកំរិតទាប កង្វះមធ្យោបាយ និងថវិកា គឺជាកត្តាផ្សេងទៀត។

ជាទូទៅ ទិន្នន័យអំពីការប្រមូលផលពីធម្មជាតិត្រូវបានចាត់ទុកថាជាការប៉ាន់ប្រមាណគិតទាប ដោយហេតុថាបុគ្គលនានានៅក្នុងផ្នែកប្រមូលទិន្នន័យមានជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍សេដ្ឋកិច្ចក្រៅផ្លូវការពីផលិតផលទាំងនោះ។ ម៉្យាងវិញទៀត មានការប៉ាន់ប្រមាណខ្ពស់ចំពោះផលិតផលដែលមិនទាក់ទងនឹងផលប្រយោជន៍បុគ្គល ប៉ុន្តែដើម្បីទទួលការលើកសរសើរពីប្រធានអង្គភាព។ ភាពទន់ខ្សោយនៃការបញ្ជូនព័ត៌មានរវាងអ្នកប្រើប្រាស់ធនធាន និងអ្នកប្រើប្រាស់ទិន្នន័យ/ព័ត៌មានច្រើនតែនាំឱ្យទិន្នន័យបានពីប្រភពផ្សេងគ្នាពុំបានផ្ទៀងផ្ទាត់រវាងគ្នា។

ការប្រមូល វិភាគ និងរក្សាទុកទិន្នន័យបានទទួលការកែលំអច្រើនចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៩០ មក។ របាយការណ៍បច្ចេកទេស និងវិទ្យាសាស្ត្រត្រូវបានរៀបចំឡើងជាហូរហែរ ហើយគុណភាពនៃរបាយការណ៍ និងទិន្នន័យក៏បានប្រសើរឡើងផងដែរ។ ដោយឡែកចំពោះវិស័យផលផល ចំនួនការសិក្សាស្រាវជ្រាវផ្អែកលើផលនេសាទទ្រង់ទ្រាយតូច វារីវប្បកម្ម និងកិច្ចការពារធនធានធម្មជាតិបានកើនឡើងចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៩០មក។ ប៉ុន្តែ នៅមានកង្វះការសំរបសំរួល និងចែករំលែកទិន្នន័យក្នុងចំណោមអង្គភាពនានា។ ជាលទ្ធផល ទិន្នន័យនានាពុំសូវបានផ្ទៀងផ្ទាត់ និងច្រើនតែពុំស៊ីសង្វាក់គ្នា ។

បច្ចុប្បន្ននេះ ពុំទាន់មានទិន្នន័យទូលំទូលាយគ្រប់គ្រាន់ ឬក្នុងទំរង់សមស្របសំរាប់ធ្វើការវាយតំលៃសេដ្ឋកិច្ចនៅឡើយទេ។ ទិន្នន័យ និងព័ត៌មានភាគច្រើនត្រូវបានប្រមូលផ្តុំសំរាប់ការប្រើប្រាស់តាមវិស័យ ហើយទិន្នន័យជាច្រើនបានពីការប៉ាន់ប្រមាណតែប៉ុណ្ណោះ ក្នុងបំណងបង្ហាញពីតំរូវការឱ្យមានការគ្រប់គ្រងប្រសើរជាងមុន។ របាយការណ៍នានាបានពីការស្រាវជ្រាវនៅពេលថ្មីៗនេះអាចទុកចិត្តបានជាងមុន ហើយទិន្នន័យនានាបានទទួលការសំរបសំរួល និងផ្ទៀងផ្ទាត់រវាងគ្នា។ ប៉ុន្តែ ដោយសារកង្វះការសិក្សាជាលក្ខណៈប្រព័ន្ធ និងមានកំរិត ដោយទិន្នន័យដែលមាននៅជាបំណែកផ្សេងៗគ្នា និងមានតែអំពីធនធានមួយចំនួន សំរាប់ទីតាំងខ្លះៗ និងអំឡុងពេលខ្លះៗតែប៉ុណ្ណោះ ។ គ្រប់ករណីទាំងអស់ ពុំមានក្រុមទទួលខុសត្រូវពិនិត្យលក្ខណៈបច្ចេកទេស និង វិទ្យាសាស្ត្រខាងការបោះពុម្ពផ្សាយឡើយ ហើយក្នុងករណីជាច្រើន ទិន្នន័យ និងព័ត៌មានត្រូវបានដកស្រង់ជាបន្តពីឯកសារមួយ ទៅឯកសារមួយទៀតដោយពុំបានដឹងថា តើទិន្នន័យ និងព័ត៌មានទាំងនោះអាចយកជាការបាន ឬមានការពិនិត្យអំពី វិធីសាស្ត្រនៃការប្រមូល និងវិភាគនោះឡើយ។

### ២.២.២ វត្តមាន និងគុណភាពនៃទិន្នន័យតាមវិស័យ

មានទិន្នន័យអំពីធនធាន ផលិតផល និង ការរួមចំណែកចំពោះផលទុនក្នុងស្រុកសរុបតាមវិស័យ នៅថ្នាក់ជាតិ ឬតំបន់។ ទិន្នន័យទាំងនេះមានអំពីវិស័យកសិកម្ម (ដំណាំយុទ្ធសាស្ត្រ ស្រូវ សត្វចិញ្ចឹម ផលនេសាទ និងព្រៃឈើ) ឧស្សាហកម្ម (ការយករ៉ែ ការយកដី កម្មន្តសាល អគ្គិសនី ទឹក និងការសាងសង់) និងសេវា (ដឹកជញ្ជូន ការប្រាស្រ័យទាក់ទង សណ្ឋាគារ និងភោជនីយដ្ឋាន)។ មានទិន្នន័យស្តីពីការខូចខាតដោយសារគ្រោះមហន្តរាយដូចជាទឹកជំនន់ និងការរាំងស្ងួតក្នុងវិស័យមួយចំនួនទៀត រួមទាំងការបាត់បង់ជីវិត កសិកម្ម (ស្រូវ សត្វ និងដំណាំ) និងហេដ្ឋារចនាសម្ព័ន្ធ (ផ្ទះ និងអាគារសាធារណៈ ផ្លូវថ្នល់ ស្ពាន ផ្លូវដែក បំពង់លូ និងប្រព័ន្ធស្រោចស្រព)។

#### កសិកម្ម

ទិន្នន័យអំពីផលិតផលកសិកម្មភាគច្រើនត្រូវបានចងក្រងបានល្អ និងទូលំទូលាយ។ ទិន្នន័យភាគច្រើនមានជាផ្លូវការ ប៉ុន្តែត្រូវបានចាត់ទុកថាគ្មានលក្ខណៈប្រាកដនិយម។ ទិន្នន័យទាំងនេះមានសំរាប់អំឡុងពេលពីម្ភៃទៅសាបសិបឆ្នាំ ដែលក្នុង

នោះមានការខ្វះចន្លោះសំរាប់រយៈពេលខ្លី និងសំរាប់ប្រភេទផលដំណាំមួយចំនួនតូចតែប៉ុណ្ណោះ។ របាយការណ៍ទូលំទូលាយបំផុតអំពីផលិតកម្មស្រូវ និងដំណាំយុទ្ធសាស្ត្រមួយចំនួន មានជាអាទិ៍ ពោត សណ្តែកបាយ សណ្តែកដី ល្ង ថ្នាំជក់ អំពៅ ដំឡូងឈើ ដំឡូងជ្វា ល្ហុងប្រេង និងក្រចៅ។ ជាទូទៅ ទិន្នន័យអំពីដំណាំទាំងនេះមានទាំងអំពីផ្ទៃដីដាំ/ប្រមូលផល និងផលិតផលសរុប។ ទិន្នន័យលំអិត មានជាពិសេសសំរាប់ដំណាំស្រូវ ដែលមានរហូតដល់ការញែកពីគ្នារវាងស្រូវប្រាំង និងស្រូវវស្សា។ តួលេខអំពីផលដំណាំប្រចាំខេត្តក៏មានក្នុងទំរង់ប្រហាក់ប្រហែលគ្នានេះដែរ ប៉ុន្តែច្រើនមានតែដំណាំយុទ្ធសាស្ត្រមួយចំនួន និងភាគច្រើនគឺ ស្រូវ។

## ផលផល និងវារីវប្បកម្ម

ទិន្នន័យមានរយៈពេលវែងឆ្នាំអំពីផលនេសាទជាលក្ខណៈពាណិជ្ជកម្ម ទាំងផលនេសាទទឹកសាប និងសមុទ្រ។ ប៉ុន្តែស្ថិតិផលនេសាទជាផ្លូវការពុំមានទិន្នន័យអំពីការនេសាទទ្រង់ទ្រាយតូចនោះទេ ដែលអាចមានបរិមាណច្រើនធៀបនឹងផលនេសាទសរុប។ ដូចគ្នានេះដែរ ទិន្នន័យអំពីផលនេសាទសមុទ្រពុំមានការបែងចែកខុសគ្នារវាងផលនេសាទពីក្នុងតំបន់ទឹករាក់ និងផលនេសាទពីសមុទ្រក្រៅឡើយ។

ទិន្នន័យថ្មីៗ និងដែលត្រឹមត្រូវជាងមុនអំពីផលនេសាទមានការបែងចែកដោយឡែកសំរាប់សកម្មភាពនេសាទខ្លះៗទៅតាមដែននេសាទទឹកសាបមួយចំនួន ដូចជាការនេសាទដោយឧបករណ៍ដាយ នៅតាមដងទន្លេសាប និងពីករណីសិក្សាមួយចំនួននៅក្នុងឡូតិ៍នេសាទខ្លះៗក្នុងបឹងទន្លេសាប។ ក្រៅពីនេះក៏មានរបាយការណ៍អំពីការចិញ្ចឹមត្រីនៅក្នុងប្រព័ន្ធនានា ដូចជា ស្រះ បែរ ស៊ង និងវាលស្រែផងដែរ។ ប៉ុន្តែ ទិន្នន័យទាំងនេះពុំមានរាប់បញ្ចូលការចិញ្ចឹមត្រីតាមទ្រង់ទ្រាយតូច ដែលធ្វើឡើងដោយកសិករ ជាពិសេសនៅក្នុងប្រព័ន្ធចិញ្ចឹមតាមស្រះដែលទ្រទ្រង់ដោយអង្គការមិនមែនរដ្ឋាភិបាលឡើយ។ ទិន្នន័យអំពីផលនេសាទកែច្នៃ និងវិធីសាស្ត្រកែច្នៃ មានតែអំពីការកែច្នៃទ្រង់ទ្រាយមធ្យម និងទ្រង់ទ្រាយធំតែប៉ុណ្ណោះ ។ មានទិន្នន័យមួយចំនួនអំពីផលនេសាទពីវាលស្រែ ពិសេសពីបណ្តាខេត្តនៅភាគខាងកើតនៃផ្ទៃប្រទេស ប៉ុន្តែទិន្នន័យទាំងនោះមានសំរាប់ខេត្តតិចតួចពេក ដែលពុំអាចតំណាងឱ្យផលនេសាទក្នុងវាលស្រែតាមបណ្តាខេត្តជាច្រើនបានឡើយ។ ទិន្នន័យខ្លះអំពីផលនេសាទសរុបពីដែននេសាទទឹកសាប និងសំរាប់ទូទាំងប្រទេស មានជាតួលេខប៉ាន់ស្មាន ដោយសារមានរួមបញ្ចូលបរិមាណប៉ាន់ស្មានពីការនេសាទទ្រង់ទ្រាយតូច និងដោយសារកត្តាជាច្រើនផ្សេងទៀត ត្រូវបានទទួលស្គាល់ថាមានភាពត្រឹមត្រូវជាង។

មានរបាយការណ៍ជាច្រើនស្តីពីការគ្រប់គ្រងវិស័យជលផល។ របាយការណ៍ទាំងនោះថែងអំពីការនេសាទ និងការគ្រប់គ្រងជលផលនៅទូទាំងប្រទេស ព្រមទាំងអំពីបញ្ហាជាក់លាក់នៅតាមដែននេសាទមួយចំនួនផងដែរ។ ក្រៅពីនេះក៏មានរបាយការណ៍បង្ហាញពីអត្ថប្រយោជន៍នៃត្រី និងផលិតផលត្រី នៅក្នុងសេដ្ឋកិច្ចជាតិ និងចំពោះការចិញ្ចឹមជីវិត និងការបរិភោគរបស់ប្រជាពលរដ្ឋ សិទ្ធិក្នុងការនេសាទ និងគោលនយោបាយរដ្ឋាភិបាលក្នុងការជំរុញការអភិវឌ្ឍន៍វិស័យជលផលផងដែរ។ ទិន្នន័យ និងព័ត៌មានអំពីផលិតផលនានា ដូចជា អណ្តើក ពស់ កំពឹស ផលិតផលពីឈើ និងសត្វមួយចំនួនទៀតក្នុងទឹកពុំមានកត់ត្រាឡើយ។ មានទិន្នន័យខ្លះៗអំពីកំលាំងពលកម្មដែលមានប្រើប្រាស់នៅក្នុងគ្រប់ប្រភេទ និងគ្រប់លំដាប់នៃសកម្មភាពនេសាទ រួមទាំងអ្នកនេសាទប្រចាំរដូវ និងអ្នកនេសាទដែលផ្លាស់ទីពីកន្លែងនានា។

ព័ត៌មានមួយចំនួនអំពីកត្តាបរិស្ថានដែលទាក់ទងនឹងផលិតភាពធនធានជលផលក៏មានចងក្រងផងដែរ។ ព័ត៌មានទាំងនោះមានជាអាទិ៍ អំពីទីជំរកមច្ឆជាតិ និងកត្តារូបសាស្ត្រជាច្រើន ដូចជា កំពស់ទឹកជំនន់ របបទឹកហូរក្នុងទន្លេមេគង្គ និងវិសាលភាព នៃការបាត់បង់ និងវិចរិលនៃព្រៃលិចទឹក។ ទិន្នន័យអំពីសត្វព្រៃមានត្រឹមតិចតួច សំរាប់តំបន់មួយចំនួន និងមានតែចំពោះប្រភេទដែលមានតំលៃសំរាប់ការអភិរក្សតែប៉ុណ្ណោះ។ មានទិន្នន័យ និងព័ត៌មានខ្លះៗផងដែរអំពីរុក្ខជាតិនៅក្នុងបឹងទន្លេសាប និងនៅក្នុងតំបន់វាលភក់ខេត្តស្ទឹងត្រែង។

## ការដឹកជញ្ជូន

ទិន្នន័យ និងព័ត៌មានស្ទើរតែទាំងអស់ស្តីពីទឹក និងការដឹកជញ្ជូនតាមផ្លូវទឹកមានក្រោមរូបភាពជារបាយការណ៍ផ្លូវការរបស់រដ្ឋាភិបាល។ ទិន្នន័យដែលអាចប្រើប្រាស់បាន និងពាក់ព័ន្ធគឺ ទិន្នន័យស្តីពីហេដ្ឋារចនាសម្ព័ន្ធកំពង់ផែធំៗ មធ្យោបាយ និងបរិមាណទំនិញដឹកជញ្ជូនតាមផ្លូវទឹក និងសេវាពាក់ព័ន្ធ។

ប៉ុន្តែ មានការខ្វះជាទូទៅនូវទិន្នន័យអំពីមធ្យោបាយដឹកជញ្ជូនតូចតាច ដូចជាទូកតូចៗដែលមាន ឬគ្មានម៉ាស៊ីន ដែលប្រជាពលរដ្ឋប្រើប្រាស់សំរាប់ការដឹកជញ្ជូនក្នុងមូលដ្ឋាន និងសំរាប់ការតាំងលំនៅរបស់ខ្លួន។

## ទេសចរណ៍ និងការកំសាន្ត

ទិន្នន័យ និងព័ត៌មានទាក់ទងនឹងទេសចរណ៍ និងការកំសាន្ត និងសេវាពាក់ព័ន្ធនានានៅក្នុងតំបន់ដីសើមពុំទាន់បានកំណត់ច្បាស់លាស់នៅឡើយទេ និង/ឬមានការបែកចេញពីទិន្នន័យស្ថិតិចំនួនភ្ញៀវទេសចរសរុបនៅឡើយទេ។ ពុំមានទិន្នន័យ និងព័ត៌មាននៅឡើយស្តីពីចំនួនភ្ញៀវទេសចរ ទីតាំង និងសមត្ថភាពនៃទីតាំងតំបន់ដីសើមនានាក្នុងការទទួលភ្ញៀវទេសចរក្នុងចំនួនណាមួយពិតប្រាកដ ចំនួនភ្ញៀវទេសចរប្រចាំឆ្នាំមកកំសាន្តនៅទីតាំងណាមួយ ប្រាក់ចំណូលប្រចាំឆ្នាំ និងប្រាក់កំរៃរកបាននៅក្នុងរមណីយដ្ឋាននីមួយៗ ចំនួនទីតាំងអ្នកលក់ផលិតផលនានានៅក្នុងរមណីយដ្ឋាន ចំនួនប្រាក់ចំណាយជាមធ្យមនៃភ្ញៀវទេសចរម្នាក់ៗនៅទីតាំងនីមួយៗ ចំនួន និងប្រាក់ចំណូលពីសេវានៅក្នុងរមណីយដ្ឋាននីមួយៗ អត្រានៃការវិនិយោគនៅក្នុងទីតាំងកំសាន្តនីមួយៗក្នុងតំបន់ដីសើម ចំនួនភ្ញៀវទេសចរធ្វើដំណើរតាមទូក និងសំរាប់ខេត្តនានាក្រៅពីខេត្តសៀមរាប និងក្រុងភ្នំពេញ។

## ការបំពុល

ទិន្នន័យស្តីពីបរិមាណសំណល់ពីឧស្សាហកម្ម និងបរិមាណសំណល់រាវដែលបានធ្វើប្រព្រឹត្តកម្មសំអាតមានចងក្រងសំរាប់ឧស្សាហកម្មមួយចំនួន។ តួលេខស្តីពីប្រាក់ចំណូលពីការផាកពិន័យចំពោះបទល្មើសនឹងច្បាប់បរិស្ថានមានកត់ត្រារួចមកហើយ។ ប៉ុន្តែ ទិន្នន័យទាំងនេះនៅពុំទាន់អាចទុកចិត្តបាននៅឡើយទេ។ ទិន្នន័យអំពីបរិមាណសំណល់រាវពីទីក្រុង ត្រូវបានប៉ាន់ស្មានសំរាប់ទីរួមខេត្តមួយចំនួន (ដូចជា ខេត្តសៀមរាប បាត់ដំបង កំពង់ចាម និងខេត្តនៅតាមតំបន់ឆ្នេរ)។

## ទិន្នន័យទាក់ទងនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ

ជាទូទៅ ទិន្នន័យនេះទាក់ទងជាបឋមនឹងផលិតកម្ម និង/ឬការប្រើប្រាស់ខ្នាតធំ និងជាលក្ខណៈពាណិជ្ជកម្ម។ ទិន្នន័យភាគច្រើនពាក់ព័ន្ធអំពីជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ និងទិន្នន័យអំពីផលិតផលស្រូវ។ ទិន្នន័យទាំងនេះត្រូវបាន

ប្រមូលនៅតាមមូលដ្ឋាន និងបញ្ចូលគ្នានៅថ្នាក់ខេត្តមុនពេលរៀបចំ និងដាក់ជូនទៅថ្នាក់ជាតិ។ ទិន្នន័យដែលឆ្លុះបញ្ចាំងច្បាស់លាស់ជាងគេអំពីជីវភាពរស់នៅរបស់ជនក្រីក្រ គឺទិន្នន័យដែលប្រមូលនៅតាមមូលដ្ឋាន។

# ៣. តំបន់ដីសើមក្នុងប្រទេសកម្ពុជា

## ៣.១ ទស្សនៈទានអំពីតំបន់ដីសើមក្នុងប្រទេសកម្ពុជា

ទស្សនៈទានអំពីតំបន់ដីសើមបានការទទួលស្គាល់ទូលំទូលាយ ក្នុងចំណោមក្រុមមនុស្សជាច្រើននៅក្រោយការចុះហត្ថលេខាលើអនុសញ្ញាស្តីពីតំបន់ដីសើម នៅទីក្រុងរ៉ាមសារ ប្រទេសអ៊ីរ៉ង់ ក្នុងឆ្នាំ ១៩៧១។ ប៉ុន្តែ ទស្សនៈទាននេះនៅពុំទាន់បានជ្រួតជ្រាបនៅឡើយក្នុងចំណោមស្ថាប័ននានា និងអ្នកពាក់ព័ន្ធក្នុងប្រទេសកម្ពុជារហូតដល់ដើមទសវត្សរ៍ឆ្នាំ ១៩៩០។ ជាបឋម កង្វះពាក្យជាភាសាខ្មែរសំរាប់ទស្សនទាននេះ បានក្លាយជាឧបសគ្គចំបងក្នុងការប្រាស្រ័យទាក់ទងអំពីប្រការនេះ។ នៅពេលឯកសារដំបូងពីរទាក់ទងនឹងតំបន់ដីសើម (Davies and Claridge 1993; Rees 1990) ត្រូវបានបកប្រែពីភាសាអង់គ្លេសមកជាភាសាខ្មែរ ពាក្យនេះត្រូវបានបកប្រែថា "ទំនាបលិចទឹក"។ ការយល់ឃើញថា តំបន់ដីសើមជាទំនាបលិចទឹកងាយស្រួលយល់ណាស់ ព្រោះថា ៩០% នៃផ្ទៃប្រទេសកម្ពុជាស្ថិតនៅក្នុងអាងទន្លេមេគង្គ និងរងការជន់លិចប្រចាំឆ្នាំពីទឹកទន្លេមេគង្គ (MoE 1999)។

នៅក្នុងសិក្ខាសាលាមួយស្តីពីតំបន់ដីសើមដែលបានរៀបចំឡើងក្នុងទីក្រុងភ្នំពេញនៅដើមឆ្នាំ ១៩៩៤ មានការមិនឯកភាពចំពោះការបកប្រែពាក្យ "wetlands" (ជាភាសាអង់គ្លេស) ឬ "zones humides" (ជាភាសាបារាំង) មកជាភាសាខ្មែរ "ដីសើម" ដែលមានន័យថា "រាល់ទីកន្លែងដែលសើម"។ ក្រោយមកដើម្បីឱ្យការប្រើប្រាស់ពាក្យនេះផ្តល់អត្ថន័យមិនត្រឹមតែកន្លែងនានាដែលសើមនោះ មានការឯកភាពប្រើប្រាស់ពាក្យថា "តំបន់ដីសើម" ជាជំនួសវិញ ។

ទោះបីមានការមិនឯកភាពខ្លះៗក្នុងការប្រើប្រាស់ពាក្យនេះក្នុងភាសាខ្មែរក្តី ពាក្យថា "តំបន់ដីសើម" ត្រូវបានប្រើប្រាស់កាន់តែច្រើនឡើងនៅក្នុងឯកសារសរសេរ។ ពាក្យនេះត្រូវបានប្រើប្រាស់ជាផ្លូវការនៅពេលដែលប្រមុខរដ្ឋបានចុះហត្ថលេខាលើក្រម[១] នៅក្នុងឆ្នាំ ១៩៩៦ ដែលគាំទ្រសំណើកំណត់ទីតាំងតំបន់ដីសើមបីកន្លែងជាតំបន់រ៉ាមសារដំបូងបង្អស់ក្នុងប្រទេស។

ទោះបីជាបែបនេះក្តី ប្រជាពលរដ្ឋធម្មតាដែលរស់នៅក្នុងទីជនបទ ដែលមានការអប់រំទាប និងដែលភាគច្រើនជាអ្នកប្រើប្រាស់តំបន់ដីសើមដោយផ្ទាល់ មិនទាន់យល់ពាក្យនេះភ្លាមៗនៅឡើយទេ។ ទោះបីពាក្យនេះបានប្រើប្រាស់កាន់តែច្រើនឡើងហើយក្តី ក្រៅពីបឹងទន្លេសាប ដងទន្លេមេគង្គ និងទំនាបទន្លេបាសាក់ ជាទូទៅមានការយល់ដឹងតិចតួចតែប៉ុណ្ណោះអំពីទីតាំង និងវិសាលភាពនៃតំបន់ដីសើមនៅក្នុងប្រទេស។

## ៣.២ លក្ខណៈនៃតំបន់ដីសើម

ទោះបីមានកិច្ចប្រឹងប្រែងជាច្រើនដើម្បីកំណត់និយមន័យ និងបែងចែកតំបន់ដីសើមជាក្រុមទាំងនៅក្នុងប្រទេស និងនៅគិរីតំបន់ក្តី ប្រទេសកម្ពុជានៅពុំទាន់មាននិយមន័យជាតិសំរាប់តំបន់ដីសើមនៅឡើយទេ។ ហេតុនេះ ជាញឹកញាប់មាន

---

[១] ឯកសារគតិយុត្តច្បាប់ចុះហត្ថលេខាដោយប្រមុខរដ្ឋដើម្បីប្រកាសឱ្យប្រើច្បាប់ដែលអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភា។

ការប្រើប្រាស់និយមន័យដែលមានចែងក្នុងអនុសញ្ញារ៉ាមសារ (សូមអានប្រអប់ទី ១) ទោះបី ពុំទាន់មានការយល់ដឹងបានទាំងស្រុងអំពីអត្ថន័យទាំងមូលនៃនិយមន័យនេះក៏ដោយ។ គំរោង MRC-DANIDA (គណៈកម្មការទន្លេមេគង្គ - ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក់) ស្តីពី "សារពើភ័ណ្ឌ និងការគ្រប់គ្រងតំបន់ដីសើមប្រទេសកម្ពុជា ជំហានទី I" បានព្យាយាមកំណត់និយមន័យតំបន់ដីសើមនៅក្នុងបរិបទនៃប្រទេសកម្ពុជា ថាជាតំបន់ដែលមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម (RGC 2000):

- វត្តមានរុក្ខជាតិ hydrophytic ពោលគឺរុក្ខជាតិដែលអាចធន់ទ្រាំនឹងការលិចលង់រយៈពេលលើសពីប្រាំមួយសប្តាហ៍
- ដីដែលត្រូវបានចាត់ទុកថាជាប្រភេទដីផ្អែតទឹក (hydric soils) និង
- តំបន់ដែលលិចទឹកក្នុងរយៈពេលមួយ ជារៀងរាល់ឆ្នាំ ឬជាញឹកញាប់ ។

**ប្រអប់ទី ១. និយមន័យតំបន់ដីសើមតាមអនុសញ្ញារ៉ាមសារ (UNESCO 1994)**

"...តំបន់ដីវាលភក់ ដីអំពុករុក្ខជាតិ ឬលំហទឹក ដែលជាទឹកធម្មជាតិ ឬដែលកើតឡើងដោយសិប្បនិម្មិត ដែលមានទឹកជាអចិន្ត្រៃយ៍ ឬតាមរដូវ មានទឹកនឹង ឬហូរ ទឹកសាប ភ្លាវ ឬប្រៃ រួមទាំងដែនទឹកសមុទ្រ ដែលមានជំរៅតិចជាងប្រាំមួយម៉ែត្រនៅពេលទឹកនាច ។"

ដោយសារប្រទេសកម្ពុជាមានលក្ខណៈជាវាលរាប តំបន់ជាច្រើន រួមទាំងតំបន់តាំងទីលំនៅ ស្ថិតនៅក្នុងតំបន់ដីសើម។ តំបន់ដីសើមមានលក្ខណៈខុសគ្នា តាមទំហំ សណ្ឋាន ប្រភេទសត្វ និងរុក្ខជាតិដែលមាននៅក្នុងនោះ សណ្ឋាននៃដំណុះរុក្ខជាតិ ប្រភេទដី ភូគព្ភសាស្ត្រ ចំណោត គុណភាពទឹក រយៈពេលមានទឹក លំហូរទឹក ជំរៅទឹក សណ្ឋាននៃទឹកហូរចេញ pH វត្តមានសារធាតុចិញ្ចឹម និងសំណុំលក្ខណៈជាច្រើនផ្សេងទៀត (Said et al. ។ ផ្អែកតាមសំណុំលក្ខណៈខាងលើ សណ្ឋានដែលកំណត់លក្ខណៈនៃតំបន់ដីសើម មានជាអាទិ៍ វត្តមាននៃផ្ទៃទឹកដែលគ្មានរុក្ខជាតិ និងជំពូកនៃសហគមន៍រុក្ខជាតិ និងសត្វ ដែលដុះ និងរស់នៅក្នុងតំបន់នោះ។ ប៉ុន្តែ ដោយសារមានទឹកជន់លិចតាមរដូវ លក្ខណៈខ្លះ១មួយចំនួនអាចឃើញមានតែក្នុងរដូវខ្លះ១តែប៉ុណ្ណោះ ។ នេះគឺជាសំណុំលក្ខណៈដែលមានជាទូទៅសំរាប់តំបន់ដីសើមក្នុងប្រទេសកម្ពុជា ។

## ៣.៣ របាយ និងប្រភេទតំបន់ដីសើមក្នុងប្រទេសកម្ពុជា

ទីតាំងចំបង១នៃតំបន់ដីសើមក្នុងដែនទឹកសាបនៃប្រទេសកម្ពុជាអាចត្រូវបានចែកជាបីតំបន់ចំបង១គឺ ទន្លេមេគង្គមានប្រវែង ៤៦៨គ.ម រួមជាមួយទំនាបលិចទឹកនៃទន្លេនេះ បឹងទន្លេសាប (ដែលមានទំហំប្រែប្រួលរវាង២.៥០០គ.ម² និង ១៣.០០០គ.ម²) រួមជាមួយទំនាបលិចទឹក នៃបឹងនេះនិងស្ទឹងសែន (មានទំហំប្រមាណ ៣.០០០គ.ម²)។ តំបន់ដីសើមនៅតាមតំបន់ឆ្នេរសមុទ្រមានជាអាទិ៍ ស្ទឹងកោះប៉ោ និងស្ទឹងកែប ដែលសុទ្ធតែស្ថិតនៅភាគនិរតីនៃប្រទេសនេះ។

ទំនាក់ទំនងរបបជលសាស្ត្រដោយឡែកប្រចាំរដូវបែបនេះរវាងទន្លេមេគង្គ និងបឹងទន្លេសាប ដើរតួយ៉ាងសំខាន់នៅក្នុងប្រព័ន្ធអេកូឡូស៊ី និង សេដ្ឋកិច្ច-សង្គមនៃតំបន់នេះ ព្រមទាំងការចិញ្ចឹមជីវិតរបស់ប្រជាជន។ ដោយសារផ្ទៃដីនៅក្នុងប្រទេសមានលក្ខណៈជាវាលរាប ទឹកជំនន់បានធ្វើឱ្យទិដ្ឋភាពនៃតំបន់ដីសើមប្រែប្រួលយ៉ាងខ្លាំងទៅតាមរដូវ។ ទឹកដែលហូរចូលពីទន្លេមេគង្គ និងពីប្រព័ន្ធទន្លេជាច្រើននៅក្នុងទីជំរាលនៃបឹងទន្លេសាប បន្ថែមជាមួយចរន្តទឹកដែលហូរច្រាសត្រលប់ពីបឹងនេះនៅក្នុងរដូវប្រាំង បានធ្វើឱ្យតំបន់ទាំងមូលមាននាទីដូចជាប្រព័ន្ធពីរផ្សេងគ្នានៅក្នុងរដូវខុសគ្នានៃឆ្នាំនីមួយ១។

ការជន់លិចនៅក្នុងរដូវវស្សាបានបំលែងផ្ទៃដីទំនាបធំធេងនៅភាគកណ្តាលនៃផ្ទៃប្រទេស ទៅជាប្រព័ន្ធដែនទឹកដ៏ធំល្វឹងល្វើយ។ នៅរដូវប្រាំង ប្រព័ន្ធបឹងនេះបានបែកជាប្រព័ន្ធដីសើមតូចៗខុសគ្នាជាច្រើន។ នៅពេលទឹកមានរយៈកំពស់ទាប ប្រព័ន្ធផ្ទៃទឹកតូចៗជាច្រើន ដែលបន្តជាប់គ្នា ឬនៅដាច់ពីគ្នាបានកើតឡើងនៅក្នុងប្រព័ន្ធព្រៃលិចទឹកនៃទំនាបបឹងទន្លេសាប ដែលលាតសន្ធឹងនៅតាមសងខាងដងទន្លេមេគង្គ និងទំនាបទន្លេបាសាក់។ តំបន់វាលភក់ និងព្រៃនាមក៏លេចឡើងនៅជុំវិញប្រព័ន្ធបឹងនានាដែលស្ថិតនៅដាច់ៗពីគ្នា។

ព្រៃលិចទឹកមានដុះនៅជាទូទៅក្នុងទំនាបលិចទឹកបឹងទន្លេសាប និងជាទូទៅលាតសន្ធឹងរវាង ២០-៣០គ.ម ប៉ុន្តែនៅក្នុងខេត្តបាត់ដំបង ព្រៃនេះលាតសន្ធឹងដល់ ៦៥គ.ម។ ក្រឡាផ្ទៃដីព្រៃលិចទឹកជុំវិញទំនាបលិចទឹកបឹងទន្លេសាបត្រូវបានរាយការណ៍ថាបានថយចុះពី ៨០០.០០០ហ.ត នៅដើមទសវត្សរ៍ឆ្នាំ ១៩៧០មកត្រឹម ៣០០.០០០ហ.តនៅចុងទសវត្សរ៍ឆ្នាំ ១៩៨០ (Dennis and Woodsworth 1992)។ វិសាលភាពនេះតំណាងឱ្យ ៨៥%នៃព្រៃលិចទឹកសរុបនៅទូទាំងប្រទេស។ ព្រៃលិចទឹកដែលមានវិសាលភាពតូចជាងក៏ត្រូវបានសង្កេតឃើញមានផងដែរនៅក្នុងទំនាបទន្លេមេគង្គ និងទន្លេបាសាក់។

តំបន់ដីសើមចំបងដែលកើតឡើងដោយសកម្មភាពមនុស្សគឺវាលស្រែ។ តំបន់ដីសើមប្រភេទនេះបានកើនវិសាលភាពជាបន្តបន្ទាប់ និងភាគច្រើនស្ថិតនៅក្នុងតំបន់ទំនាបលិចទឹក។ នៅក្នុងព្រៃលិចទឹកក៏មានចំការជាច្រើនផងដែរ ប៉ុន្តែចំការដែលមានវិសាលភាពធំជាងគេក្នុងព្រៃលិចទឹកគឺស្ថិតនៅភាគពាយ័ព្យនៃទំនាបលិចទឹកបឹងទន្លេសាបក្នុងខេត្តសៀមរាបនិងកំពង់ធំ។ ចំការមួយចំនួនផ្សេងទៀតក៏មានផងដែរនៅតាមដងទន្លេមេគង្គ ទន្លេបាសាក់ និងទន្លេសាប។ វាលស្រែ និងចំការច្រើនតែតាំងនៅលើតំបន់ដីសើមក្រោយពីកាប់ព្រៃអស់។ តំបន់ដីសើមមួយប្រភេទទៀតដែលកើតឡើងដោយសកម្មភាពមនុស្ស និងដែលកំពុងកើនវិសាលភាពផងដែរនោះគឺ កន្លែងធ្វើវារីវប្បកម្ម និងស្រះដាក់ទឹក ។ តារាងទី ១ បង្ហាញពីប្រព័ន្ធអេកូឡូស៊ីចំបងៗនៃតំបន់ដីសើមក្នុងប្រទេសកម្ពុជា រួមទាំងតំបន់ដីសើមធម្មជាតិ និងតំបន់ដីសើមកើតឡើងដោយសកម្មភាពមនុស្ស ព្រមទាំងតំបន់ដីសើមនៅតាមតំបន់ឆ្នេរសមុទ្រ។

**តារាងទី ១ វិសាលភាពនៃប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើមក្នុងប្រទេសកម្ពុជា**

| ប្រភេទទីជំរក | វិសាលភាព (ហ.ត) |
|---|---|
| ១. វាលស្រែ (១៩៩៩) | ២ ១៥៨ ០០០ |
| ២. ចំការដំណាំលិចទឹក | ៥២៥ ៩០០ |
| ៣. តំបន់លិចទឹកជាប្រចាំ | ៤១១ ១០០ |
| ៤. ព្រៃលិចទឹក | ៣៧០ ៧០០ |
| ៥. ព្រៃលិចទឹករិចរិល | ២៥៥ ៨០០ |
| ៦. ព្រៃកោងកាង (១៩៩៤) | ៨៥ ១០០ |
| ៧. វាលស្មៅលិចទឹក | ៨៤ ៩០០ |
| ៨. វាលភក់ | ១ ៤០០ |

ប្រភព: លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (1994); RGC (2001).

កំណត់សំគាល់: ទិន្នន័យសំរាប់ឆ្នាំ ១៩៩២/៩៣ លើកលែងតែមានការបញ្ជាក់។

ប្រព័ន្ធអេកូឡូស៊ីនៃតំបន់ដីសើមធម្មជាតិក្នុងតំបន់ឆ្នេរមានជាអាទិ៍ ព្រៃកោងកាង ផ្កាថ្ម ស្មៅសមុទ្រ និងវាលភក់។ ព្រៃកោងកាងមានដុះច្រើនតែនៅក្នុងខេត្តកោះកុង។ ស្រែអំបិល និងវាលស្រែ គឺជាប្រភេទតំបន់ដីសើមដែលកើតឡើងដោយសកម្មភាពមនុស្សនៅក្នុងតំបន់ឆ្នេរ ជាពិសេស នៅក្នុងខេត្តកំពត និងក្រុងកែប។

## ៣.៤ តំបន់ដីសើម និងការប្រើប្រាស់ដី

យោងតាមផែនទីចំណាត់ថ្នាក់នៃការប្រើប្រាស់ដីក្នុងឆ្នាំ១៩៩៧ ទីជំរកក្នុងតំបន់ដីសើមបានប្រែប្រួលយ៉ាងខ្លាំងដោយសារកំនើនឡើងយ៉ាងឆាប់រហ័សនៃការពង្រីកកសិកម្ម និងការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ។ ភាគច្រើននៃតំបន់ដីសើមក្នុងទីក្រុងត្រូវបានបង្ហូរទឹកចេញ ចាក់ដីបំពេញដើម្បីសង់ផ្ទះ និងអភិវឌ្ឍន៍ឧស្សាហកម្ម។ នៅទីក្រុងភ្នំពេញ អាងទឹកធម្មជាតិនិងបឹងនានាមានវិសាលភាពកាន់តែរួមតូច ដោយសារការចាក់ដីបំពេញ។ ទង្វើបែបនេះនាំឱ្យមានទឹកជំនន់លិចលង់ជាញឹកញាប់នៅតាមកន្លែងមួយចំនួនក្នុងទីក្រុងនៅពេលមានភ្លៀងធំ។ នៅខេត្តតាកែវ និងសៀមរាប ព្រៃលិចទឹកជាច្រើនកំពុងត្រូវបានកាប់រានឆ្ការដើម្បីធ្វើស្រូវប្រដេញទឹក[២] និងសំរាប់ការប្រើប្រាស់ផ្សេងៗទៀត។ នៅក្នុងអំឡុងពេលនៃគំរោងនេះ (ឆ្នាំ២០០២) មានការសង្កេតឃើញថាព្រៃនៅតាមមាត់ទន្លេក្នុងតំបន់រាំសារខេត្តស្ទឹងត្រែងបានត្រូវកាប់រានដើម្បីយកដីដាំដំណាំ និងដើម្បីយកឈើ។ មានព្រៃសម្បទានមួយចំនួននៅក្នុងតំបន់ស្ថិតនៅជាប់ជាមួយតំបន់រាំមសារខេត្តស្ទឹងត្រែង ត្រូវបានវិនិយោគដោយក្រុមហ៊ុនឯកជន។ ប្រការនេះអាចជាការគំរាមកំហែងចំពោះមុខងារនៃប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើមតាមដងទន្លេ បណ្តាលពីកំនើននៃការហូរច្រោះ និងកំណើននៃកំទេចកំណក។

### ៣.៤.១ *របាយប្រជាជនក្នុងតំបន់ដីសើម*

ទោះបីជនជាតិខ្មែរគឺជាជនជាតិភាគច្រើននៅក្នុងប្រទេសក្តី ក៏មានជនជាតិភាគតិចមួយចំនួនរស់នៅក្នុងតំបន់ដីសើមផងដែរ។ នៅក្នុងតំបន់ដីសើមដែលបានជ្រើសរើសសំរាប់ការសិក្សានេះ មានក្រុមជនជាតិភាគតិចនានារស់នៅ។

នៅក្នុងតំបន់ដីសើមក្នុងខេត្តស្ទឹងត្រែងមានក្រុមជនជាតិភាគតិចមួយចំនួនរស់នៅ ក្នុងនោះជនជាតិភាគតិចឡាវគឺជាក្រុមដែលមានចំនួនច្រើនជាងគេ។ ការបរបាញ់ កសិកម្មពនេចរ និងការនេសាទគឺជាសកម្មភាពសេដ្ឋកិច្ចចំបងរបស់ជនជាតិភាគតិចឡាវ។

នៅក្នុងតំបន់បឹងទន្លេសាប ដោយឡែកក្នុងខេត្តសៀមរាប មានសហគមន៍ជនជាតិវៀតណាមជាច្រើនរស់នៅ។ ជនជាតិខ្មែរអ៊ីស្លាមខ្លះៗក៏មានរស់នៅក្នុងឃុំភ្នំក្រោមផងដែរ ដែលការនេសាទគឺជាសកម្មភាពចំបងរបស់ពួកគេ។ ភាគច្រើននៃសហគមន៍អ្នកនេសាទក្នុងបឹងទន្លេសាបមានទំលាប់រស់នៅក្នុងភូមិបណ្តែតទឹក។

នៅក្នុងតំបន់ដីសើមខេត្តតាកែវក៏មានជនជាតិវៀតណាមរស់នៅផងដែរ។ ការជួញដូរ នេសាទ និងការធ្វើចរាចរគឺជាសកម្មភាពដែលកើតមានជាទូទៅក្នុងចំណោមក្រុមជនជាតិភាគតិចនេះ ដោយសារខេត្តតាកែវនៅជាប់ព្រំដែនជាមួយប្រទេសវៀតណាម។

---

[២] ការធ្វើស្រូវប្រដេញទឹកចាប់ផ្តើមនៅពេលទឹកចាប់ផ្តើមស្រកនៅដើមរដូវប្រាំង។

### ៣.៤.២ ការគំរាមកំហែងចំពោះតំបន់ដីសើម

**ការនេសាទច្រើនលើសកំរិត**

តំបន់ដីសើមជាច្រើនបានរងការគំរាមកំហែងដោយសារកំនើនសកម្មភាពនេសាទ ដែលបានធ្វើឡើងដើម្បីបំពេញតំរូវការនៃចំនួនប្រជាជនដែលកាន់តែកើនឡើង។ ផលិតផលនេសាទសរុបកើនឡើង ឬមានកំរិតស្ថិរភាពតិច ប៉ុន្តែត្រីដែលនេសាទបានមានទំហំកាន់តែតូច ដែលជាការបង្ហាញថាត្រីមិនអាចលូតលាស់ទាន់ឡើយ។ ការដែលបច្ចុប្បន្នអ្នកនេសាទមិនចោលកូនត្រីតូចៗទៅក្នុងទឹកវិញក៏ជាកត្តានាំឱ្យស្ថានភាពនេះកាន់តែធ្ងន់ធ្ងរឡើង។ សញ្ញាមួយផ្សេងទៀតដែលបញ្ជាក់ពីការធ្វើនេសាទច្រើនហួសកំរិតគឺការថយចុះ ជាពិសេសសមាសភាគនៃប្រភេទត្រីមួយចំនួននៅក្នុងផលនេសាទ។ មានការជជែកវែកញែកជាច្រើនអំពីមូលហេតុចំបងបណ្តាលឱ្យមានការធ្វើនេសាទច្រើនហួសកំរិត។ ប៉ុន្តែលទ្ធផលបង្ហាញឱ្យឃើញថា វាទំនងជាកើតពីសកម្មភាពរួមគ្នានៃសកម្មភាពនេសាទជាលក្ខណៈបំផ្លាញទាំងនៅក្នុងឡូត៍នេសាទ និងនៅក្នុងកន្លែងនេសាទសាធារណៈ។ ទីតាំងទាំងបីនៃតំបន់ដីសើមដែលបានជ្រើសរើសសំរាប់ការសិក្សានេះ បានជួបប្រទះនូវវិបត្តិការដូចគ្នានៃការធ្វើនេសាទហួសកំរិត។

**ការវិចវិលនៃព្រៃលិចទឹក**

ការគំរាមកំហែងធំជាងគេចំពោះព្រៃលិចទឹកគឺការរានឆ្ការព្រៃដើម្បីយកដីធ្វើកសិកម្ម ការកាប់អុស ការដុតព្រៃ និងការកាប់ឈើដើម្បីធ្វើសំរាស់។ នេះប្រហែលជាមូលហេតុដែលនាំឱ្យព្រៃលិចទឹកជាច្រើនកន្លែងត្រូវបានបំលែងទៅជាវាលព្រៃគុម្ពោត និងវាលស្មៅ។ ការរាលដាលនៃរុក្ខជាតិចង្រៃ ដូចជាកំប្លោក និងដើមប្រខ្ទបយក្ស(បន្លាយួន) ក៏អាចពាក់ព័ន្ធជាមួយកំនើននៃការបាត់បង់ព្រៃឈើផងដែរ និងកំនើននៃសារធាតុចិញ្ចឹមដែលជាប់ទាក់ទងជាមួយការបំពុលទឹក និងទឹកបញ្ចេញចោលពីដីកសិកម្ម។

**ការចាប់សត្វស្លាប និងការប្រមូលស៊ុតសត្វ**

សកម្មភាពនេះទំនងជាកើតមានជាទូទៅ ដោយហេតុថាវាផ្តល់ជាប្រភពយ៉ាងសំខាន់នៃប្រាក់ចំណូលសំរាប់គ្រួសារក្រីក្រ។ ដំណើរនៃការប្រមូលពងសត្វរួមមានការត្រាយផ្លូវ ដែលជាសកម្មភាពមានលក្ខណៈបំផ្លាញ ដើម្បីអាចធ្វើដំណើរឱ្យដល់កន្លែងមានសំបុកសត្វ។ សាច់សត្វស្លាបទឹក និងស៊ុតសត្វ មានតំលៃខ្ពស់ជាងសាច់សត្វស្លាបចិញ្ចឹម ហេតុនេះវាផ្តល់ជាការលើកទឹកចិត្តឱ្យមានការចាប់សត្វទាំងនេះកាន់តែច្រើនសំរាប់លក់ទៅទីផ្សារ។

**ការចាប់សត្វពស់ និងអណ្តើក**

សាច់សត្វពស់មានតំលៃខ្ពស់នៅទីផ្សារក្នុងប្រទេសចិន ចំណែកក្នុងប្រទេសវៀតណាមមានតំរូវការច្រើនទាំងសាច់សត្វពស់ និងអណ្តើក។ លើសពីនេះ ដោយសារកំនើនថ្លៃត្រីនៅទីផ្សារ ចំនួនសត្វពស់កាន់តែច្រើនត្រូវបានចាប់ដើម្បីធ្វើជាចំណីសំរាប់សត្វក្រពើ។

**ការរានឆ្ការទីជំរក**

កំនើននៃការតាំងទីលំនៅ ការពង្រីកដីកសិកម្ម និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ បាននាំឱ្យមានការខូចខាតទីជំរកសំខាន់ៗនៅក្នុងតំបន់ដីសើម។ បឹងទន្លេសាបគឺជាគំរូមួយបែបនៃទីជំរកធម្មជាតិ ដែលបច្ចុប្បន្ននេះហ៊ុំព័ទ្ធដោយវាលស្រែ និង

ផ្លូវជាតិដែលមានចរាចរយ៉ាងមមាញឹក។ ច្រកផ្លូវសំរាប់សត្វព្រៃ (លើកលែងតែសត្វស្លាបទឹក) ធ្វើបំលាស់ទីរវាងតំបន់ដីសើម និងព្រៃតំបន់ភ្នំកំពុងត្រូវបានរងការបំផ្លាញ។ ជាលទ្ធផល សត្វព្រៃជាច្រើន ដូចជា ដំរី ខ្លាធំ ជ្រូកព្រៃ និងសត្វក្របីព្រៃ ត្រូវបានរំខានក្នុងការធ្វើដំណើរទៅរកចំណី និងទឹកនៅក្នុងតំបន់ដីសើម។

## ការវិចវិលនៃព្រៃជាប់នឹងតំបន់ដីសើម

ការកាប់ឈើនៅក្នុងតំបន់ភ្នំនៅជុំវិញតំបន់ដីសើមក៏បង្កឱ្យមានឥទ្ធិពលអវិជ្ជមានចំពោះជីវៈចំរុះក្នុងតំបន់ដីសើមផងដែរ។ សត្វខ្លះ ដូចជា ក្រពើ អណ្តើក និងសត្វពស់ ពឹងផ្អែកលើទីជំរកព្រៃដែលស្ថិតនៅជាប់នឹងតំបន់ដីសើមសំរាប់ការបន្តពូជ។ ក្រៅពីនេះ កំណើននៃការកាប់ឈើជាទូទៅនៅជុំវិញតំបន់រាមសារក្នុងខេត្តស្ទឹងត្រែង អាចនាំឱ្យជីវៈចំរុះបាត់បង់តំលៃ ដែលបានទទួលស្គាល់ដោយសហគមន៍អន្តរជាតិ។ ទោះបីសកម្មភាពកាប់ឈើកំពុងស្ថិតនៅក្រោមការតាមដាន និងត្រួតពិនិត្យក្តី បញ្ហានេះស្ថិតនៅជាកង្វល់នៅឡើយ ដោយសារពុំមានការអនុវត្តផែនការគ្រប់គ្រងព្រៃឈើប្រកបដោយប្រសិទ្ធភាព។

## កសិកម្មពឹងផ្អែកលើប្រព័ន្ធស្រោចស្រព

ការបំលែងតំបន់ដីសើមសំរាប់គោលដៅកសិកម្មបានកើតឡើងជាទូទៅ។ តំបន់ដីសើមមួយចំនួនធំក្នុងខេត្តតាកែវ និងសៀមរាបកំពុងត្រូវបានប្រើប្រាស់សំរាប់ធ្វើស្រូវប្រដេញទឹក។ សកម្មភាពនេះបានបង្កផលប៉ះពាល់ចំពោះគុណភាពទឹក និងព្រៃលិចទឹក។ ស្រូវឡើងទឹកក៏មានដាំនៅក្នុងតំបន់ជាច្រើនផងដែរ ដូចជាបឹងទន្លេសាប។ (ប៉ុន្តែផលប៉ះពាល់នៃដំណាំបែបនេះមិនសូវធ្ងន់ធ្ងរទេ ដោយសារស្រូវប្រភេទនេះត្រូវបានដាំនៅក្នុងរដូវទឹកជំនន់ ដោយពុំមានប្រើប្រាស់ជី ឬសារធាតុគីមីច្រើនឡើយ)។ ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធស្រោចស្រពក៏អាចមានឥទ្ធិពលលើអេកូឡូស៊ីទន្លេផងដែរ ប្រសិនបើមានការកសាងប្រព័ន្ធបែបនេះកាត់ទទឹងផ្លូវទឹកសំខាន់ៗ។ ភស្តុតាងនៃផលប៉ះពាល់ខាងបរិស្ថានបណ្តាលពីការកសាងទំនប់យ៉ាលី ត្រូវបានសង្កេតឃើញនៅក្នុងតំបន់ដីសើមខ្លះៗនៅក្នុងខេត្តស្ទឹងត្រែង និងខេត្តរតនៈគីរី។ ការធ្វើកសិកម្មប្រពលវប្បកម្មបាននាំឱ្យមានកំណើននៃការប្រើប្រាស់ជីនៅក្នុងតំបន់ដីសើម ដែលមានឥទ្ធិពលទៅលើគុណភាពទឹក និងជីវៈចំរុះ។

## ការដឹកជញ្ជូន និងការប្រាស្រ័យទាក់ទង

តំបន់ដីសើមរួមចំណែកយ៉ាងសំខាន់ក្នុងការដឹកជញ្ជូន និងការប្រាស្រ័យទាក់ទងគ្នារវាងទីក្រុង និងជនបទ។ នៅពេលដែលមានកំណើននៃការដឹកជញ្ជូនបែបនេះ ចំនួនទូក និងនាវាក៏កើនឡើងផងដែរ ដែលនាំឱ្យមានកំណើននៃការរំខានចំពោះជីវៈចំរុះក្នុងតំបន់ដីសើម។ ផែ និងចំណតនាវាមួយចំនួនទំនងជានឹងត្រូវកសាងឡើងជាបន្ថែម ទន្ទឹមនឹងមានការកែលំអផ្លូវទឹកជាបន្ថែមនៅតាមស្ទឹងមួយចំនួន។ សកម្មភាពបែបនេះអាចមានផលប៉ះពាល់អវិជ្ជមានចំពោះអេកូឡូស៊ីនៅតំបន់ខ្សែទឹកខាងក្រោមនៃតំបន់ដីសើម។ ឧទាហរណ៍ៈ ប្រសិនបើមានការបំផ្លាញជួរថ្មនៅក្នុងខេត្តស្ទឹងត្រែង និងក្រចេះ ផលប៉ះពាល់អេកូឡូស៊ីអាចមានកំរិតធ្ងន់ធ្ងរ ដោយហេតុថាជួរថ្មទាំងនោះទ្រទ្រង់ការបន្តពូជនៃត្រី និងសារពាង្គកាយប្រភេទខ្លះៗ និងមាននាទីសំអាតទឹកដែលហូរឆ្លងកាត់វាផងដែរ។

## ទេសចរណ៍

តំបន់ដីសើមមានសក្តានុពលខ្ពស់សំរាប់ការអភិវឌ្ឍន៍ទេសចរណ៍នៅក្នុងប្រទេសកម្ពុជា។ ឧទាហរណ៍ៈ ខេត្តសៀមរាបបានក្លាយជាគោលដៅប្រកបដោយភាពទាក់ទាញភ្ញៀវទេសចរវប្បធម៌ និងទេសចរធម្មជាតិ។ វត្តមានសត្វព្រៃដែលមាន

សារៈសំខាន់ជាអន្តរជាតិ រួមផ្សំនឹងបេតិកភណ្ឌធម្មជាតិដោយឡែកនៅក្នុងតំបន់ជុំវិញបានធ្វើឱ្យបឹងទន្លេសាបក្លាយជាគោលដៅទេសចរណ៍សំរាប់អ្នកដែលមានចំណាប់អារម្មណ៍ចំពោះធម្មជាតិ។ ដូចគ្នានេះដែរ ចំនួនអ្នកទេសចរបរទេសកាន់តែច្រើនឡើងបានមកទស្សនាខេត្តស្ទឹងត្រែង ដើម្បីកំសាន្តសប្បាយនឹងការទស្សនាសត្វផ្សោត និងទេសភាពប្លែកៗនៃព្រៃនៅតាមដងទន្លេ។ ឧស្សាហកម្មទេសចរណ៍មានសក្តានុពលក្នុងការនាំមកនូវប្រាក់ចំណូលដ៏ច្រើនសំរាប់ប្រទេសនេះ និងសំរាប់ប្រជាពលរដ្ឋមូលដ្ឋាន។ ប៉ុន្តែសកម្មភាពទេសចរណ៍អាចមានឥទ្ធិពលអវិជ្ជមានចំពោះគុណភាពបរិស្ថាន ដោយសារការគ្រប់គ្រងសំណល់ពុំបានត្រឹមត្រូវ និងការរៀបចំផែនការអភិវឌ្ឍទីក្រុងពុំបានសមស្រប។ ទេសចរណ៍ក្នុងខេត្តសៀមរាបបានកើនឡើង ដែលមានចំនួនភ្ញៀវទេសចរមកកំសាន្តប្រមាណជាង៤០០.០០០នាក់ជារៀងរាល់ឆ្នាំ ។ ចំនួននេះត្រូវបានរំពឹងថានឹងកើនឡើងពីរដងនៅក្នុងអនាគតដ៏ខ្លីខាងមុខនេះដែលអាចនឹងនាំឱ្យមានកំនើនបន្ទុកចំពោះទីក្រុងនេះដែលតំរូវឱ្យមានហេដ្ឋារចនាសម្ព័ន្ធកាន់តែប្រសើរឡើង ប្រព័ន្ធផ្គត់ផ្គង់ទឹក និងការគ្រប់គ្រងសំណល់។ នៅតំបន់ងាយរងការខូចខាត ដូចជាដែនជំរកសត្វស្លាប ចំនួនភ្ញៀវទេសចរកាន់តែច្រើនអាចបង្កឱ្យមានផលប៉ះពាល់ជាច្រើនចំពោះអេកូឡូស៊ី និងសង្គម។

<u>គំរោងសាងសង់ទំនប់នៅលើប្រព័ន្ធទន្លេមេគង្គ</u>

ទោះបីការកសាងទំនប់នាំឱ្យមានការប្រែប្រួលយ៉ាងខ្លាំងចំពោះរបបជលសាស្ត្រនៃប្រព័ន្ធទន្លេមេគង្គ ដែលធ្វើឱ្យបាត់បង់ ឬថយចុះនូវវិសាលភាព និងចំនួនតំបន់ដីសើមក្តី រដ្ឋាភិបាលកម្ពុជានៅតែមានផែនការកសាងទំនប់វារីអគ្គិសនីជាច្រើនផងដែរ។ ទោះបីមានផែនការជាផ្លូវការដើម្បីសាងសង់ទំនប់នៅលើប្រព័ន្ធទន្លេមេគង្គក្តី រដ្ឋាភិបាលនៅខ្វះមូលធនដែលចាំបាច់សំរាប់សាងសង់គំរោងទំនប់ខ្នាតធំ។ ទោះជាយ៉ាងនេះក្តី ការសាងសង់ទំនប់លើដៃនានានៃទន្លេមេគង្គពីសំណាក់ប្រទេសផ្សេងទៀតអាចនឹងបន្តទៅជាលំដាប់។ ទង្វើបែបនេះនឹងនាំឱ្យមានផលប៉ះពាល់បន្ថែមទៀតចំពោះវដ្តនៃទឹកជំនន់ប្រចាំរដូវនៅក្នុងតំបន់ដីសើម។

## ៤. ក្របខ័ណ្ឌស្ថាប័ន និងច្បាប់

### ៤.១ ក្របខ័ណ្ឌស្ថាប័ន

#### *៤.១.១ ស្ថានភាពនៃការចាត់ចែងស្ថាប័ន*

ភាពប្លែកៗគ្នានៃធនធាន និងមុខងាររបស់តំបន់ដីសើមគឺជាមូលហេតុនាំឱ្យការចាត់ចែងស្ថាប័នមានលក្ខណៈស្មុគស្មាញ សំរាប់ការអភិវឌ្ឍន៍ កសាងផែនការ និងគ្រប់គ្រងតំបន់ដីសើម។ ធនធានទាំងអស់នៃតំបន់ដីសើមត្រូវបានចាត់ទុកថាជាទ្រព្យសម្បត្តិរបស់រដ្ឋ និងត្រូវបានចាត់ចែងគ្រប់គ្រងអនុលោមតាមច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ពោលគឺរដ្ឋធម្មនុញ្ញ។ យោងតាមរដ្ឋធម្មនុញ្ញកម្ពុជា រចនាសម្ព័ន្ធនៃអំណាចរបស់រដ្ឋ ត្រូវបានចែកជាបីផ្នែកជាគន្លឹះគឺ៖ ព្រឹទ្ធសភា និងរដ្ឋសភាជាតិ គណៈរដ្ឋមន្ត្រី និងតុលាការ។ ព្រឹទ្ធសភា (ដែលមានសមាជិកចំនួន៦១រូប) និងរដ្ឋសភាជាតិ (មានសមាជិកចំនួន ១២៣រូប) មានអំណាចក្នុងការអនុម័តនិងតាក់តែងច្បាប់ព្រមទាំងបទប្បញ្ញត្តិនានាសំរាប់គ្រប់គ្រងធនធានទាំងអស់នៅក្នុងប្រទេស។ គណៈរដ្ឋមន្ត្រី រួមមាន នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ព្រមទាំងមានអំណាចគ្រប់គ្រង អនុលោមតាមរដ្ឋធម្មនុញ្ញ និងច្បាប់ដែលបានអនុម័តដោយសភាជាតិ។ តាមធម្មតា រាល់សំណើច្បាប់ត្រូវបានដាក់ជូនសំរាប់ការពិភាក្សាក្នុងចំណោមរដ្ឋមន្ត្រីនានា ដើម្បីធ្វើឱ្យប្រាកដថាមានការឯកភាពមតិមុនពេលដាក់ជូនទៅសភាជាតិដើម្បីសុំការអនុម័ត។ លើសពីនេះ នាយករដ្ឋមន្ត្រីមានអំណាចក្នុងការចេញអនុក្រឹត្យ និងបទប្បញ្ញត្តិនានាដែលបានស្នើ

ឡើងដោយក្រសួងនានា។ យោងតាមរដ្ឋធម្មនុញ្ញ ប្រជាពលរដ្ឋគឺជាម្ចាស់អំណាច ប៉ុន្តែអំណាចទាំងនោះត្រូវបានអនុវត្តតាមរយៈតំណាងរបស់ពួកគេ ដែលបានជ្រើសតាំងជាសមាជិកសភា ដោយការបោះឆ្នោតរៀងរាល់ប្រាំឆ្នាំម្តង។ តុលាការ និងចៅក្រមមានអំណាចធ្វើសេចក្តីសំរេចតាមផ្លូវច្បាប់ដើម្បីដោះស្រាយ ទំនាស់និងធ្វើឱ្យប្រាកដថា ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបគោរពច្បាប់ ។

ពុំមានក្រសួងណាមួយតែឯងទទួលខុសត្រូវគ្រប់គ្រងតំបន់ដីសើមឡើយ។ មានវិស័យជាច្រើនទាក់ទងជាមួយតំបន់ដីសើម ជាអាទិ៍ កសិកម្ម ព្រៃឈើ ជលផល ការគ្រប់គ្រងទឹក បរិស្ថាន នាវាចរ ទេសចរណ៍ និងការកំសាន្ត ។ល។ ក្រសួងជាច្រើនមានភារៈទទួលខុសត្រូវលើវិស័យមួយចំនួនដូចមានបង្ហាញខាងក្រោម ។ក្របខ័ណ្ឌនេះមានសង្ខេបជូនក្នុងតារាងទី ២។

តារាងទី ២. ការចាត់ចែងស្ថាប័ន និងក្របខ័ណ្ឌច្បាប់

| ក្រសួង | ផ្នែកពាក់ព័ន្ធ | នាយកដ្ឋាន/អង្គភាពពាក់ព័ន្ធ | ច្បាប់ និងបទប្បញ្ញត្តិ | សេចក្ដីសង្កេត |
|---|---|---|---|---|
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | • ជលផល និងធនធានក្នុងទឹក<br>• កសិកម្ម<br>• ព្រៃឈើ<br>• សត្វព្រៃ<br>• សិទ្ធិសហគមន៍ | • នាយកដ្ឋានជលផល<br>• នាយកដ្ឋានកៅស៊ូ/ក្សេត្រសាស្ត្រ និងកែលំអគុណភាពដី<br>• រដ្ឋបាលព្រៃឈើ | • ច្បាប់ជលផល<br>• ច្បាប់ព្រៃឈើ<br>• អនុក្រឹត្យស្ដីពីស្ដង់ដារ និងការគ្រប់គ្រងសំភារៈកសិកម្ម<br>• អនុក្រឹត្យស្ដីពីសហគមន៍នេសាទ | ច្បាប់ជលផលបានដាក់ជូនសភារួចហើយនិងកំពុងរងចាំការអនុម័ត ។ អនុក្រឹត្យស្ដីពីការគ្រប់គ្រងសហគមន៍នេសាទត្រូវបានអនុម័តរួចនៅ២០០៥ ។ |
| ក្រសួងបរិស្ថាន | • តំបន់ការពារធម្មជាតិ<br>• តំបន់ដីសើម និងតំបន់ឆ្នេរ<br>• ការបំពុលទឹក<br>• សំណល់រឹង<br>• វាយតំលៃហេតុប៉ះពាល់បរិស្ថាន | • នាយកដ្ឋានការពារអភិរក្សធម្មជាតិ<br>• នាយកដ្ឋានត្រួតត្រាការបំពុល<br>• នាយកដ្ឋានវាយតំលៃហេតុប៉ះពាល់បរិស្ថាន | • ច្បាប់បរិស្ថាន<br>• ព្រះរាជក្រឹត្យស្ដីពីតំបន់ការពារធម្មជាតិ<br>• អនុក្រឹត្យស្ដីពីការបំពុលទឹក<br>• អនុក្រឹត្យស្ដីពីសំណល់រឹង<br>• អនុក្រឹត្យស្ដីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន | មានគោលនយោបាយជាច្រើនទៀត ជាអាទិ៍ ផែនការបរិស្ថានជាតិ ផែនការសកម្មភាពជីវៈចំរុះ និងផែនការសកម្មភាពតំបន់ដីសើមជាតិដែលពុំទាន់បានអនុម័តនៅឡើយ ។ច្បាប់ស្ដីពីតំបន់ការពារធម្មជាតិនៅជាសេចក្ដីព្រាង ។ |
| ក្រសួងធនធានទឹក និងឧតុនិយម | • ថាមពល<br>• ការស្រោចស្រព | • នាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក<br>• នាយកដ្ឋានធារាសាស្ត្រ និងដោះស្រាយទឹក<br>• អង្គការសហគមន៍ | • ច្បាប់ទឹក<br>• លក្ខន្តិកៈសហគមន៍កសិករប្រើប្រាស់ទឹក | ច្បាប់ទឹកនៅពុំទាន់អនុម័តនៅឡើយទេ។ អនុក្រឹត្យ និងប្រកាសកំពុងត្រូវរៀបចំ។ |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | • ការប្រើប្រាស់ដីធ្លី<br>• កម្មសិទ្ធិ និងការកាន់កាប់ដីធ្លី | • នាយកដ្ឋានភូមិបាល<br>• នាយកដ្ឋានផែនការប្រើប្រាស់ដីធ្លី | • ច្បាប់ភូមិបាល | បានអនុម័តនៅឆ្នាំ ២០០១ ។ |

| | | | | |
|---|---|---|---|---|
| ក្រសួងអភិវឌ្ឍន៍ជនបទ | • ផ្គត់ផ្គង់ទឹកនៅជនបទ<br>• ថែទាំសុខភាពនៅជនបទ<br>• អភិវឌ្ឍន៍សហគមន៍<br>• សេដ្ឋកិច្ចជនបទ | • នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ | • ក្រុមប្រឹក្សារៀបចំយន្តការអភិវឌ្ឍន៍កសិកម្មជនបទ | |
| ក្រសួងសាធារណៈការ និងដឹកជញ្ជូន | • នាវាចរ | • នាយកដ្ឋានទឹកស្អាត | • អនុក្រិត្យស្តីពីការដឹកជញ្ជូនឯកជន<br>• អនុក្រិត្យស្តីពីនាវាចរតាមទន្លេ | |
| ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | • ទំនប់វារីអគ្គិសនី | • នាយកដ្ឋានវារីអគ្គិសនី | | ការគ្រប់គ្រងអនុលោមតាមច្បាប់ទឹក អនុក្រិត្យស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងបទបញ្ជាស្តីពីការប្រើប្រាស់ទឹករបស់គណកម្មការទន្លេមេគង្គ ។ |
| ក្រសួងទេសចរណ៍ | • ក្រុមហ៊ុនទេសចរណ៍<br>• ទីភ្នាក់ងារទេសចរណ៍<br>• មគ្គុទេសក៍ទេសចរណ៍ | | • សេចក្តីព្រាងច្បាប់ស្តីពីទេសចរណ៍ និងការកំសាន្ត | |
| គណៈកម្មាធិការជាតិទន្លេមេគង្គ | • សំរបសំរួលការអភិវឌ្ឍន៍ធនធានទឹកដោយចីរភាព<br>• ត្រួតពិនិត្យ<br>• ព័ត៌មាន | • ផ្នែកកម្មវិធីប្រើប្រាស់ទឹក<br>• ផ្នែកផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ<br>• លេខាធិការដ្ឋានជីវៈមណ្ឌលបឹងទន្លេសាប<br>• នាយកដ្ឋានអភិវឌ្ឍន៍តំរោង | • កិច្ចព្រមព្រៀង MRC<br>• បទបញ្ជាស្តីពីការប្រើប្រាស់ទឹក | |

## ក្រសួងបរិស្ថាន

ក្រសួងបរិស្ថានត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៣ និងមានអណត្តិទូលំទូលាយពាក់ព័ន្ធនឹងកិច្ចការពារ អភិរក្ស និងអភិវឌ្ឍន៍បរិស្ថាន និងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ មាត្រាគន្លឹះដែលផ្តល់អំណាចដល់ក្រសួងបរិស្ថាន មានចែងនៅក្នុងច្បាប់បរិស្ថាន(ខែធ្នូឆ្នាំ ១៩៩៦) ច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន (ខែមករាឆ្នាំ ១៩៩៦) និងអនុក្រឹត្យស្តីពី ការបង្កើត និងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន (ខែកញ្ញា ឆ្នាំ១៩៩៧)។ ក្រសួងមានមន្ត្រីចំនួន ៦០០នាក់នៅថ្នាក់ជាតិ និងប្រមាណ ៦០០ នាក់ផ្សេងទៀតនៅតាមបណ្តាខេត្តនានា។ គោលដៅសំខាន់នៃក្រសួងនេះគឺ :

- លើកកំពស់គុណភាព និងសុខភាពសាធារណៈ តាមរយៈការត្រួតត្រាការបំពុល
- ធានាឱ្យមានការអភិរក្ស អភិវឌ្ឍន៍ ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ ដោយឈ្លាសវៃ និងនិរន្តរភាព
- ធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន
- លើកកំពស់ការចូលរួមជាសាធារណៈនៅក្នុងការធ្វើសេចក្តីសំរេច ការគ្រប់គ្រង និងការពង្រឹងការអនុវត្តន៍ច្បាប់។

មាននាយកដ្ឋានចំនួនបីនៅក្នុងក្រសួងបរិស្ថាន ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ដីសើមគឺ :

- **នាយកដ្ឋានការពារអភិរក្សធម្មជាតិ** ដែលទទួលខុសត្រូវជាចំបងក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងអភិរក្សជីវៈចំរុះ ។ ការិយាល័យចំនួនពីរដែលទាក់ទងនឹងការគ្រប់គ្រងតំបន់ដីសើមគឺ ការិយាល័យតំបន់ដីសើម ទឹកដីរាល និងតំបន់ឆ្នេរ និងការិយាល័យតំបន់ប្រើប្រាស់ច្រើនយ៉ាង និងតំបន់ការពារទេសភាព ។ ព្រះរាជក្រឹត្យ(ឆ្នាំ ១៩៩៣) គឺជាបរិបទច្បាប់ដ៏សំខាន់សំរាប់តំរង់ទិសការងាររបស់នាយកដ្ឋាននេះ ។ នាយកដ្ឋាននេះ គឺជាស្ថាប័នបង្គោលសំរាប់អនុសញ្ញាមួយចំនួន ដូចជា អនុសញ្ញារ៉ាមសារ និងអនុសញ្ញាស្តីពីជីវៈចំរុះ ។ នាយកដ្ឋាននេះកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ។
- **នាយកដ្ឋានត្រួតត្រាការបំពុល** ទទួលខុសត្រូវត្រួតត្រាការបំពុលនៅទូទាំងប្រទេស ជាអាទិ៍ ការបំពុលខ្យល់ ទឹក និងការបំពុលដោយសំណល់រឹង។ អនុក្រឹត្យមួយចំនួនពាក់ព័ន្ធនឹងការងាររបស់នាយកដ្ឋាននេះ មានជាអាទិ៍ អនុក្រឹត្យស្តីពីការត្រួតត្រាការបំពុល (ឆ្នាំ១៩៩៨) អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង (ឆ្នាំ១៩៩៩) និងអនុក្រឹត្យស្តីពីការត្រួតត្រាការបំពុលខ្យល់ និងការរំខានដោយសំលេង (ឆ្នាំ ២០០០)។
- **នាយកដ្ឋានពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន** ទទួលខុសត្រូវលើការវាយតំលៃហេតុប៉ះពាល់បរិស្ថានសំរាប់គ្រប់គំរោង ដែលនេះជាមធ្យោបាយដើម្បីធានាថាការអភិវឌ្ឍន៍ មានផលប៉ះពាល់បរិស្ថាន និងសង្គម ក្នុងកំរិតអប្បបរមាសំរាប់រយៈពេលយូរអង្វែង។

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគឺជាស្ថាប័នចាស់ជាងគេមួយ។ ក្រសួងនេះមានអាណត្តិទូលំទូលាយទាក់ទងនឹងការអភិវឌ្ឍន៍ និងគ្រប់គ្រងការងារកសិកម្ម និងធនធានធម្មជាតិ។ ផ្នែកសំខាន់ៗដែលពាក់ព័ន្ធមានជាអាទិ៍ :

- កសិកម្ម ការកែលំអគុណភាពដី និងក្សេត្រសាស្ត្រ
- ផលិតកម្ម និងបសុព្យាបាល
- កសិ-ឧស្សាហកម្ម
- ព្រៃឈើ និងសត្វព្រៃ
- ជលផល ។

ក្រសួងកសិកម្មមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍន៍ និងការពារតំបន់ដីសើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រសួងនេះមាននាយកដ្ឋានបច្ចេកទេសចំនួន១២ ដែលក្នុងនោះនាយកដ្ឋានបីដូចខាងក្រោមនេះមានការទទួលខុសត្រូវច្រើនជាងគេទាក់ទងនឹងការគ្រប់គ្រងតំបន់ដីសើម ។

*នាយកដ្ឋានជលផល*

នាយកដ្ឋាននេះទទួលខុសត្រូវគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានជលផល។ ច្បាប់ជលផលចែងអំពីក្របខ័ណ្ឌសំរាប់គ្រប់គ្រង ការពារ អភិរក្ស ប្រើប្រាស់ ការធ្វើអាជីវកម្ម និងការអភិវឌ្ឍន៍ធនធានជលផល ដើម្បីធានានិរន្តរភាពធនធានជលផល សំរាប់ជាប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន។ លើសពីនេះ នាយកដ្ឋាននេះអនុវត្តភារកិច្ចតាមអនុក្រឹត្យមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងដែននេសាទ។ នាយកដ្ឋានជលផលទទួលខុសត្រូវលើកកំពស់ការរៀបចំសហគមន៍នេសាទនៅក្នុងតំបន់លិចទឹក។ នាយកដ្ឋាននេះគឺជាស្ថាប័នបង្គោលនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិប្រភេទសត្វ និងរុក្ខជាតិជិតផុតពូជ (CITES)។ យោងតាមសេចក្តីព្រាងច្បាប់ជលផលថ្មី ធនធានជលផលរួមបញ្ចូល សារពាង្គកាយនៅក្នុងដែនទឹកសាប និងសមុទ្រ ដែលមានជាអាទិ៍ វារីរុក្ខជាតិ និងសត្វ ដែលមានជីវិត និងគ្មានជីវិត ដែលអាស្រ័យលើដែននេសាទ រួមមាន សិប្បិសត្វ ផ្កាថ្ម ផលផលិត សត្វល្អិតទឹក ល្អទឹក ថនិកសត្វទឹក និងសត្វស្លាបទឹក។

ដែននេសាទមានជាអាទិ៍ ដែនទឹកសាប និងសមុទ្រ។ ដែននេសាទទឹកសាបរួមមាន ទន្លេ ដៃទន្លេ ស្ទឹង ព្រែក អាងជលសាស្ត្រ ព្រៃលិចទឹក ប្រឡាយ ត្រពាំង អន្លង់ និងបឹង។

នាយកដ្ឋានជលផលមានផ្នែកសំខាន់១: ផែនការ ជលផលទឹកសាប និងជលផលសមុទ្រ។

*រដ្ឋបាលព្រៃឈើ*

រដ្ឋបាលព្រៃឈើទទួលបន្ទុកគ្រប់គ្រង និងអភិវឌ្ឍន៍ ធនធានព្រៃឈើ អនុផលព្រៃឈើ និងសត្វព្រៃដោយនិរន្តរភាព។ ច្បាប់ព្រៃឈើគឺជាបរិធានសំខាន់បំផុត ដែលផ្តល់ជាក្របខ័ណ្ឌសំរាប់ការគ្រប់គ្រង ប្រមូលផល ប្រើប្រាស់ អភិវឌ្ឍន៍ និងអភិរក្សព្រៃឈើក្នុងព្រះរាជាណាចក្រកម្ពុជា។ ព្រៃឈើត្រូវបានចែកជាពីរក្រុម : ដែនបំរុងអចិន្ត្រៃយ៍ និងព្រៃឈើឯកជន។ ព្រៃលិចទឹក និងព្រៃឈើនៅក្នុងតំបន់ការពារធម្មជាតិ ស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ ដោយឡែក។ ច្បាប់ព្រៃឈើថ្មីត្រូវបានអនុម័តនៅឆ្នាំ ២០០៣។ រដ្ឋបាលព្រៃឈើទទួលខុសត្រូវបង្កើតសហគមន៍ព្រៃឈើ នៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់ខ្លួន។ ប៉ុន្តែ ព្រៃលិចទឹក និងព្រៃកោងកាងស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់នាយកដ្ឋានជលផល។ ម្យ៉ាងវិញទៀត ព្រៃតំបន់ឆ្នេរនៅជាប់ពីក្រោយព្រៃកោងកាង គឺ ព្រៃស្មាច់ *Melaleuca leucadendron)* ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ។

*នាយកដ្ឋានក្សេត្រសាស្ត្រ*

នាយកដ្ឋានក្សេត្រសាស្ត្រមានអាណត្តិគ្រប់គ្រង ការពារ និងអភិវឌ្ឍន៍ផលិតកម្មកសិកម្ម និងគុណភាពដីឱ្យមាននិរន្តរភាព។ កិច្ចការចំបងរបស់ខ្លួនគឺដើម្បីកសាងគោលនយោបាយ បទប្បញ្ញត្តិ ផែនការ និងគំរោងសំរាប់ផលិតកម្មកសិកម្មសំរាប់ត្រួតពិនិត្យផលិតកម្មដំណាំ និងបច្ចេកវិទ្យា ព្រមទាំងការធ្វើសារពើភ័ណ្ឌ និងការចាត់ថ្នាក់ប្រភេទដី។

<u>ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់</u>

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ទទួលខុសត្រូវគ្រប់គ្រង និងការលៃលកដីធ្លីសំរាប់ការអភិវឌ្ឍន៍ដោយចីរភាពនៅទូទាំងប្រទេស។ ច្បាប់ភូមិបាល (ឆ្នាំ២០០១) គឺជាឯកសារច្បាប់សំខាន់បំផុតសំរាប់គ្រប់គ្រង និងត្រួតពិនិត្យការបែងចែកដីធ្លីសំរាប់ការប្រើប្រាស់ទាំងអស់។ ការកសាងផែនការប្រើប្រាស់ដីមានពាក់ព័ន្ធមួយចំណែកជាមួយការបែងចែកជាតំបន់ និងការគ្រប់គ្រងតំបន់ដីសើម។ ក្រសួងពាក់ព័ន្ធ ដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានគឺជាស្ថាប័នដែលមាននាទីកសាងផែនការគ្រប់គ្រងជាក់លាក់សំរាប់ដីប្រភេទណាមួយ។

<u>ក្រសួងធនធានទឹក និងឧតុនិយម</u>

ក្រសួងធនធានទឹក និងឧតុនិយមមានភារៈគ្រប់គ្រងធនធានទឹកឱ្យមានប្រសិទ្ធភាព និងមាននិរន្តរភាព។ អាណត្តិនិងវចនាសម្ព័ន្ធរបស់ក្រសួងនេះមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម (ខែមិថុនា ឆ្នាំ ១៩៩៩) និងច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក។ មុខងារចំបងរបស់ក្រសួងនេះគឺ (i) កសាងគោលនយោបាយទឹក (ii) សិក្សា និងស្រាវជ្រាវ (iii) ការស្រាវជ្រាវបច្ចេកទេសអំពីទំនប់ពហុបំណង ប្រព័ន្ធស្រោចស្រព ប្រព័ន្ធដោះទឹក ប្រព័ន្ធផ្គត់ផ្គង់ទឹក និងការងារកែលំអទន្លេ និង (iv) កសាងផែនការ រៀបគំរូ និងស្ថាគំរោងដែលមានស្រាប់ និងការដាក់ឱ្យដំណើរការ និងការថែទាំ ។ ផ្នែកដែលពាក់ព័ន្ធសំខាន់ជាងគេគឺ បរិមាណ និងគុណភាពទឹក ការប្រើប្រាស់ទឹកតាមវិស័យ និងការផលិតថាមពលវារីអគ្គិសនី ប៉ុន្តែស្ថាប័ននេះពុំមានសមត្ថកិច្ចចំពោះធនធានដែលមាននៅក្នុងទឹកឡើយ ដូចជា ជលផល និងសត្វក្នុងទឹក។ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកគឺជាបរិធានចំបងបំផុត ដែលផ្តល់សមត្ថកិច្ចដល់ក្រសួងធនធានទឹក ក្នុងការអនុវត្តអាណត្តិរបស់ខ្លួន ទោះបីច្បាប់នេះនៅពុំទាន់បានអនុម័តនៅឡើយក្តី ។ ក្រសួងនេះមានផ្នែកសំខាន់បីគឺ: អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាល និងអគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស។ អគ្គនាយកដ្ឋានកិច្ចការបច្ចេកទេសមាននាយកដ្ឋានមួយចំនួននៅក្រោមចំណុះ ដែលមានអាណត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ដីសើម រួមទាំង នាយកដ្ឋានគ្រប់គ្រងនិងអភិរក្សធនធានទឹក និងនាយកដ្ឋានធារាសាស្ត្រ និងដោះស្រាយទឹក។

<u>ក្រសួងអភិវឌ្ឍន៍ជនបទ</u>

ក្រសួងអភិវឌ្ឍន៍ជនបទមានអាណត្តិក្នុងការជំរុញការអភិវឌ្ឍន៍ជនបទនៅក្នុងប្រទេសកម្ពុជា ដូចមានចែងនៅក្នុងអនុក្រឹត្យស្តីពីការបង្កើត និងការប្រព្រឹត្តទៅនៃក្រសួងអភិវឌ្ឍន៍ជនបទ។ កិច្ចការពាក់ព័ន្ធសំខាន់បំផុតរបស់ក្រសួងអភិវឌ្ឍន៍ជនបទគឺ ការផ្គត់ផ្គង់ទឹកនៅជនបទ ការថែទាំសុខភាពនៅជនបទ ការអភិវឌ្ឍន៍ជនបទ និងសេដ្ឋកិច្ចជនបទ។ នាយកដ្ឋានមួយរបស់ក្រសួងនេះគឺ នាយកដ្ឋានអភិវឌ្ឍន៍ជនបទ មានទំនាក់ទំនងដោយប្រយោលនឹងការគ្រប់គ្រងតំបន់ដីសើម តាមរយៈការងាររបស់ខ្លួនជាមួយសហគមន៍នៅក្នុងតំបន់ដីសើម។ ក្រសួងអភិវឌ្ឍន៍ជនបទអនុវត្តអាណត្តិរបស់ខ្លួនតាមរយៈការបង្កើត

ក្រុមប្រឹក្សាអភិវឌ្ឍន៍ជនបទ មានជាអាទិ៍ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ឃុំ និងភូមិ។ ក្រសួងអភិវឌ្ឍន៍ជនបទពុំមានច្បាប់ជាក់លាក់ណាមួយពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់ដីសើមឡើយ។

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

ក្រសួងសាធារណការនិងដឹកជញ្ជូនត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រង និងកសាងផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ការអភិវឌ្ឍន៍នាវាចរ និងកំពង់ផែ គឺជាបញ្ហាចំបងទាក់ទងនឹងតំបន់ដីសើម ។

**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

ក្រសួងនេះទទួលខុសត្រូវអភិវឌ្ឍន៍ឧស្សាហកម្ម រ៉ែ និងថាមពល។ កង្វល់ចំបងគឺការអភិវឌ្ឍន៍ថាមពល ដែលមានឥទ្ធិពលលើអេកូឡូស៊ីតំបន់ដីសើម ជាពិសេសតាមរយៈការកសាងសង់ទំនប់។ នៅចំណុះអគ្គនាយកដ្ឋានថាមពល មាននាយកដ្ឋានវារីអគ្គិសនី ដែលមានអំណាចក្នុងការធ្វើសេចក្តីសំរេចអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី។

**ក្រសួងទេសចរណ៍**

ក្រសួងទេសចរណ៍មានសមត្ថកិច្ចជំរុញទេសចរណ៍វប្បធម៌ និងធម្មជាតិ នៅទូទាំងប្រទេស ដោយសហការជាមួយផ្នែកឯកជន។ មានកិច្ចប្រឹងប្រែងជាច្រើនដែលបានធ្វើឡើងដើម្បីជំរុញទេសចរណ៍ធម្មជាតិនៅក្នុងតំបន់ដីសើម ជាពិសេសនៅក្នុង និងនៅជុំវិញបឹងទន្លេសាប ស្ទឹងត្រែង និងកោះនានានៅក្នុងតំបន់ឆ្នេរសមុទ្រ។

**គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា**

កិច្ចការចំបងរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាគឺបង្កើតឱ្យមានការប្រាស្រ័យទាក់ទងគ្នារវាងក្រសួងពាក់ព័ន្ធ និងដើម្បីសំរបសំរួលនៅថ្នាក់ជាតិ សំរាប់អនុវត្តកិច្ចព្រមព្រៀងទន្លេមេគង្គដែលបានចុះហត្ថលេខានៅឆ្នាំ១៩៩៥ ជាពិសេសដោយសារគណៈកម្មាធិការនេះមានអាណត្តិទាក់ទងនឹងការរៀបចំផែនការអភិវឌ្ឍន៍សំរាប់អាងទន្លេមេគង្គ និងចេញគោលនយោបាយគ្រប់គ្រងការប្រើប្រាស់ទឹក។ អនុក្រិត្យថ្មីស្តីពីការបង្កើតលេខាធិការដ្ឋានបរិយាជីវមណ្ឌលបឹងទន្លេសាបបាននាំឱ្យមានការពង្រីកតួនាទីសំរបសំរួលរបស់គណៈកម្មាធិការជាតិទន្លេមេគង្គ ដោយរួមបញ្ចូលការអភិរក្ស និងគ្រប់គ្រងបឹងទន្លេសាបដោយនិរន្តរភាព។ គណៈកម្មាធិការទន្លេមេគង្គមានផ្នែកបីជាសំខាន់ ដែលមានតួនាទីពាក់ព័ន្ធនឹងបញ្ហាតំបន់ដីសើមពោលគឺ ផ្នែកប្រើប្រាស់ទឹក ផ្នែកកម្មវិធីបរិស្ថាន និង ផ្នែកផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ។

**រដ្ឋបាលខេត្ត**

រដ្ឋបាលខេត្តត្រូវបានចែកជាស្រុក ហើយស្រុកនានាត្រូវបានបែកចែកបន្តជាឃុំ ។ ឃុំទទួលខុសត្រូវរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ដោះស្រាយទំនាស់ក្នុងការគ្រប់គ្រងធនធាន និងគាំទ្រការអភិវឌ្ឍន៍នៅក្នុងខេត្ត និងស្រុក។ នៅថ្នាក់ឃុំក្រុមប្រឹក្សាឃុំត្រូវបានបង្កើត ដោយមានគោលដៅលើកទឹកចិត្តឱ្យមានការចូលរួមនៅថ្នាក់មូលដ្ឋាននៅក្នុងការកសាងផែនការ និងអភិវឌ្ឍន៍ធនធាន។

### ៤.១.២ បញ្ហាស្ថាប័នទាក់ទងនឹងការគ្រប់គ្រងតំបន់ដីសើម

**ការសំរបសំរួល**

ដោយសារតំបន់ដីសើមស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងជាច្រើន និងអ្នកប្រើប្រាស់ធនធានជាច្រើន ការសំរបសំរួលគឺជាកត្តាសំខាន់ណាស់ ដើម្បីធ្វើឱ្យមានការគ្រប់គ្រង និងការអភិរក្សឱ្យស៊ីសង្វាក់គ្នានៅគ្រប់លំដាប់ថ្នាក់។ បច្ចុប្បន្ន ពុំទាន់មានយន្តការសំរបសំរួលជាក់លាក់ ដើម្បីដោះស្រាយបញ្ហាកសាងផែនការ និងគ្រប់គ្រងតំបន់ដីសើមឡើយ។

តាមធម្មតា បទប្បញ្ញត្តិ និងច្បាប់នានាត្រូវបានរៀបចំឡើងដោយនាយកដ្ឋានពាក់ព័ន្ធ និងអនុម័តតាមរយៈការសំរបសំរួលជាមួយអន្តរក្រសួង ។ បទប្បញ្ញត្តិ និងច្បាប់អាចទាក់ទងខ្លះៗនឹងបញ្ហាតំបន់ដីសើម ទៅតាមវិស័យនានា។ ដោយសារតំបន់ដីសើមមានមុខនាទីជាប្រព័ន្ធអេកូឡូស៊ី ការកសាងផែនការតាមវិស័យនឹងពុំអាចធានាឱ្យមានវិធានការនយោបាយស៊ីសង្វាក់គ្នាឡើយ និងពុំអាចដោះស្រាយបញ្ហាអន្តរវិស័យឡើយ ទាក់ទងនឹងការចូលរួមជាសាធារណៈ ការអភិវឌ្ឍន៍ធនធានមនុស្ស សេដ្ឋកិច្ចសង្គម និងការស្រាវជ្រាវជីវៈចំរុះ។ ឧទាហរណ៍មួយស្តីពីផលប៉ះពាល់នៃការខកខានបែបនេះមាន ដូចជាការកាប់ឈើដែលរាលដាលជាទូទៅនៅជុំវិញតំបន់រាមសារខេត្តស្ទឹងត្រែង ការទុកឱ្យសកម្មភាពបែបនេះបន្តដោយគ្មានការបង្ក្រាប ហើយសកម្មភាពបែបនេះនឹងនាំឱ្យបាត់បង់ជីវៈចំរុះ បាត់បង់ទីជំរកអេកូតូន នៅតាមដងទន្លេមេគង្គ និងដៃទន្លេនេះ និងការប្រែប្រួលរបបជលសាស្ត្រ។ កិច្ចប្រឹងប្រែងខ្លះៗ មានដូចជា ការសំរបសំរួលទូទៅ (សូមអានប្រអប់ទី 2)។ ប៉ុន្តែសេចក្តីព្រាងផែនការសកម្មភាពតំបន់ដីសើមជាតិនៅតែពុំទាន់បានទទួលការអនុម័តនៅឡើយទេ។ លើសពីនេះ នៅក្នុងប្រទេសពុំទាន់មានការឯកភាពគ្នាអំពីប្រព័ន្ធចំណាត់ថ្នាក់តំបន់ដីសើមឡើយ ដែលមានប្រយោជន៍សំរាប់ធ្វើសារពើភ័ណ្ឌតំបន់ដីសើម ដែលអាចផ្តល់ជាមូលដ្ឋានចំណេះដឹងសំរាប់ការប្រើប្រាស់ធនធានតំបន់ដីសើម អនុលោមតាមតំលៃ និងសារៈសំខាន់របស់វា។

**ប្រអប់ទី ២. សេចក្តីព្រាងផែនការសកម្មភាពតំបន់ដីសើមជាតិ (១៩៩៩)**

សេចក្តីព្រាងផែនការសកម្មភាពតំបន់ដីសើមជាតិ (ឆ្នាំ១៩៩៩)ចែកជាប្រាំផ្នែកគឺ ក្របខ័ណ្ឌស្ថាប័ន និងច្បាប់អំពីតំបន់ដីសើម មូលដ្ឋានព័ត៌មានសំរាប់អភិរក្ស និងគ្រប់គ្រងតំបន់ដីសើមកម្ពុជា និងការអភិវឌ្ឍន៍ធនធានមនុស្ស។ ផ្នែកទីមួយលើកឡើងអំពីការសំរបសំរួលស្ថាប័ន និងច្បាប់ទាក់ទងនឹងតំបន់ដីសើម រួមទាំងកិច្ចព្រមព្រៀងអន្តរជាតិដូចជាអនុសញ្ញាស្តីពីជីវៈចំរុះនិងសន្ធិសញ្ញាពាក់ព័ន្ធផ្សេងៗទៀត។ ផ្នែកចុង ក្រោយបំផុតផ្តោតលើការបង្កើនការយល់ដឹង កសាងសមត្ថភាពមនុស្ស និងការចូលរួមជាសាធារណៈ។ សេចក្តីព្រាងផែនការសកម្មភាពតំបន់ដីសើមជាតិគឺជាគោលនយោបាយទូលំទូលាយដែលដោះស្រាយបញ្ហាភាគច្រើនដែលបានកើតឡើង។

ទោះបីសេចក្តីព្រាងផែនការសកម្មភាពតំបន់ដីសើមជាតិនៅពុំទាន់បានទទួលការអនុម័តនៅឡើយក្តី ប៉ុន្តែទំរង់មួយចំនួននៃការសំរបសំរួលត្រូវបានបង្កើតឡើងសំរាប់តំបន់មួយចំនួន ដូចជា បំបនីយជីវមណ្ឌលបឹងទន្លេសាប តាមរយៈការបង្កើតយន្តការអន្តរក្រសួងនៅថ្នាក់ជាតិ (សូមអានប្រអប់ទី ៣)។ ការសំរបសំរួលស្ទើរតែពុំមានឡើយនៅថ្នាក់ខេត្តនិងមូលដ្ឋាន ទោះបីមានអង្គការមិនមែនរដ្ឋាភិបាលខ្លះ ដូចជាអង្គការស្បៀង និងកសិកម្មសហប្រជាជាតិ (FAO) ដែលបានធ្វើការជំរុញឱ្យមានការសំរបសំរួលអន្តរវិស័យនៅក្នុងបណ្តាខេត្តដែលអង្គការទាំងនោះធ្វើការ។ ជាភស្តុតាងការសំរបសំរួលជាប្រការ

ចាំបាច់សំរាប់ការកសាងផែនការ ការអភិវឌ្ឍន៍ច្បាប់ និងបទប្បញ្ញត្តិ ការពង្រឹងកិច្ចការអនុវត្តច្បាប់ ការអភិវឌ្ឍន៍ធនធានមនុស្ស សារពើភ័ណ្ឌ និងស្រាវជ្រាវតំបន់ដីសើម និងដំណោះស្រាយទំនាស់ ។

**ប្រអប់ទី ៣ យន្តការសំរបសំរួលសំរាប់ជាបទីយជីវមណ្ឌលបឹងទន្លេសាប**

អនុក្រឹត្យមួយស្តីពីការបង្កើត តួនាទី និងមុខងាររបស់លេខាធិការដ្ឋានសំរាប់ជាបទីយជីវមណ្ឌលបឹងទន្លេសាប ត្រូវបានអនុម័តនៅក្នុងឆ្នាំ ២០០១ ។ លេខាធិការដ្ឋាននេះគ្រប់គ្រងដោយគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងលេខាធិការរងបីរូបពីក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក។ លេខាធិការដ្ឋានជាបទីយជីវមណ្ឌលបឹងទន្លេសាបមានផ្នែកបីចំបងគឺ ផ្នែកយុទ្ធសាស្ត្រនិងគោលនយោបាយ ផ្នែកស្រាវជ្រាវ តាមដាននិងគ្រប់គ្រងទិន្នន័យ និងផ្នែករដ្ឋបាល។ តួនាទីចំបងរបស់លេខាធិការដ្ឋាននេះគឺ ជំរុញឱ្យមានការសំរបសំរួល និងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមអង្គភាពនៅថ្នាក់ជាតិ និងអន្តរជាតិ អាជ្ញាធរខេត្ត និងសង្គមស៊ីវិល ដើម្បីការពារនិងគ្រប់គ្រងជាបទីយជីវមណ្ឌលបឹងទន្លេសាបឱ្យមាននិរន្តរភាព។ លេខាធិការដ្ឋាននេះមាននាទីជា មណ្ឌលផ្សព្វផ្សាយព័ត៌មាន និងសំរួលឱ្យមានការផ្លាស់ប្តូរព័ត៌មានក្នុងចំណោមអ្នកពាក់ព័ន្ធនានា និងស្ថាប័ននានា។ លេខាធិការដ្ឋាននេះនឹងសំរួលឱ្យមានការកសាងយុទ្ធសាស្ត្រចំរុះសំរាប់ការអភិវឌ្ឍន៍ដោយចីរភាព និងការអភិរក្សធនធានធម្មជាតិក្នុងបឹងទន្លេសាប។ គេមានសង្ឃឹមថា គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាបដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ីនឹងជួយពង្រឹងលេខាធិការដ្ឋាននេះក្នុងការអនុវត្តអាណត្តិរបស់ខ្លួន ។

តំបន់ដីសើមក៏អាចទទួលផលប៉ះពាល់ពីសកម្មភាពនៅផ្នែកម្ខាងនៃព្រំប្រទល់ប្រទេសផងដែរ។ តំបន់ដីសើមក្នុងខេត្តស្ទឹងត្រែងដែលមានព្រំប្រទល់ជាប់ជាមួយប្រទេសឡាវ និងខេត្តតាកែវដែលមានព្រំប្រទល់ជាប់ជាមួយប្រទេសវៀតណាមបង្ហាញឱ្យឃើញពីករណីនៃទំនាស់ឆ្លងដែន ដែលកើតឡើងដោយសារការកសាងទំនប់វារីអគ្គិសនី និងប្រព័ន្ធស្រោចស្រព។ ប្រការនេះបង្ហាញថា ការសំរបសំរួលថ្នាក់តំបន់មានសារៈសំខាន់ណាស់ក្នុងការធានានិរន្តរភាពតំបន់ដីសើមនៅទូទាំងតំបន់នេះ។ ក្នុងន័យនេះ គណៈកម្មការទន្លេមេគង្គដែលជាអ្នកសំរបសំរួលកំរិតតំបន់មានតួនាទីសំខាន់ណាស់ក្នុងការសំរបសំរួលរវាងប្រទេសនានាដើម្បីឱ្យមានការគ្រប់គ្រងតំបន់ដីសើម។

## ការធ្វើវិមជ្ឈការ

គ្រប់ក្រសួងទាំងអស់របស់រដ្ឋាភិបាលមាននាយកដ្ឋាន និងការិយាល័យបច្ចេកទេស ដែលបានបង្កើតឡើងនៅគ្រប់លំដាប់ថ្នាក់ ចាប់ពីថ្នាក់ជាតិ រហូតដល់ថ្នាក់ខេត្ត ស្រុក និងឃុំ ។ ប្រព័ន្ធខ្សែបណ្តោយបែបនេះអាចសំរួលឱ្យមានការផ្ទេរអំណាចរដ្ឋបាលពីថ្នាក់ជាតិ មកថ្នាក់មូលដ្ឋាន។ ការធ្វើប្រតិភូកម្មអំណាចអាចធ្វើទៅបានប្រកបដោយប្រសិទ្ធភាពអាស្រ័យលើកត្តាជាច្រើន ដូចជា តួនាទី និងការទទួលខុសត្រូវរបស់ការិយាល័យនៅថ្នាក់មូលដ្ឋានក្នុងការកសាងផែនការ អនុវត្តកម្មវិធី ពង្រឹងការអនុវត្តច្បាប់ និងការធ្វើសេចក្តីសំរេច។ មានការយល់ឃើញរួមគ្នាអំពីកង្វះប្រសិទ្ធភាព និងការចែកអំណាចតិចតួចពីក្រសួងនៅថ្នាក់ជាតិ មកការិយាល័យនៅថ្នាក់មូលដ្ឋាន ដើម្បីធ្វើការគ្រប់គ្រងធនធាន និងជាពិសេសតំបន់ដីសើម។ ការងារខ្លះដូចជាការកសាងផែនការ និងការអនុវត្តកម្មវិធីអាចធ្វើឡើងប្រកបដោយប្រសិទ្ធភាពខ្ពស់ជាងនៅពេលដែលអនុវត្តដោយ

អង្គភាពនៅថ្នាក់មូលដ្ឋាន ប្រៀបធៀបនឹងការអនុវត្តដោយអង្គភាពនៅថ្នាក់ជាតិ។ វិធានការតាមបែបបញ្ជាពីលើចុះក្រោម អាចមានប្រសិទ្ធភាពខ្ពស់ជាងតែក្នុងករណីនៃការអនុវត្តគោលនយោបាយជាតិតែប៉ុណ្ណោះ ប៉ុន្តែវាអាចមានការយឺតយ៉ាវក្នុងការអនុវត្ត និងពុំផ្តល់ភាពងាយស្រួលក្នុងការបត់បែនដែលជាតំរូវការចាំបាច់ដើម្បីឆ្លើយតបចំពោះបញ្ហាដែលកើតមានឡើងនៅថ្នាក់មូលដ្ឋាននោះឡើយ។ ឧទាហរណ៍: ការបង្កើតសហគមន៍ព្រៃឈើបានធ្វើឡើងដោយយឺតយ៉ាវ ដោយសារការធ្វើសេចក្តីសំរេចចុងក្រោយស្ថិតនៅថ្នាក់ជាតិ។ ក្នុងករណីជាច្រើនគេឃើញថា មន្ទីរនៅថ្នាក់ខេត្តពិបាកធ្វើការត្រួតពិនិត្យនិងពង្រឹងការអនុវត្តច្បាប់នៅក្នុងតំបន់ការពារធម្មជាតិ និងក្នុងតំបន់ព្រៃសម្បទាន និងឡូត៍នេសាទ ដោយសារ មានធនធានត្រឹមតិចតួច និងការកំនត់តួនាទីសមត្ថកិច្ច និងការទទួលខុសត្រូវពុំបានច្បាស់លាស់។ លើសពីនេះ មន្ទីរនានាពុំបានទទួលអំណាចគ្រប់គ្រាន់ក្នុងការកសាងផែនការពង្រឹងការអនុវត្តច្បាប់ ការធ្វើសេចក្តីសំរេច និងត្រួតពិនិត្យលើការប្រើប្រាស់ធនធានឡើយ។ ការផ្ទេរអំណាចមួយចំនួនបានធ្វើឡើងយ៉ាងពិតប្រាកដតាមរយៈការបង្កើតក្រុមប្រឹក្សាឃុំ។ កម្មវិធីកែលំអសេដ្ឋកិច្ចសង្គម(ស៊ីលា) គឺជាគំរូមួយនៃការធ្វើវិមជ្ឈការប្រកបដោយជោគជ័យ។ តាមរយៈការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) កម្មវិធីនេះបានផ្តល់ការគាំទ្រដល់ប្រជាពលរដ្ឋមូលដ្ឋានក្នុងការកសាងផែនការ និងអនុវត្តកម្មវិធីបណ្តុះបណ្តាល និងគំរោងខ្នាតតូច ។

## ការពង្រឹងការអនុវត្តច្បាប់

ធនធានតំបន់ដីសើមស្ថិតនៅក្រោមសមត្ថកិច្ចនៃក្រសួងជាច្រើនដែលមានច្បាប់ និងបទប្បញ្ញត្តិរៀង ៗខ្លួន។ ជាទូទៅការអនុវត្តច្បាប់ទាក់ទងនឹងការគ្រប់គ្រងតំបន់ដីសើម ត្រូវបានសង្កេតឃើញថានៅពុំទាន់គ្រប់គ្រាន់ និងពុំមានប្រសិទ្ធភាពនៅឡើយទេ។ ប្រការនេះកើតឡើងដោយសារសមត្ថភាព និងធនធាននៅមានកំរិតកំណត់ ប្រាក់ចំណូលទាបក្នុងចំណោមមន្ត្រីពង្រឹងការអនុវត្តច្បាប់ ភាពពុំច្បាស់លាស់ក្នុងការផ្ទេរអំណាចពីថ្នាក់លើមកថ្នាក់ក្រោម កង្វះបទប្បញ្ញត្តិ សំរាប់គ្រប់គ្រងធនធានខ្លះៗ អាណត្តិត្រួតគ្នា និងភាពទន់ខ្សោយនៃការសំរបសំរួលរវាងស្ថាប័ននានា។

ការពង្រឹងកិច្ចការអនុវត្តច្បាប់នៅក្នុងតំបន់វាលភ្នាមសារខេត្តស្ទឹងត្រែង និងក្នុងតំបន់ស្នូលនៃបរិមណ្ឌលជីវមណ្ឌលបឹងទន្លេសាបស្ថិតនៅក្រោមសមត្ថកិច្ចត្រួតគ្នារវាងនាយកដ្ឋានចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងនាយកដ្ឋានចំណុះក្រសួងបរិស្ថាន។ ការដឹកជញ្ជូនផលិតផលព្រៃឈើ និងសត្វព្រៃរវាងតំបន់ដីសើម និងដែនដីគោក មិនងាយនឹងត្រួតត្រាបានឡើយ បើពុំមានការសំរបសំរួលរវាងនាយកដ្ឋាននានាដែលមានភារៈទទួលខុសត្រូវ។ ឧទាហរណ៍: ប្រភេទខ្លះនៃសត្វពស់ ស្វា និងអណ្តើកអាចមានរស់នៅទាំងក្នុងព្រៃឈើ និងក្នុងទឹក ដែលតំបន់ទាំងពីរនេះស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់នាយកដ្ឋានខុសគ្នា។ ដោយសារមានករណីជាច្រើនដែលពុំមានភាពច្បាស់លាស់ថាតើនាយកដ្ឋានណា មានសមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ ជាញឹកញាប់គេសង្កេតឃើញមានសមត្ថកិច្ចត្រួតគ្នា ឬអវត្តមាននៃកិច្ចប្រឹងប្រែងពង្រឹងការអនុវត្តច្បាប់។ ដើម្បីពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព ទាមទារកិច្ចសហការពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ និង ការឯកភាពគ្នាអំពីបទបញ្ជាទាក់ទងនឹងការប្រើប្រាស់ធនធាន និងនីតិវិធីពង្រឹងការអនុវត្តច្បាប់ (ពិន័យឃាត់ខ្លួន រឹបអូសវត្ថុតាង ការដោះស្រាយអន្តរការណ៍ និងប្តឹងទៅតុលាការ)។ ក្នុងការអនុវត្តជាក់ស្តែង មានការសង្កេតឃើញថា ផ្នែកឯកជនដែលជាអ្នកប្រើប្រាស់ធនធាន ជាពិសេសអ្នកកាន់កាប់ឡូត៍នេសាទ និងព្រៃសម្បទានច្រើនតែបង្កើតបទបញ្ជារបស់ខ្លួនដើម្បីគ្រប់គ្រងធនធាន

នៅក្នុងតំបន់របស់ខ្លួនកាន់កាប់ ដោយពុំមានពិគ្រោះយោបល់ជាមួយសហគមន៍ឡើយ ដែលជាញឹកញាប់បានបង្កើតឱ្យមានបទរំលោភលើសិទ្ធិសហគមន៍ និងអំពើហិង្សា។

ការចូលរួមជាសាធារណៈ

មានកំណើនឡើងនៃការទទួលស្គាល់ថា ការចូលរួមជាសាធារណៈមានសារៈសំខាន់ណាស់នៅក្នុងការគ្រប់គ្រងធនធានតំបន់ដីសើមដោយនិរន្តរភាព។ ការចូលរួមជាសាធារណៈមានសារៈសំខាន់ដើម្បីធ្វើឱ្យមានជោគជ័យនៃការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល បង្កើនការយល់ដឹង ពង្រឹងការអនុវត្តច្បាប់ ការគ្រប់គ្រងធនធាន និងការកសាងផែនការ និងអនុវត្ត។ ក្នុងប្រទេសកម្ពុជា ការចូលរួមជាសាធារណៈត្រូវបានជំរុញដោយអង្គភាពនៅក្នុងវិស័យនានា តាមរយៈប្រព័ន្ធអប់រំ ការបង្កើតបែបបទគ្រប់គ្រងដោយសហគមន៍ ការប្រជុំជាសាធារណៈ និងយុទ្ធនាការបង្កើនការយល់ដឹង។ ប៉ុន្តែ មានការរីកចំរើនតិចតួចតែប៉ុណ្ណោះ ដោយសារពុំមានបទប្បញ្ញត្តិច្បាស់លាស់ស្តីពីការចូលរួមដោយសហគមន៍ និងសិទ្ធិរបស់ប្រជាពលរដ្ឋមូលដ្ឋានក្នុងការសំដែងកង្វល់របស់ពួកគេ។ លើសពីនេះ ស្ថាប័នទទួលខុសត្រូវរារែកក្នុងការផ្ទេរអំណាចទទួលខុសត្រូវគ្រប់គ្រងធនធានទៅឱ្យសហគមន៍ ដោយសារកង្វះខាតនៃជំនាញក្នុងការចាត់ចែង និងសមត្ថភាពទាបរបស់សហគមន៍ក្នុងការត្រួតត្រា និងពង្រឹងបទបញ្ជាប្រើប្រាស់ធនធាន។ ប្រសិនបើមានការអនុម័តផែនការសកម្មភាពតំបន់ដីសើមជាតិ អាចនាំឱ្យមានការអនុវត្តក្របខ័ណ្ឌរបស់រូលមួយសំរាប់ការចូលរួមជាសាធារណៈ។

ទំនាស់

ដោយសារមានក្រុមជាច្រើនចាប់អារម្មណ៍ចំពោះតំបន់ដីសើម គេរំពឹងថានឹងមានទំនាស់ជាច្រើនរវាងអ្នកប្រើប្រាស់ធនធាន។ ទំនាស់នានាអាចចែកជាបីក្រុមគឺ: ទំនាស់ក្នុងចំណោមអ្នកប្រើប្រាស់ធនធាន រវាងស្ថាប័នគ្រប់គ្រង និងរវាងប្រទេសនានា (ទំនាស់ឆ្លងដែន)។

ទំនាស់ក្នុងចំណោមអ្នកប្រើប្រាស់ធនធានកើតឡើងដោយសារកង្វះលទ្ធភាពក្នុងការធ្វើសុខដុមនីយកម្មរបៀបនៃការប្រើប្រាស់ធនធាន ការបែងចែកផលក្នុងចំណោមអ្នកប្រើប្រាស់ធនធានមួយឬច្រើន ។ នៅក្នុងតំបន់ដីសើម ទំនាស់ក្នុងការនេសាទកើតមានឡើងជាទូទៅរវាងអ្នកនេសាទខ្នាតតូច និងអ្នកនេសាទទ្រង់ទ្រាយធំ ដោយសារពុំមានការរៀបចំបែងចែកធនធានជលផលប្រកបដោយសមធម៌ (សូមអានប្រអប់ទី ៤)។ នៅឆ្នាំ២០០០ ដើម្បីបន្ធូរបន្ថយបញ្ហាទាំងនេះ រដ្ឋាភិបាលបានលុបចោលឡូតិ៍នេសាទច្រើនជាង ៥៦% និងបំលែងដែននេសាទទាំងនោះទៅជាធនធានសំរាប់ការប្រើប្រាស់រួមនៅក្រោមរបបគ្រប់គ្រងផ្អែកលើសហគមន៍។

ភាពពុំច្បាស់លាស់នៃការប្រើប្រាស់ធនធានក៏អាចបង្កឱ្យមានទំនាស់ផងដែរ ។ ជាក់ស្តែង ការពង្រីកដីកសិកម្មនាំឱ្យបាត់បង់ព្រៃលិចទឹក និងធ្វើឱ្យប្រែប្រួលអេកូឡូស៊ីតំបន់ដីសើម ហេតុនេះនាំឱ្យមានឥទ្ធិពលអវិជ្ជមានចំពោះអ្នកប្រើប្រាស់ធនធានជលផលផ្សេងទៀត ដូចជា អ្នកនេសាទ អ្នកបរបាញ់ និងអ្នករកអុស។

ប្រអប់ទី ៤ ករណីសិក្សាមួយអំពីទំនាស់ប្រើប្រាស់ធនធានតំបន់ដីសើមនៅកំពង់ក្រសាំង ស្រុកបុរីជលសា ខេត្តតាកែវ

គំរោងមួយដែលជាផ្នែកមួយនៃកម្មវិធីគាំទ្រដោយសហភាពអឺរ៉ុបសំរាប់វិស័យកសិកម្មក្នុងប្រទេសកម្ពុជា (ប្រាសាក់) បានអនុវត្តនៅក្នុងឆ្នាំ ១៩៩៥ ដោយមានគោលដៅជំរុញការស្តារវិស័យកសិកម្មនៅក្នុងស្រុកចំនួនបួនក្នុងខេត្តតាកែវ។ គំរោងនោះបានគាំទ្រការជីកប្រឡាយដ៏ធំមួយខ្សែដែលមានបណ្តោយប្រវែង ១៦៧គ.ម សំរាប់យកទឹកស្រោចស្រពស្រូវប្រាំង។ ប្រឡាយលេខ ៩០ ត្រូវបានជីករួចនៅក្នុងឆ្នាំ ១៩៩៦ និងស្ថិតនៅក្នុងឡូតិ៍នេសាទលេខ ១១។ ក្រោយពេលជីកប្រឡាយរួចរាល់ ប្រាសាក់បានបង្កើតសហគមន៍អ្នកប្រើប្រាស់ទឹក ដែលហៅថា "ត្រិក" ដើម្បីសំរបសំរួលការប្រើប្រាស់ និងគ្រប់គ្រងទឹក។ ក្រោយបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) ទំនាស់មួយបានកើតឡើងរវាងអ្នកកាន់កាប់ឡូតិ៍នេសាទ និង FWUC។ មូលហេតុនៃទំនាស់ស្ថិតនៅត្រង់ថា ត្រីក្នុងឡូតិ៍នេសាទបានប្រមូលផ្តុំនៅក្នុងប្រឡាយ ដែលគ្រប់គ្រងដោយ FWUC។ បញ្ហានៃទំនាស់នេះត្រូវបានបញ្ជូនទៅអភិបាលខេត្តដើម្បីដោះស្រាយ។ ក្រោមការគាំទ្ររួមគ្នាពីសំណាក់ FWUC ទំនាស់នោះត្រូវបានដោះស្រាយ ដោយអភិបាលខេត្តបានសំរេចថាធនធានជលផលនៅក្នុងប្រឡាយនោះត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់FWUC។ក្រោយកំណែទំរង់ឡូតិ៍នេសាទក្នុងឆ្នាំ២០០០ ឡូតិ៍នេសាទលេខ១១ ត្រូវបានលុបចោល និងដាក់ឱ្យសហគមន៍មូលដ្ឋានប្រើប្រាស់តាមរយៈការបង្កើតសហគមន៍នេសាទ។ ប៉ុន្តែទំនាស់មួយផ្សេងបានកើតឡើងនៅពេលមានការប្រជែងគ្នារវាងកសិករ និង FWUC ក្នុងការប្រើប្រាស់ទឹកនៅក្នុងប្រឡាយលេខ ៩០។ ទំនាស់នោះក៏ត្រូវបានដោះស្រាយដោយគណៈកម្មការចំរុះថ្នាក់ខេត្ត ដែលសំរេចឱ្យកសិករទាំងអស់មានសិទ្ធិដូចគ្នាក្នុងការនេសាទត្រីនៅក្នុងប្រឡាយដោះទឹក ដោយប្រើប្រាស់វិធីនេសាទទ្រង់ទ្រាយតូច។

នៅថ្នាក់ជាតិ អាចមានត្រួតមុខងារគ្នាក្នុងចំណោមក្រសួងមួយចំនួន ជាពិសេសរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងទេសចរណ៍។ ក្នុងប្រការនោះ ទាមទារឱ្យមានការសំរបសំរួលរវាងបណ្តាក្រសួងនានា ដើម្បីដាក់ចេញគោលនយោបាយស៊ីសង្វាក់គ្នា និងយុទ្ធសាស្ត្ររួមស្តីពីតំបន់ដីសើម។

តំបន់ដីសើមក្នុងប្រទេសកម្ពុជាក៏អាចរងគ្រោះដោយសារការអភិវឌ្ឍន៍នៅក្នុងប្រទេសជិតខាងផងដែរ។ គំរោងអភិវឌ្ឍន៍សំរាប់ការផលិតវារីអគ្គិសនី ប្រព័ន្ធស្រោចស្រព និងទំនប់ការពារទឹកជំនន់បានបង្កផលប៉ះពាល់អវិជ្ជមានចំពោះតំបន់ដីសើមដែលស្ថិតនៅឆ្ងាយពីព្រំប្រទល់នៃប្រទេស។ ឧទាហរណ៍: តំបន់ដីសើមក្នុងខេត្តស្ទឹងត្រែង និងក្នុងខេត្តតាកែវអាចងាយប្រែប្រួលបណ្តាលពីការអភិវឌ្ឍន៍នៅក្នុងប្រទេសឡាវ និងប្រទេសវៀតណាម។ ទោះបីនៅមានកិច្ចការជាច្រើនត្រូវអនុវត្តមុនពេលអាចបង្កើតយន្តការសំរាប់ដោះស្រាយទំនាស់ឱ្យមានប្រសិទ្ធភាពក្តី ស្ថាប័នថ្នាក់តំបន់ ដូចជាគណៈកម្មការទន្លេមេគង្គ អាចដើរតួនាទីស្នូលក្នុងការកាត់បន្ថយទំនាស់បែបនេះ។

## ៤.២ ក្របខ័ណ្ឌច្បាប់

ច្បាប់លេខ ១២៩៦ន.ស-រកម/២៤ធ្នូ ៩៦ ដែលបានអនុម័តនៅថ្ងៃទី ២៤ខែ ធ្នូ ឆ្នាំ ១៩៩៦ បានចែងពីការចូលជាសមាជិករបស់ប្រទេសកម្ពុជាទៅក្នុងអនុសញ្ញាស្តីពីតំបន់ដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិ ជាពិសេសជាជំរកសត្វស្លាបទឹក (អនុសញ្ញារ៉ាមសារ)។ ទោះបីច្បាប់នេះចែងពីកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្នុងការអនុវត្តអនុសញ្ញារ៉ាមសារក្តី ច្បាប់នេះពុំបានចែងពីបទប្បញ្ញត្តិជាក់លាក់សំរាប់គ្រប់គ្រងការប្រើប្រាស់ និងការពារធនធានតំបន់ដីសើមឡើយ។ តាមរយៈអនុសញ្ញារ៉ាមសារ តំបន់ដីសើមចំនួនបីកន្លែងគឺ កោះកាពិ បឹងទន្លេឆ្មា និងស្ទឹងត្រែង ត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីតំបន់ដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិ។ ទោះបីមានកិច្ចផ្តួចផ្តើមមួយចំនួនបានធ្វើឡើងដើម្បីកសាងសេចក្តីព្រាងផែនការសកម្មភាពតំបន់ដីសើមជាតិក្តី ផែនការនោះនៅពុំទាន់បានទទួលការអនុម័តដោយគណៈរដ្ឋមន្ត្រីនៅឡើយទេ។ លើសពីនេះប្រទេសនេះនៅពុំទាន់មានប្រព័ន្ធដែលឯកភាពគ្នាសំរាប់ចាត់ថ្នាក់តំបន់ដីសើមនៅឡើយទេ ដែលជាប្រការសំខាន់សំរាប់រៀបចំផែនការគ្រប់គ្រង និងអភិរក្ស។ ដូចដែលមានបកស្រាយពីខាងដើម ច្បាប់ និងបទប្បញ្ញត្តិចំបង១១ទាក់ទងនឹងតំបន់ដីសើមមានក្រោមរូបភាពជាច្បាប់នៅតាមវិស័យនានាតែប៉ុណ្ណោះ។

### *៤.២.១ ជលផល*

ច្បាប់ជលផលដែលបានប្រកាសឱ្យប្រើនៅក្នុងឆ្នាំ១៩៨៧ បានផ្តល់អាណត្តិទូលំទូលាយដល់នាយកដ្ឋានជលផលដើម្បីគ្រប់គ្រងធនធានជលផល។ ទោះបីច្បាប់ជលផលឆ្នាំ ១៩៨៧ ត្រូវបានចាត់ទុកថាចាស់ហួសសម័យហើយក្តីសំរាប់បរិបទបច្ចុប្បន្ននៃសេដ្ឋកិច្ចសង្គមនិងបរិស្ថាន វានៅតែជាច្បាប់ដ៏សំខាន់នៅឡើយ សំរាប់ចាត់ចែងការគ្រប់គ្រងធនធានតំបន់ដីសើម។ នៅក្នុង កិច្ចប្រឹងប្រែងដើម្បីបំពេញបន្ថែមលើចំណុចខ្វះចន្លោះនៅក្នុងច្បាប់ជលផលបច្ចុប្បន្ន ច្បាប់ជលផលថ្មី ដែលត្រូវបានឱ្យឈ្មោះថា "ច្បាប់ស្តីជលផល" កំពុងត្រូវបានរៀបចំដោយនាយកដ្ឋានជលផល ក្រោយការជួយឧបត្ថម្ភពីធនាគារពិភពលោក។

<u>ប្រភេទនៃការធ្វើនេសាទ</u>

មាត្រា១នៃច្បាប់ជលផលចាស់បានឱ្យនិយមន័យធនធានជលផលថា ជាសត្វ និងរុក្ខជាតិមានជីវិតទាំងអស់ ដែលបន្តពូជ និងរស់នៅក្នុងដែននេសាទ។ ដែននេសាទត្រូវបានចែកជា ដែននេសាទទឹកសាប និងដែននេសាទសមុទ្រ។ ដែននេសាទទឹកសាប រួមមាន ទន្លេ ដៃទន្លេ បឹង ស្ទឹង ប្រឡាយ ព្រៃលិចទឹក និងដែនទឹកនានាដែលតភ្ជាប់ទៅដែនទឹកខាងលើ។ យោងតាមនិយមន័យនេះ នៅក្នុងរដូវវស្សា បឹងទន្លេសាបទាំងមូល នៅពេលមានជំរៅទឹក ១០ ម (ខ្ពស់ជាងនីវ៉ូទឹកសមុទ្រ) ត្រូវបានចាត់ទុកថាជាដែននេសាទ ដោយរាប់បញ្ចូលទាំងតំបន់វាលស្មៅ និងវាលស្រែដែលលិចទឹកផងដែរ។

បទប្បញ្ញត្តិជលផលបច្ចុប្បន្ន បែងចែកការនេសាទជាបីបែបគឺ ការនេសាទឧស្សាហកម្ម ការនេសាទសិប្បកម្ម និងការនេសាទទ្រង់ទ្រាយតូច ដែលត្រូវបានអនុញ្ញាតនៅក្នុងដែននេសាទនានា។ មាត្រា ៣ កំណត់ដែននេសាទជាបីក្រុមគឺ ឡូតិ៍នេសាទ កន្លែងនេសាទបំរុងទុក និងព្រៃលិចទឹក។ លើសពីនេះ មាត្រា ៤ចែងថា ដែននេសាទដែលត្រូវការពារគឺជាដែននេសាទ (បឹងដែលមានទឹកអចិន្ត្រៃយ៍ ឬស្ទឹង) ដែលស្ថិតនៅក្រៅដែនទឹកដែលមានកំណត់ខាងលើ។ ម្យ៉ាងវិញទៀត ការនេសាទអាចអនុញ្ញាតបានតែនៅក្នុងឡូតិ៍នេសាទ និងដែននេសាទសាធារណៈនៅក្រៅឡូតិ៍នេសាទ តែមិនអាចអនុញ្ញាតឱ្យធ្វើនៅក្នុងកន្លែងនេសាទបំរុងទុកឡើយ។ ប៉ុន្តែ ច្បាប់ជលផលមិនបានចែងអំពីការប្រើប្រាស់ដែលជាទំលាប់ប្រពៃណីមានស្រាប់ និងសិទ្ធិរបស់

អ្នកពាក់ព័ន្ធនានា ដែលពឹងផ្អែកលើធនធានតំបន់ដីសើមសំរាប់ការចិញ្ចឹមជីវិតនោះឡើយ។ អាស្រ័យហេតុនេះ ទំនាក់ទំនងរវាងដែននេសាទគ្រប់ប្រភេទទាំងអស់ ជាមួយស្ថានភាពបច្ចុប្បន្ននៃការប្រើប្រាស់ដីពុំមានសភាពច្បាស់លាស់ និងមានភាពច្របូកច្របល់នៅឡើយ។

កន្លែងនេសាទបំរុងទុកត្រូវដាក់នៅក្រោមកិច្ចការពារតឹងរ៉ឹងសំរាប់ជាកន្លែងមច្ឆជាតិបន្តពូជ។ ប៉ុន្តែកន្លែងនេសាទបំរុងទុកត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋានព័ត៌មានវិទ្យាសាស្ត្រដែលមាននៅពេលនោះ និងបានចូលរួមចំណែកក្នុងកំរិតណាមួយចំពោះការអភិរក្សធនធានជលផល ។

លើកលែងតែការនេសាទទ្រង់ទ្រាយតូចជាលក្ខណៈគ្រួសារ ឡូត៍នេសាទ និងការធ្វើនេសាទជាលក្ខណៈសិប្បកម្មទាំងអស់ត្រូវបានកំណត់ទៅតាមបច្ចេកទេស ប្រភេទឧបករណ៍ និងពេលវេលាកំណត់ ដូចមានចែងក្នុងសេចក្តីប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ការគ្រប់គ្រងឡូត៍នេសាទ

ការជួលឡូត៍នេសាទត្រូវធ្វើឡើងតាមរយៈការដេញថ្លៃដោយសហគ្រាសនេសាទ ឬក្រុមសាមគ្គីឯកជន (ឧទាហរណ៍សហករណ៍) ដើម្បីទទួលសិទ្ធិផ្តាច់មុខ។ ឡូត៍នេសាទនៅតែត្រូវបានចាត់ទុកថាមធ្យោបាយចាត់ចែងដ៏មានប្រសិទ្ធភាព និងជាប្រភពដ៏សំខាន់ក្នុងការរកប្រាក់ចំណូលសំរាប់ស្ថាប័នរដ្ឋាភិបាល។ អ្នកជំនាញការជលផលជឿថាវាជាវិធីសាស្ត្រដែលចំណាយតិចបំផុតសំរាប់គ្រប់គ្រងជលផល។ ឡូត៍នេសាទក៏ជាមធ្យោបាយ ដែលជួយដាក់កំហិតដើម្បីបញ្ចៀស ការធ្វើនេសាទច្រើនហួសហេតុ។ ប្រសិនបើមានការកែលំអការគ្រប់គ្រងឱ្យបានប្រសើរជាងនេះ ឡូត៍នេសាទមិនត្រឹមតែផ្តល់ប្រាក់ចំណូលសំរាប់ប្រជារាស្ត្រ និងផ្តល់ប្រាក់ចំណូលបន្ថែមទៀតសំរាប់រដ្ឋាភិបាលនៅថ្នាក់កំរិតម៉ាក្រូប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមវិភាគទានដើម្បីឈានទៅចានិរន្តរភាពធនធានជលផលថែមទៀតផង។ នៅកំរិតមីក្រូ ឡូត៍នេសាទគួរតែបង្កើតការងារបន្ថែមទៀតសំរាប់ប្រជាជននៅតាមជនបទ។ ប៉ុន្តែក្នុងស្ថានភាពបច្ចុប្បន្ន ឡូត៍នេសាទពុំទាន់បានដំណើរការគ្រប់គ្រងឱ្យមានប្រសិទ្ធិភាពខ្ពស់នៅឡើយ ខាងផ្នែករកប្រាក់ចំណូល ឬការរក្សានិរន្តរភាពជលផល។

គុណភាពស្ថិតិជលផលរបស់រដ្ឋាភិបាលនៅមានកំរិតនៅឡើយ ហើយច្រើនតែប៉ាន់ប្រមាណបរិមាណផលនេសាទកំរិតទាប (Van Zalinge et al. 2000)។ ជាលទ្ធផល ការប្រមូលប្រាក់ចំណូលពុំបានអនុវត្តពេញលេញនៅឡើយ។ ឡូត៍ស្រាវជ្រាវត្រូវបានសិក្សា និងធ្វើរបាយការណ៍ទាក់ទងតែអំពីផលនេសាទ។ មុនឆ្នាំ ២០០១ នាយកដ្ឋានជលផល និងអ្នកកាន់កាប់ឡូត៍នេសាទបានកំណត់ព្រំប្រទល់ឡូត៍នេសាទចំនួន ២០០ និងកន្លែងនេសាទបំរុងទុកចំនួន ១៣។ ការកំណត់ និងការដាក់ព្រំប្រទល់ឡូត៍នេសាទពុំទាន់បានកំរិតខ្ពស់តាមលក្ខណៈបច្ចេកទេស និងផ្លូវច្បាប់នៅឡើយ។

ច្បាប់ជលផលចាស់ត្រូវបានកំណត់ដោយមានអំពីការចូលរួមពីចាស់ព្រឹទ្ធាចារ្យ នៅក្នុងការកំណត់ និងដាក់ព្រំប្រទល់ដែននេសាទ។ ប្រការនេះដោយសារក្នុងសេចក្តីប្រកាសរបស់ក្រសួងកសិកម្ម (មាត្រា១ និងសេចក្តីប្រកាសលេខ ០០៤៤ ចុះថ្ងៃទី ២៤/៥/៨៩) ដែលបានទទួលការពិគ្រោះយោបល់នៅមានកំរិតនៅឡើយអំពីតួនាទី និងសិទ្ធិរបស់ស្ថាប័នផ្សេងទៀតរបស់រដ្ឋាភិបាល និងអ្នកនេសាទ។ ជាក់ស្តែង ដោយសារនាយកដ្ឋានជលផលនៅពេលនោះមានសមត្ថភាពមានកំរិត និងខ្វះធនធានហិរញ្ញវត្ថុ ការកំណត់ព្រំប្រទល់ឡូត៍នេសាទ និងកន្លែងនេសាទបំរុងទុកទាំងនេះត្រូវបានអនុវត្ត ដោយផ្អែក

លើផែនទីនៅក្នុងច្បាប់ជលផលឆ្នាំ១៩៥៦ ដោយពុំមានព័ត៌មានវិទ្យាសាស្ត្រថ្មីៗជាក់លាក់ឡើយ។ ជាក់ស្តែងពុំមានការចងក្រងជាឯកសារឱ្យបានច្បាស់លាស់ឡើយអំពីទីតាំងនៃព្រំប្រទល់ ហេតុនេះទីតាំងទាំងនេះងាយត្រូវគេបំភ្លេចចោលៈនៅក្នុងការអនុវត្តជាក់ស្តែងនៅមូលដ្ឋាន។ ដំណើរការនៃការកំណត់ព្រំប្រទល់ច្រើនតែអនុវត្តក្នុងគោលដៅបង្កើនផលប្រយោជន៍សេដ្ឋកិច្ចតែប៉ុណ្ណោះ ដោយពុំមានការពិគ្រោះយោបល់ឱ្យបានទូលំទូលាយជាមួយសហគមន៍មូលដ្ឋាន។ ជាលទ្ធផលពុំបានបំពេញតាមសេចក្តីត្រូវការដែលសង្ឃឹមចង់បានរបស់សហគមន៍មូលដ្ឋាននៅឡើយ។

មាត្រា១៨ នៃអនុក្រឹត្យលេខ២៦ ( អ.ន.ក្រ ចុះខែឧសភា ឆ្នាំ១៩៨៩) ចែងអំពីសិទ្ធិរបស់អ្នកកាន់កាប់ឡូត៍នេសាទក្នុងការឃាត់ខ្លួនជាបណ្តោះអាសន្ននូវអ្នកលួចចូលនេសាទនៅក្នុងឡូត៍នេសាទ។ ដោយសារនាយកដ្ឋានជលផលមានសមត្ថភាពទន់ខ្សោយនិងខ្វះធនធាន ការផ្តល់អំណាចពង្រឹងការអនុវត្តច្បាប់ទៅឱ្យផ្នែកឯកជន យ៉ាងហោចណាស់នៅក្នុងរដូវបើកនេសាទអាចជាមូលហេតុសមស្របនិងគួរឱ្យយល់ស្របផងដែរ។ ប៉ុន្តែ វិធានការពង្រឹងការអនុវត្តច្បាប់ពីសំណាក់អ្នកកាន់កាប់ឡូត៍នេសាទ ដែលជាធម្មតាមានការយល់ដឹងតិចតួចអំពីនីតិវិធីច្បាប់ និងការអនុវត្តច្បាប់ មិនទំនងជាមានប្រសិទ្ធភាពឡើយ ជាហេតុនាំឱ្យមានបទរំលោភ។ ក្នុងកាលៈទេសៈបែបនេះ មន្ត្រីជលផលមានអំណាចតាមផ្លូវច្បាប់ ដើម្បីត្រួតពិនិត្យអ្នកកាន់កាប់ឡូត៍នេសាទអំពីការគោរពច្បាប់។ ជាលទ្ធផល ទាំងអ្នកកាន់កាប់ឡូត៍នេសាទ និងក្រុមអ្នកនេសាទផ្សេងៗទៀត សុទ្ធតែប្រព្រឹត្តល្មើស នឹងបទប្បញ្ញត្តិជលផល។ របៀបធ្វើនេសាទល្មើសច្បាប់មានដូចជាការបូមពង្រីងបឹង ការសង់ទំនប់កាត់ស្ទឹង និងការនេសាទដោយ។

ការលុបចោលនៅពេលថ្មីៗនេះនូវឡូត៍នេសាទមួយចំនួនដើម្បីដាក់ឱ្យគ្រប់គ្រងតាមបែបសហគមន៍ ត្រូវបានចាត់ទុកថាជាជំហានដ៏ល្អមួយឆ្ពោះទៅកែលំអការគ្រប់គ្រងជលផល។ ច្បាប់ជលផលថ្មីគួរតែផ្តល់អំណាចគ្រប់គ្រាន់ដល់សហគមន៍ដើម្បីត្រួតត្រាធនធាន និងចូលរួមក្នុងការធ្វើសេចក្តីសំរេច ព្រមទាំងពង្រឹងការអនុវត្តច្បាប់ផងដែរ។

<u>ការនេសាទដោយចំហ</u>

ការនេសាទដោយចំហប្រព្រឹត្តទៅនៅក្នុងបឹង ទន្លេ និងតំបន់ព្រៃលិចទឹក ដែលត្រូវបានកំណត់នៅខាងក្រៅឡូត៍-នេសាទ និងវាលស្រែដែលស្ថិតនៅក្រៅឡូត៍នេសាទ និងកន្លែងនេសាទបំរុងទុក។ ជាទូទៅ ការនេសាទសិប្បកម្មប្រព្រឹត្តទៅនៅក្នុងលំហទឹក ដោយប្រើប្រាស់អួន លបណ មង និងសំរាស់ ។ ការកំណត់ថ្លៃឈ្នួលឧបករណ៍នេសាទត្រូវបានកំណត់តាមប្រភេទ និង ទំហំឧបករណ៍នេសាទ។

ការនេសាទជាលក្ខណៈគ្រួសារពុំត្រូវការអាជ្ញាប័ណ្ណទេ និងអនុញ្ញាតឱ្យធ្វើនេសាទនៅគ្រប់រដូវ និងគ្រប់ទីកន្លែងក្នុងដែននេសាទសាធារណៈ និងនៅក្នុងឡូត៍នេសាទផងដែរនៅក្នុងរដូវបិទនេសាទ ( មាត្រា ១១)។ ការចូលនេសាទនៅក្នុងឡូត៍នេសាទត្រូវអនុវត្តតាម "សៀវភៅបន្ទុក" ដែលកំណត់ដោយក្រសួងកសិកម្ម។ ការទទួលស្គាល់សិទ្ធិនេសាទជាលក្ខណៈគ្រួសារបែបនេះត្រូវបានចាត់ទុកថាជាចំណុចវិជ្ជមាននៃច្បាប់ជលផលនេះ ដោយសារវាជួយការពារសិទ្ធិសហគមន៍ដើម្បីចូលរួមក្នុងការគ្រប់គ្រងធនធាន។ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ដែននេសាទសាធារណៈត្រូវបានកំណត់ដោយពុំច្បាស់លាស់ និងពុំអាចទ្រទ្រង់កំនើនតំរូវការនៃការនេសាទជាលក្ខណៈគ្រួសារបានគ្រប់គ្រាន់ឡើយ។ ការនេសាទជាលក្ខណៈគ្រួសារច្រើនតែប្រើប្រាស់ឧបករណ៍នេសាទបុរាណ ដែលសមស្របសំរាប់ការនេសាទក្នុងព្រៃលិចទឹក និងតាមស្ទឹងតូចៗ ដែលភាគច្រើនត្រូវបានកាន់កាប់ដោយម្ចាស់ឡូត៍នេសាទ។ ភាគច្រើននៃដែននេសាទសាធារណៈនៅក្នុងលំហទឹកបឹងត្រូវបានប្រើប្រាស់ដោយអ្នក

នេសាទសិប្បកម្មដែលប្រើប្រាស់ឧបករណ៍នេសាទទំនើប ដូចជា អួន ជាដើម ។ លើសពីនេះដែននេសាទសាធារណៈដែលបានកំណត់សំរាប់ការនេសាទជាលក្ខណៈគ្រួសារគួរតែមានការចូលរួមគ្រប់គ្រងដោយអាជ្ញាធរមូលដ្ឋាន។ ការនេសាទជាលក្ខណៈគ្រួសារមិនត្រូវបានអនុញ្ញាតឱ្យធ្វើនៅក្នុងឡូត៍នេសាទនៅរដូវបើកនេសាទ។ នៅក្នុងឡូត៍នេសាទខ្លះការនេសាទជាលក្ខណៈគ្រួសារត្រូវបានហាមឃាត់គ្រប់រដូវ ។

**<u>ការគ្រប់គ្រងសហគមន៍នេសាទ</u>**

បច្ចុប្បន្ន វិស័យនេសាទកំពុងស្ថិតនៅក្រោមកំណែទំរង់ធំបងមួយ។ ការសំរេចថ្មីៗនេះដោយនាយករដ្ឋមន្ត្រីក្នុងការកាត់ចេញឡូត៍នេសាទប្រមាណ ៥៦% ពីឡូត៍នេសាទ សំរាប់ដាក់ឱ្យសហគមន៍ធ្វើនេសាទ មានគោលដៅលើកកំពស់សន្តិសុខស្បៀងសំរាប់ប្រជាពលរដ្ឋនៅជនបទ។

សហគមន៍នេសាទរំពឹងថានឹងមានការផ្តល់អំណាចខ្លះៗ ក្នុងការត្រួតត្រាធនធានជលផលទៅឱ្យសហគមន៍មូលដ្ឋានដោយផ្អែកលើកម្មសិទ្ធិសមូហភាពដែលពុំអាចផ្ទេរបាន ។ ប៉ុន្តែ នៅមានបញ្ហាច្របូកច្របល់ជាច្រើនទាក់ទងនឹងអំណាចត្រួតត្រាធនធាន ដំណោះស្រាយទំនាស់ ការចែករំលែកធនធានក្នុងចំណោមសមាជិកសហគមន៍ និងរវាងសហគមន៍នានា និងអ្នកដែលមិនមែនជាសមាជិកសហគមន៍ ដោយសារទស្សនវិស័យនេះកំពុងស្ថិតនៅក្នុងដំណាក់កាលសាកល្បង និងកែលំអកំហុសឆ្គង។ នៅពេលដែលសេចក្តីព្រាងអនុក្រិត្យស្តីពីសហគមន៍នេសាទពុំទាន់បានទទួលការអនុម័តនៅឡើយ មានការជជែកវែកញែកជាច្រើនអំពីថាតើគួរបន្តប្រមូលថ្លៃឈ្នួលដែននេសាទពីការធ្វើនេសាទជាលក្ខណៈសិប្បកម្ម ឬយ៉ាងណា។ បទពិសោធន៍ពីអតីតកាលបង្ហាញថា ការគ្រប់គ្រងដោយសហគមន៍ពុំអាចទទួលជោគជ័យឡើយ បើពុំមានការបន្តគាំទ្រខាង ផ្នែកច្បាប់ ការកសាងសមត្ថភាព ការកសាងផែនការ និងត្រួតត្រាធនធានសហគមន៍ ការចែករំលែកធនធាន និងដំណោះស្រាយទំនាស់ ។ នៅក្នុងប្រទេសកម្ពុជា វិធីសាស្ត្រនេះត្រូវបានណែនាំឱ្យប្រើប្រាស់ដោយអង្គការអន្តរជាតិ ដូចជា FAO អង្គការមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) អង្គការជំនួយបច្ចេកទេសអាល្លឺម៉ង់ (GTZ) និងអង្គការមិនមែនរដ្ឋាភិបាល ដូចជាអង្គការខនស៊ីន អង្គការសមាគមន៍ការពារបរិស្ថាន និងវប្បធម៌ (CEPA) ។ល។ (សូមអានប្រអប់ទី ៥ និងទី ៦)។ ប៉ុន្តែតែនៅពុំទាន់ប្រាកដថា តើសហគមន៍នានាអាចបន្តអនុវត្តវិធីសាស្ត្រគ្រប់គ្រងដោយសហគមន៍ដោយខ្លួនឯងបានដែរឬ យ៉ាងណានៅពេលជំនួយពីខាងក្រៅត្រូវបញ្ចប់។ បច្ចុប្បន្នមានសហគមន៍នេសាទចំនួនច្រើនជាង ៣០០ ដែលត្រូវបានបង្កើតឡើងនៅទូទាំងតំបន់ដីសើមក្នុងប្រទេសកម្ពុជា ដែលក្នុងនោះមានមួយចំនួនប៉ុណ្ណោះដែលមិនទទួលស្គាល់ជាផ្លូវការពីនាយកដ្ឋានជលផល។ លើសពីនេះ ទោះបីសហគមន៍នេសាទទាំងនេះនៅពុំទាន់មានផែនការគ្រប់គ្រងធនធាន ឬសិទ្ធិចំពោះមុខច្បាប់នៅឡើយ ដែលនេះជាកត្តានាំឱ្យសហគមន៍ជាច្រើនពុំមានអាណត្តិច្បាស់លាស់។ ប្រសិនបើស្ថានភាពបែបនេះនៅតែបន្ត សមាជិកសហគមន៍នឹងបាត់បង់ការជឿទុកចិត្តរវាងគ្នា។ ជាការច្បាស់ណាស់ដែលថា បទពិសោធន៍ក្នុងការគ្រប់គ្រងធនធានដោយផ្អែកលើសហគមន៍នៅពុំទាន់មានគ្រប់គ្រាន់នៅឡើយទេ ចំណែកនៅតាមកន្លែងដែលមានការបង្កើតសហគមន៍រួចហើយដំណើរការរបស់សហគមន៍ទាំងនោះកំពុងស្ថិតនៅក្នុងដំហានដកស្រង់បទពិសោធន៍តែប៉ុណ្ណោះ។

**ប្រអប់ទី ៥ សហគមន៍នេសាទនៅក្នុងខេត្តស្ទឹងត្រែង**

នៅឆ្នាំ១៩៩៧ការិយាល័យជលផលខេត្តស្ទឹងត្រែង ក្រោមកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល CEPA បានបង្កើតសហគមន៍នេសាទចំនួន១៦ នៅក្នុងស្រុកសៀមបូក។ នៅចន្លោះឆ្នាំ ១៩៩៨ និង ២០០២ មានសហគមន៍ចំនួន ១៤ បន្ថែមទៀតត្រូវបានបង្កើតឡើង។ អង្គការ CEPA ក៏បានបន្តគាំទ្រសហគមន៍នេសាទមួយចំនួននៅស្រុកសេសាន ថាឡាបរិវ៉ាត់ និងស្រុកស្ទឹងត្រែងផងដែរ។

សហគមន៍នេសាទនីមួយៗមានគណៈកម្មការមួយដែលមានប្រធានមួយរូប អនុប្រធានមួយរូប និងសមាជិកចំនួនបីរូប។ សហគមន៍នេសាទបានការទទួលស្គាល់ដោយអភិបាលខេត្ត ពិនាយកដ្ឋានជលផលជាបន្តបន្ទាប់។

មានការកត់សំគាល់ជាទូទៅមួយថា សហគមន៍នេសាទបាននាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានចំពោះការគ្រប់គ្រងតំបន់ដីសើម។ សកម្មភាពនេសាទល្មើសច្បាប់បានថយចុះនៅក្នុងតំបន់ដែលមានសហគមន៍នេសាទ។ ឧទាហរណ៍: សហគមន៍នៅអូរម្រះបានពង្រឹងការអនុវត្តបទបញ្ជាសហគមន៍ជាបណ្តើរៗ និងអាចទប់ស្កាត់សកម្មភាពល្មើសច្បាប់ដោយសហការជាមួយនគរបាលឃុំ និងមន្ត្រីជលផល។ សព្វថ្ងៃ ការនេសាទល្មើសច្បាប់ ដូចជា ការប្រើប្រាស់ថ្នាំពុល គ្រឿងផ្ទុះ និងឧបករណ៍ឆក់បានថយចុះជាបណ្តើរៗ។ ហេតុផលរួមដែលនាំឱ្យសហគមន៍នេសាទដទៃទៀតពុំសូវបានទទួលជោគជ័យ គឺដោយសារខ្វះការយល់ដឹងអំពីសហគមន៍នេសាទ ការភ័យខ្លាចចំពោះការគំរាមកំហែងពីអ្នកប្រព្រឹត្តល្មើសច្បាប់ គ្មានជំនួយខាងផ្នែកសំរបសំរួល គ្មានថវិកា គ្មានសំភារៈជាមូលដ្ឋាន និងមធ្យោបាយសំរាប់ត្រួតពិនិត្យ និងស្ថានភាពនៃជីវភាពរស់នៅមានកំរិតទាបពេក។

**ប្រអប់ទី ៦ សហគមន៍នេសាទអន្លង់សំណរ ក្នុងស្រុកជីក្រែង ខេត្តសៀមរាប . ប្រវត្តិអំពីជោគជ័យ**

ដោយសារកំណែទំរង់របស់រដ្ឋាភិបាល ដែននេសាទច្រើនជាង ៥០% ត្រូវបានកាត់ចេញសំរាប់សហគមន៍ធ្វើនេសាទ។ ប្រជាពលរដ្ឋមូលដ្ឋានអាចធ្វើនេសាទជាលក្ខណៈគ្រួសារ និងបង្កើតជាសហគមន៍នេសាទសំរាប់ការពារនិងអភិរក្សធនធានជលផល ។

ដោយមានទីតាំងនៅក្នុងឃុំអន្លង់សំណរ ស្រុកជីក្រែង សហគមន៍នេសាទអន្លង់សំណរត្រូវបានបង្កើតឡើងតាមរយៈការគាំទ្ររបស់អង្គការ FAO។ ជាដំបូង អ្នកសំរបសំរួលបានរៀបចំការបណ្តុះបណ្តាល បន្ទាប់មកបានជួយនៅក្នុងដំណើរការរៀបចំសហគមន៍។ គណៈកម្មការសហគមន៍ត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោត ដោយមានប្រធានមួយរូប និងអនុប្រធានមួយរូប និងមានគណនេយ្យករមួយរូប លេខាមួយរូប ក្រុមល្បាត និងក្រុមផ្សព្វផ្សាយ។

នៅក្នុងឆ្នាំទីមួយនៃដំណើរការរបស់ខ្លួន ការគ្រប់គ្រងមិនបានដំណើរការល្អឡើយ ដោយសារទស្សនៈវិស័យនេះនៅថ្មីសំរាប់ជនរាល់រូប។ ប៉ុន្តែ ដំណើរការនោះបានកែលំអជាបណ្តើរៗ នៅពេលកិច្ចសហការរវាងអាជ្ញាធរមូលដ្ឋាន និងមន្ត្រីបច្ចេកទេសផ្សេងទៀតពាក់ព័ន្ធនៅក្នុងតំបន់នោះត្រូវបានកែលំអ។ មានសេចក្តីរាយការណ៍ថា នៅឆ្នាំ ២០០៣

សហគមន៍នេសាទនេះបានទទួលជោគជ័យក្នុងការថែរក្សាត្រីមេពូជប្រមាណ ១.០០០ តោន នៅក្នុងតំបន់ស្ទឹងជ្រៅ។ ជោគជ័យនេះអាចទទួលបានដោយសារសមាជិកសហគមន៍មានជំនឿលើសមត្ថភាពរបស់អ្នកដឹកនាំសហគមន៍ខ្លួនក្នុងការបញ្ឈប់សកម្មភាពល្មើស និងពង្រឹងការអនុវត្តបទបញ្ជារបស់សហគមន៍ ។ ឧទាហរណ៍បែបនេះនៃការអភិរក្សដោយផ្អែកលើសហគមន៍បាននាំមកនូវជោគជ័យក្នុងការលើកកំពស់ជីវភាពរស់នៅរបស់សហគមន៍ពីមួយឆ្នាំទៅមួយឆ្នាំ។

### *៤.២.២ ការប្រើប្រាស់ដី*

ច្បាប់ភូមិបាលថ្មីត្រូវបានអនុម័តនៅខែ សីហា ឆ្នាំ ២០០១ ។ ច្បាប់នេះផ្តល់ក្របខ័ណ្ឌសំរាប់ការប្រើប្រាស់ធនធាន និង កម្មសិទ្ធិដីនៅទូទាំងប្រទេស។ ច្បាប់នេះចែកជា ១៩ជំពូក និងមាន ២៦៨មាត្រា។ មាត្រាមួយចំនួនដែលពាក់ព័ន្ធនឹងតំបន់ដីសើមមានបកស្រាយដូចខាងក្រោម។

មាត្រាទី ៣ នៃច្បាប់នេះចែងអំពីអាណត្តិសំរាប់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការគ្រប់គ្រងដីធ្លីជាទ្រព្យសម្បត្តិរដ្ឋ និងសាធារណៈ និងក្នុងការចេញលិខិតបញ្ជាក់កម្មសិទ្ធិដីនៅទូទាំងប្រទេស។ មាត្រាទី ៧ ចែងថា កម្មសិទ្ធិដីធ្លីមុនឆ្នាំ ១៩៧៩ ត្រូវទុកជាមោឃៈ។ មានតែជនជាតិខ្មែរដែលមានសិទ្ធិលើកម្មសិទ្ធិដីក្នុងព្រះរាជាណាចក្រកម្ពុជា (មាត្រាទី៨)។ មាត្រាទី ១៦ ចែងថា ធនធានធម្មជាតិទាំងអស់និងដីធ្លី ជារបស់រដ្ឋនិងមិនអាចលក់ ឬផ្ទេរបានឡើយ។ មាត្រា ២៣-២៥ ទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិច ក្នុងការកាន់កាប់ដី និងចែងថាអាជ្ញាធរពុំមានសិទ្ធិលើដីរបស់សហគមន៍ជនជាតិដើមឡើយ ។

ដីសម្បទានដែលផ្តល់ឱ្យក្រុមហ៊ុនឯកជនសំរាប់សកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច ដូចជាការជីកយករ៉ែ ការសាងសង់កំពង់ផែ ព្រលានយន្តហោះ តំបន់ឧស្សាហកម្ម កសិកម្ម ឡូតិ៍នេសាទ ។ល។ ពុំស្ថិតនៅក្រោមសមត្ថកិច្ចនៃច្បាប់នេះទេ (មាត្រា ៥០) ។ ទោះជាយ៉ាងនេះក្តី រាល់ដីសម្បទានត្រូវចុះបញ្ជីនៅក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ (មាត្រា ៥៣) ដែលមានន័យថាត្រូវមានការឯកភាពពីក្រសួងនេះ ។ ការកំណត់ជាដីសម្បទានអាចធ្វើបានតែនៅលើដីជាកម្មសិទ្ធិរបស់រដ្ឋ ប្រសិនបើពុំមានផលប៉ះពាល់អវិជ្ជមានចំពោះហេដ្ឋារចនាសម្ព័ន្ធ ផ្លូវទឹក ស្រះ និងដែនបំរុងធម្មជាតិ ដែលមានសារៈសំខាន់សំរាប់ការរស់នៅរបស់ប្រជាជន ។

អវត្តមាននៃគោលនយោបាយ និងផែនការមេសមស្របអំពីការប្រើប្រាស់ដី ធ្វើឱ្យការអនុវត្តរបបគ្រប់គ្រងដីធ្លីសព្វថ្ងៃពុំមានលក្ខណៈប្រាកដប្រជា។ ច្បាប់ស្តីពីផែនការ នគរូបនីយកម្ម និងសំណង់នៅក្នុងប្រទេសពុំមានប្រសិទ្ធិភាពឡើយ ដោយសារពុំទាន់មានការរៀបចំផែនការមេអំពីការប្រើប្រាស់ដី សំរាប់ខេត្តណាមួយនៅឡើយទេ ។ នេះជាមូលហេតុដែលនាំឱ្យតំបន់ដីសើមមួយចំណែកធំត្រូវបានបំលែងជាដីកសិកម្ម ឬត្រូវចាក់លុបបំពេញសំរាប់ការពង្រីកទីក្រុង ។ តំបន់ទាំងនោះច្រើនតែងាយខូចខាតដោយសារទឹកជំនន់ សត្វចង្រៃ និងមានផលិតភាពទាប ។

### *៤.២.៣ ការអភិរក្ស និងការពារបរិស្ថាន*

ការអភិរក្សនិងការពារបរិស្ថានមានចែងច្បាស់នៅក្នុងច្បាប់របស់កម្ពុជា ។ មាត្រាទី ៥៩ នៃរដ្ឋធម្មនុញ្ញបានកំណត់ឱ្យរដ្ឋការពារបរិស្ថាន និងធនធានធម្មជាតិ និងតំរូវឱ្យមានការកសាងផែនការត្រឹមត្រូវដើម្បីគ្រប់គ្រងបរិស្ថាន ដែលជាមូលដ្ឋានសំរាប់ក្រសួងបរិស្ថានក្នុងការអនុម័តច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយសំរាប់ការពារបរិស្ថានទាំងនៅថ្នាក់ជាតិ និង

អន្តរជាតិ ។ ច្បាប់បរិស្ថានដែលបានអនុម័តនៅឆ្នាំ ១៩៩៦ បានចែងយ៉ាងទូលាយអំពីគោលការណ៍ទូទៅ និងមានមាត្រាជាក់លាក់ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ។ ប៉ុន្តែ ច្បាប់បរិស្ថានមានអំណាចតិចតួចក្នុងការគ្រប់គ្រង និងរាំងស្កាត់ឧក្រិដ្ឋកម្មបរិស្ថាន ។ គ្របខ័ណ្ឌច្បាប់សំខាន់បំផុតទាក់ទងនឹងការអភិរក្សធនធានធម្មជាតិ ជាពិសេសតំបន់ដីសើម មានចែងនៅក្នុងព្រះរាជក្រឹត្យ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ (១៩៩៣) ។ ព្រះរាជក្រឹត្យនេះ កំណត់តំបន់ការពារធម្មជាតិចំនួន ២៣កន្លែង ដែលមានវិសាលភាពសរុបប្រមាណ ១៨% នៃផ្ទៃដីប្រទេសកម្ពុជា ។ តំបន់ទាំងនោះត្រូវបានចែកជា ៤ក្រុម គឺ ឧទ្យានជាតិ ដែនជំរកសត្វព្រៃ តំបន់ប្រើប្រាស់ច្រើនយ៉ាង និងតំបន់ការពារទេសភាព ។

តំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងទន្លេសាប និងឧទ្យានជាតិរាម ត្រូវបានកំណត់សំរាប់ការអភិរក្ស និងប្រើប្រាស់តំបន់ដីសើមដោយឈ្លាសវៃ ។ លើសពីនេះ តំបន់ដីសើមខ្លះទៀត ត្រូវបានកំណត់តាមរយៈអនុសញ្ញានិងកិច្ចព្រមព្រៀងអន្តរជាតិ ដូចជាអនុសញ្ញារ៉ាមសា (កោះកាពិ បឹងទន្លេឆ្មា និងស្ទឹងត្រង់) និងបណ្តាញជំបនីយ៍ជីវមណ្ឌល (ជំបនីយ៍ជីវមណ្ឌលបឹងទន្លេសាប សូមអានប្រអប់ទី ៧) ។ ប៉ុន្តែដូចក្នុងករណីអនុសញ្ញាអន្តរជាតិភាគច្រើនដែរ ការគ្រប់គ្រងជាក់ស្តែង និងការចាត់ចែងគ្របខ័ណ្ឌច្បាប់សំរាប់អនុវត្ត ត្រូវផ្អែកលើគោលនយោបាយរបស់រដ្ឋាភិបាលជាម្ចាស់ផ្ទះ និងអង្គភាពមួយចំនួន ។ ទោះបីទីតាំងតំបន់រ៉ាមសាទាំង៣ ត្រូវបានចុះបញ្ជីជាតំបន់ដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិក្តី តំបន់ទាំងនេះ នៅពុំទាន់បានគ្រប់គ្រងតាមផែនការគ្រប់គ្រងណាមួយនោះនៅឡើយទេ (ទោះបីផែនការគ្រប់គ្រងត្រូវបានរៀបចំឡើង សំរាប់តំបន់រ៉ាមសាបឹងទន្លេឆ្មាក្តី ផែនការនោះពុំត្រូវបានយកមកអនុវត្តឡើយ) ។ ករណីអវត្តមានបទប្បញ្ញត្តិទាក់ទងនឹងតំបន់ដីសើម ច្បាប់សព្វថ្ងៃ ដូចជាច្បាប់ជលផល នៅតែជាបរិធានច្បាប់តែមួយគត់សំរាប់ការគ្រប់តំបន់ដីសើម ។ ប្រការចាំបាច់គឺត្រូវឱ្យមានរដ្ឋបាលគ្រប់គ្រងស្របច្បាប់ឱ្យបានប្រសើរជាងមុន ជាពិសេសសំរាប់អភិរក្សតំបន់ដីសើម។ សព្វថ្ងៃក្រសួងបរិស្ថានកំពុងពិនិត្យឡើងវិញនូវសេចក្តីព្រាងច្បាប់តំបន់ការពារធម្មជាតិ ដែលមានមាត្រាជាក់លាក់ជាច្រើនចែងអំពីការជំរុញអភិរក្ស និងការពារតំបន់ការពារធម្មជាតិ ព្រមទាំងតំបន់ដីសើម ។ ដោយសារតំបន់ដីសើមពាក់ព័ន្ធនឹងអ្នកប្រើប្រាស់ខុសៗជាច្រើន ហេតុនេះការសម្របសម្រួលស្ថាប័នមានសារៈសំខាន់ ដើម្បីធានាឱ្យមានការគ្រប់គ្រងចំរុះ និងស៊ីសង្វាក់គ្នា ។

**ប្រអប់ទី ៧ ជំបនីយ៍ជីវមណ្ឌលបឹងទន្លេសាប ជាវិធានមួយសំរាប់លើកកំពស់ការអភិរក្សតំបន់ដីសើម**

នៅឆ្នាំ១៩៩៧ និងតាមរយៈកម្មវិធីជំបនីយ៍ជីវមណ្ឌលបឹងទន្លេសាប ក្រសួងបរិស្ថានបានផ្តួចផ្តើមគំរោងបង្ហាញមួយនៅព្រែកទាល់ក្នុងឃុំកោះជីវាំង។ គំរោងបង្ហាញនេះ មានគោលដៅ (i) ជំរុញការអប់រំ និងបង្កើនការយល់ដឹងអំពីបរិស្ថាននៅក្នុងចំណោមមនុស្សស្រទាប់ក្រោម (ii) ធ្វើការស្រាវជ្រាវ និងតាមដានជាទៀងទាត់អំពីសកម្មភាពអេកូឡូស៊ី (iii) ជំរុញការអភិរក្សព្រៃលិចទឹក និងសត្វព្រៃដែលមានសារៈសំខាន់ជាអន្តរជាតិ (iv) កំណត់វិធីសផ្សេងនៃការចិញ្ចឹមជីវិត និងការលើកទឹកចិត្តឱ្យសហគមន៍ចូលរួម និង (v) ពិនិត្យមើលសក្តានុពលសំរាប់រៀបចំអេកូទេសចរណ៍ ។ ស្ថានីយ៍ស្រាវជ្រាវបរិស្ថានដំបូងបង្អស់មួយ ត្រូវបានកសាងឡើងសំរាប់អនុវត្តជាប្រចាំថ្ងៃ អនុលោមតាមគោលបំណងខាងលើ ។ ស្ថានីយនេះជួលអ្នកភូមិ ២៥នាក់ ជាបុគ្គលិក និងគ្រប់គ្រងដោយមន្ត្រីបរិស្ថានពីររូប នៅក្រោមការចាត់ចែងទូទៅនៃប្រធានក្រុមសម្របសម្រួលក្រុមបច្ចេកទេសបឹងទន្លេសាប ។ ការងារនេះបានប្រព្រឹត្តទៅនៅក្រោមការឧបត្ថម្ភ

ថវិកាពីអង្គការ យូណេស្កូ និងអង្គការសមាគមន៍អភិរក្សសត្វព្រៃ (WCS) ។ សព្វថ្ងៃស្ថានីយ៍ស្រាវជ្រាវនេះមានសកម្មភាពដូចតទៅ:

អភិរក្សនិងតាមដានប្រភេទសត្វស្លាបជិតផុតពូជ: តំបន់ស្នូលព្រៃកទាល់នៃបម្រុងជីវមណ្ឌលបឹងទន្លេសាប គឺជាជំរកសំរាប់សត្វព្រៃជាច្រើនប្រភេទ ជាពិសេសសត្វស្លាបទឹកធំៗ។ ដោយសារសត្វស្លាបទាំងនោះមានតំលៃខ្ពស់ និងមានការរំខានជាញឹកញាប់ពីសំណាក់អ្នកលួចចាប់សត្វ ប៉ុស្តិ៍សង្កេតការណ៍ចំនួនពីរ ត្រូវបានកសាងឡើង ដើម្បីឱ្យបុគ្គលិកនៅមូលដ្ឋានអាចនៅប្រចាំការទាំងថ្ងៃទាំងយប់ ដើម្បីពិនិត្យនិងសង្កេតសត្វស្លាប ។ អង្គការWCS ជាអ្នកផ្តល់ការគាំទ្រហិរញ្ញវត្ថុសំរាប់ការងារនេះ ។ ដោយសារកិច្ចប្រឹងប្រែងទាំងនេះ សំបុកសត្វជាច្រើនពុំរងការបំផ្លិចបំផ្លាញទេនៅឆ្នាំនេះ ហើយមានកូនសត្វជាច្រើនបានញាស់ដោយជោគជ័យ ។ បុគ្គលិកនៅមូលដ្ឋានបានរាប់ និងកត់ត្រាចំនួនប្រភេទសត្វស្លាបទាំងនោះជាទៀងទាត់ ។

ការយល់ដឹងអំពីបរិស្ថាន: សកម្មភាពបង្កើនការយល់ដឹងអំពីបរិស្ថានតាមរូបភាពជាច្រើនត្រូវបានអនុវត្តដោយបុគ្គលិកនៅស្ថានីយ៍ស្រាវជ្រាវនេះ ដូចជាការប្រជុំពិគ្រោះយោបល់ សិក្ខាសាលា បទបង្ហាញតាមរយៈវីដេអូ ការផ្សព្វផ្សាយឯកសារ និងសន្លឹករូបភាព ។ល។ ឱ្យដល់មនុស្សចាស់ មនុស្សពេញវ័យ និងកុមារ ។ ឯកសារទាំងនោះត្រូវបានផ្សព្វផ្សាយដល់មនុស្សទូទៅ និងសហគមន៍នៅក្នុងឃុំនានា ។ ទាំងសិស្សសាលា និងក្មេងដែលមិនបានចូលរៀន ត្រូវបានអញ្ជើញមកស្ថានីយ៍នេះ និងចូលរួមនៅក្នុងការធ្វើទស្សនកិច្ច ដើម្បីសិក្សាអំពីត្រី សត្វស្លាប សត្វព្រៃ និងព្រៃលិចទឹក ដើម្បីឱ្យពួកគេបានយល់ពីសារៈសំខាន់នៃធនធាននៅជុំវិញឃុំរបស់ពួកគេ ។ យើងសង្ឃឹមថាពួកគេនឹងផ្សព្វផ្សាយចំណេះដឹងនេះបន្ត ទៅឪពុកម្តាយរបស់ពួកគេ ។

ជំរើសផ្សេងនៃការចិញ្ចឹមជីវិត: មានការផ្តួចផ្តើមកម្មវិធីមួយចំនួនដើម្បីកំណត់ប្រភពនានា សំរាប់សហគមន៍រកប្រាក់ចំណូល ជំនួសឱ្យមានបរបាញ់សត្វព្រៃ ការចាប់សត្វស្លាបទឹក និងការកាប់ឈើ ។ មានកម្មវិធីឥណទានមួយដែលបានអនុវត្តស្របគ្នាជាមួយគំរោងអន្តរាគមន៍ខ្នាតតូច ដែលផ្តល់មូលនិធិដោយកម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍របស់ប្រទេស បែលហ្សិក ដែលកម្មវិធីនេះបានអនុវត្តនៅឃុំកោះជីវាំង ។ គ្រួសារប្រហែល ១០០ បានទទួលប្រាក់កំចីនិង ប្រាក់អំណោយសំរាប់ ទិញឧបករណ៍នេសាទខ្នាតតូច ការចិញ្ចឹមជ្រូក មាន់ និងទា វារីវប្បកម្ម និងការលក់ត្រីនិងបន្លែ ។ តាមរយៈអន្តរាគមន៍ផ្នែកហិរញ្ញវត្ថុបែបនេះ គ្រួសារក្រីក្របានទទួលការលើកទឹកចិត្ត និងការទូទាត់ដើម្បីឱ្យពួកគេ បញ្ឈប់សកម្មភាពល្មើសច្បាប់ ដូចជាការបរបាញ់សត្វព្រៃ និងការកាប់ឈើ ។ តាមរយៈកម្មវិធីនេះសម្ពាធលើធនធានធម្មជាតិត្រូវបានកាត់បន្ថយ ។ ការបណ្តុះបណ្តាលអំពីវារីវប្បកម្ម និងការចិញ្ចឹមសត្វក៏បានរៀបចំឱ្យមានផងដែរ ។

អេកូទេសចរណ៍ : វត្តមានសត្វស្លាបទឹកដែលមានតំលៃជាអន្តរជាតិ បានផ្តល់សក្តានុពលខ្ពស់សំរាប់ការអភិវឌ្ឍន៍អេកូទេសចរណ៍ ដែលនាំមកនូវប្រាក់ចំណូលសំរាប់សហគមន៍មូលដ្ឋាន និងរដ្ឋាភិបាល ។ តាមរយៈកិច្ចសហការណ៍ជាមួយភ្នាក់ងារទេសចរណ៍ និងអង្គការមិនរដ្ឋាភិបាល ស្ថានីយ៍នេះបានផ្តួចផ្តើមសកម្មភាពអេកូទេសចរណ៍ចាប់តាំងពីឆ្នាំ ១៩៩៩ មកម្លេះ ។ ទោះបីសព្វថ្ងៃនេះប្រាក់ចំណូលបានពីអេកូទេសចរណ៍ មានកំរិតទាបនៅឡើយក្តី ធៀបនឹងប្រាក់

ចំណូលពីការជួលដែននេសាទ សកម្មភាពបែបនេះនឹងនាំឱ្យមានកំណើនប្រាក់ចំណូលយ៉ាងច្រើននៅក្នុងរយៈពេល ១០ឆ្នាំខាងមុខ ប្រសិនបើមានការចាត់ចែងនិងបទបញ្ជាគ្រប់គ្រងបានច្បាស់លាស់ ។

# ៥. ការទាយតំលៃសេដ្ឋកិច្ចតំបន់ដីសើម

## ៥.១ តំលៃ និងការវាយតំលៃតំបន់ដីសើម

តំលៃតំបន់ដីសើមអាចមើលឃើញដោយងាយស្រួល ឬដោយលំបាកបំផុត។ ការប្រើប្រាស់ធនធានដោយផ្ទាល់ ដូចជាការនេសាទ ការបរបាញ់ ការប្រើប្រាស់ទឹកសំរាប់ស្រោចស្រព ។ល។ ត្រូវបានសង្កេតឃើញយ៉ាងងាយស្រួល និង បានទទួលការយកចិត្តទុកដាក់ទាំងក្នុងវិស័យសង្គម និងសេដ្ឋកិច្ច (Said et al. 1992) ។ ចរិតលក្ខណៈដែលមិនចាំបាច់តែផ្តល់តួនាទី ឬទ្រទ្រង់ការប្រើប្រាស់ អាចត្រូវបានចាត់ទុកថាជា "តំលៃបែបធម្មជាតិ" ។ តំលៃទាំងនេះរួមមានភាពសំបូរបែបនៃជីវៈចំរុះ គុណភាពនៃទេសភាពធម្មជាតិ ឬសោភ័ណភាព ភាពសំបូរប្រភេទប្រចាំទី (high endemism) ជាមណ្ឌលសំខាន់នៃធនធានសេនេទិច វត្តមាននៃប្រភេទកំរ ឬប្រភេទជិតផុតពូជ ប្រភពព័ត៌មាន ឬទិន្នន័យសំរាប់ការយល់ដឹងប្រសើរថែមទៀតអំពីប្រព័ន្ធអេកូឡូស៊ី ។ល។

មនុស្សទាំងអស់មិនមែនសុទ្ធតែមានទស្សនៈដូចគ្នាអំពីតំបន់ដីសើមនោះឡើយ។ រវាងអ្នកក្រ និងអ្នកមាន រវាងអ្នកប្រើប្រាស់ដោយផ្ទាល់និងដោយប្រយោល រវាងប្រជាពលរដ្ឋក្នុងមូលដ្ឋាននិងអ្នកមកពីខាងក្រៅ និងរវាងភាគីពាក់ព័ន្ធនានា ពួកគេសុទ្ធតែមានគំនិតប្លែកៗគ្នាជាច្រើនអំពីតំលៃនៃតំបន់ដីសើម។ មានករណីជាច្រើនផងដែរដែលប្រជាពលរដ្ឋរស់នៅក្នុងតំបន់ដីសើមមិនឱ្យតំលៃ ឬឱ្យតំលៃទាបចំពោះតំបន់ដីសើម រីឯបុគ្គលជាច្រើនដែលរស់នៅឆ្ងាយពីតំបន់ដីសើមក៏អាចមានការឱ្យតំលៃខ្ពស់ចំពោះតំរូវខ្លះនៃការប្រើប្រាស់តំបន់ដីសើមផងដែរ។ ឧទាហរណ៍: អ្នកទាំងនោះខ្លះអាចចូលចិត្តកំសាន្តនៅតាមតំបន់ដីសើម ហេតុនេះពួកគេឱ្យតំលៃខ្ពស់ចំពោះការប្រើប្រាស់បែបនោះ។

ទោះបីមនុស្សបានទាញយកអត្ថប្រយោជន៍ដោយផ្ទាល់ជាច្រើនពីតំបន់ដីសើមក្តី ការយល់ដឹងក៏រិតទាបអំពីដំណើរប្រព្រឹត្តទៅនៅក្នុងតំបន់ដីសើមអាចជាមូលហេតុដែលនាំឱ្យមានការវាយតំលៃទាបចំពោះតំបន់ដីសើម។ ការប្រើប្រាស់ធនធាន និងសេវាតំបន់ដីសើមជាលក្ខណៈបើកចំហរនិង/ឬគ្មានកំរិតកំនត់អាចមានឥទ្ធិពលលើអាកប្បកិរិយាចំពោះតំបន់ដីសើម ហើយនេះជាហេតុនាំឱ្យមានឥទ្ធិពលលើវិធីវាយតំលៃតំបន់ដីសើម។ នៅពេលដែលមានការដាក់កំហិតចំពោះការប្រើប្រាស់ធនធាន និងសេវា ឬនៅពេលធនធានទាំងឡាយកាន់តែខ្សត់ទៅៗ ឬ អត្ថប្រយោជន៍ពីតំបន់ដីសើមកាន់តែធ្លាក់ចុះ ឬត្រូវបាត់បង់ទាំងស្រុង ប្រជាពលរដ្ឋនឹងយល់កាន់តែច្បាស់អំពីតំលៃនៃតំបន់ដីសើម ហើយចាប់ផ្តើមកោតសរសើរពីលទ្ធភាពប្រើប្រាស់កាលពីមុន។ ការវាយតំលៃ ឬកោតសរសើរឆ្លុះបញ្ចាំងអំពីអាកប្បកិរិយានិងជំរើសរវាងការប្រើប្រាស់នានា។ អ្នកខ្លះអាចឱ្យតំលៃតំបន់ដីសើមដោយផ្អែកលើអត្ថប្រយោជន៍ ឬផលចំណេញទទួលបានដោយផ្ទាល់ពីជំរើសផ្សេងៗនៃការប្រើប្រាស់។ ប្រអប់ទី ៨ បង្ហាញពីអត្ថប្រយោជន៍ជាច្រើនផ្តល់ដោយដំបន់ដីសើម។

ប្រអប់ទី ៤. អត្ថប្រយោជន៍នានានៃតំបន់ដីសើម (តាម Howe et al. 1991).

១ ផ្គត់ផ្គង់ទឹក

ក. សំរាប់ប្រជាពលរដ្ឋប្រើប្រាស់ដោយផ្ទាល់

ខ. ទៅទឹកខ្លែងផ្សេងៗ

គ. ទៅអាងទឹកធម្មជាតិក្រោមដី (aquifer)

ឃ. ទៅតំបន់ដីសើមផ្សេងៗទៀត

២. និយ័តកម្មលំហូរទឹក ជាពិសេសកាត់បន្ថយទឹកជំនន់

៣. រាំងស្កាត់ការជ្រាបចូលនៃទឹកសមុទ្រ

ក. ខ្សែទឹកក្រោមដី

ខ. ទឹកនៅលើផ្ទៃដី

៤. ការពារទល់នឹងកំលាំងធម្មជាតិ

ក. ការពារខ្សែឆ្នេរ និងគ្រប់គ្រងសំណឹកដី

ខ. របាំងខ្យល់

៥. ច្រោះ/ស្តុកកំទេចកំណក

៦. ច្រោះ/ស្តុកសារធាតុចិញ្ចឹម

៧. ច្រោះ/ស្តុកសារធាតុពុល

៨. ប្រភពផលិតផលធម្មជាតិ (នៅកន្លែងដើម)

៩. ប្រភពផលិតផលធម្មជាតិ (នៅក្រៅកន្លែងដើម)

១០. ផលិតកម្មថាមពល

១១. ការដឹកជញ្ជូនតាមផ្លូវទឹក

១២. ឃ្លាំងសេនេទិច

១៣. សារៈសំខាន់សំរាប់ការអភិរក្ស

ក. ទីជំរកសំខាន់ៗសំរាប់ប្រភេទសត្វ និងរុក្ខជាតិសំខាន់ៗរស់នៅគ្រប់ដំណាក់កាលនៃវដ្តជីវិតរបស់វា

ខ. វត្តមាននៃប្រភេទ ទីជំរក សហគមន៍ ប្រព័ន្ធអេកូឡូស៊ី តំបន់ទេសភាពធម្មជាតិ ធាតុភូត ឬ ប្រភេទនៃតំបន់ដីសើម ដែលមានដោយកំរ

១៤. ការកំសាន្ត/ទេសចរណ៍

១៥. សារៈសំខាន់ខាងសង្គម-វប្បធម៌

ក. ផ្នែកចំបងនៃតំបន់ដែលមានសារៈសំខាន់ខាងទេសភាព/សោភ័ណភាពធម្មជាតិ

ខ. សារៈសំខាន់ខាងសាសនា និង ជំនឿ

គ. វត្តមានសកម្មភាពមនុស្សដែលមានលក្ខណៈប្លែកពីគេ

ឃ. ទីរហោស្ថាន

ង. ទីតាំងមានសារៈសំខាន់ខាងប្រវត្តិសាស្ត្រ

១៦. ទីតាំងសំរាប់ការស្រាវជ្រាវ និងអប់រំ

ក. ទីតាំងសំរាប់ការស្រាវជ្រាវវិទ្យាសាស្ត្រ

ខ. លក្ខណៈពិសេសប្រចាំមូលដ្ឋាន

គ. ទីតាំងសំរាប់ការអប់រំ

១៧. វិភាគទានចំពោះការថែរក្សាបាតុភូត ឬប្រព័ន្ធធម្មជាតិដែលមានស្រាប់

ក. បាតុភូត និងប្រព័ន្ធអេកូឡូស៊ី និងភូគព្ភសាស្ត្រ

ខ. អាងស្រូបកាបូន

គ. រាំងស្កាត់ការប្រែក្លាយទៅជាដីអាស៊ីត

១៨. តំណាងនៃតំបន់ដីសើមជំពូកណាមួយជាក់លាក់

## ៥.២ មុខងារ និងការប្រើប្រាស់តំបន់ដីសើម

អន្តរកម្មរវាងសមាសភាគនានាក្នុងប្រព័ន្ធតំបន់ដីសើមត្រូវបានឱ្យឈ្មោះថា មុខងារ (Barbier *et al.* 1996)។ មុខងារទាំងនោះរួមមាន វដ្តសារធាតុចិញ្ចឹម និងបណ្តូររវាងទឹកនៅលើផ្ទៃដី ទឹកក្រោមដី និងទឹកក្នុងបរិយាកាស និងសំរុបទឹកជំនន់ និងទឹកភ្លៀង ។ល។ ផលសំរេចនៃមុខងារនេះត្រូវបានស្តែងឡើងក្រោមរូបភាពជា ផលិតផល និងសេវា ដែលផ្តល់ដោយតំបន់ដីសើម។

ការប្រើប្រាស់អាចចាត់ទុកថាជាការប្រើប្រាស់ដោយផ្ទាល់នូវសំណុំលក្ខណៈមួយឬច្រើននៃតំបន់ដីសើម និងអាចរួមមានការដកហូតផលិតផលរុក្ខជាតិ និងសត្វ ការផ្គត់ផ្គង់ទឹក និងការប្រើប្រាស់ដែលមិនមែនជាការដកហូត ដូចជា ការដឹកជញ្ជូនតាមផ្លូវទឹក ការកំសាន្ត/ទេសចរណ៍ ទីតាំងស្រាវជ្រាវ ទីតាំងសំរាប់សិក្សាតាមដាន ទីតាំងសំរាប់ការអប់រំ កន្លែងចោលសំណល់ប្រព្រឹត្តកម្មសំអាតទឹក ផលិតកម្មថាមពល ។ល។ (Said, 1992) ។ លទ្ធផលនៃការប្រើប្រាស់អាចស្តែងចេញជាផលិតផលដែលដកហូតបាន សេវានានា ឬឧទ្ទិន្នន័យ និងព័ត៌មានអំពីតំបន់ដីសើម និងការយល់ដឹងអំពីតំបន់ដីសើម។ ការប្រើប្រាស់អាចមានរូបភាពខុសៗគ្នាពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀត នៅពេលខុសគ្នានៃឆ្នាំនីមួយៗ និងក្នុងចំណោមក្រុមមនុស្សខុសៗគ្នា។ ជាទូទៅ ការប្រើប្រាស់តំបន់ដីសើមក្នុងប្រទេសកម្ពុជា មានជាអាទិ៍ ការនេសាទ វារីវប្បកម្ម ការផ្គត់ផ្គង់ទឹក និយ័តកម្មទឹកជំនន់ ការកំសាន្ត ការដឹកជញ្ជូនតាមផ្លូវទឹក និងការតាំងទីលំនៅ។

### *៥.២.១ ការប្រើប្រាស់តំបន់ដីសើមចំបងៗតាមវិស័យ*

វិស័យសំខាន់ៗនៃការប្រើប្រាស់តំបន់ដីសើមមានជាអាទិ៍ កសិកម្ម នេសាទ និងប្រមាញ់ វារីវប្បកម្ម ផ្គត់ផ្គង់ទឹក ការធ្វើអាជីវកម្មឈើ និងអនុផលព្រៃឈើ ទេសចរណ៍ ការដឹកជញ្ជូនតាមផ្លូវទឹក និងការតាំងទីលំនៅលើផ្ទៃទឹក និងការអភិរក្ស។ ការប្រើប្រាស់តាមវិស័យទាំងអស់នេះមានទំនាក់ទំនងគ្នាទៅវិញទៅមក និងបានវិវត្តន៍ពីទំលាប់ប្រើប្រាស់តាមបែបប្រពៃណីដែលច្រើនតែមានទ្រង់ទ្រាយតូច និងមិនមានលក្ខណៈបំផ្លាញ មករបៀបប្រើប្រាស់បច្ចុប្បន្នដែលមានទ្រង់ទ្រាយធំ និងមានលក្ខណៈស្មុគស្មាញ ដោយសារការរីកចំរើននៃបច្ចេកវិទ្យា។

<u>កសិកម្ម</u>

ផ្ទៃដីដាំដុះរបស់សរុបមាន ៣.៧៨ លានហិកតា ដែលត្រូវជាប្រមាណ ២០% នៃផ្ទៃប្រទេសទាំងមូល។ ដោយហេតុថាស្រូវគឺជាអាហារមូលដ្ឋានសំរាប់ប្រជាជនកម្ពុជា ការដាំដុះស្រូវគឺជាសកម្មភាពចំបងក្នុងសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន។ វាលស្រែភាគច្រើនស្ថិតនៅលើតំបន់ដីសើមដែលបាត់បង់ព្រៃតាំងពីយូរមកហើយ ឬដែលទើបនឹងរានឆ្ការនៅពេល

ថ្មី១នេះ។ ផ្ទៃដីស្រែសរុបក្នុងប្រទេសបានកើនឡើងគួរឱ្យកត់សំគាល់ពី១.៧៣៥.០០០ហិកតាក្នុងឆ្នាំ១៩៨៨ដល់១.៩២៨.៦៨៩ ហិកតា ក្នុងឆ្នាំ ១៩៩៧ (FAO STAT 1998) និងដល់ ២.១៥៨.០០០ ហិកតា នៅឆ្នាំ ១៩៩៩ (RGC 2001)។ ស្រែទាំងនោះភាគច្រើនស្ថិតនៅក្នុងខេត្តបាត់ដំបង តាកែវ កណ្ដាល កំពង់ស្ពឺ និងព្រៃវែង។ ប្រព័ន្ធវប្បកម្មផ្ដោតលើដំណាំស្រូវដែលពឹងផ្អែកលើទឹកភ្លៀង និងមានផ្ទៃដីតិចតួចតែប៉ុណ្ណោះដែលទទួលទឹកពីប្រព័ន្ធស្រោចស្រពខ្លះ១។ ប្រការនេះនាំឱ្យទិន្នផលស្រូវជាមធ្យមមានកំរិតទាប ដោយសារផលិតភាពស្រូវពឹងផ្អែកលើទឹកភ្លៀងដែលធ្លាក់ពុំទៀងទាត់។ ទិន្នផលស្រូវដែលពឹងផ្អែកលើទឹកភ្លៀងមានអត្រាទាបជាងទិន្នផលដំណាំប្រចាំឆ្នាំខ្លះ១ផ្សេងទៀត ។ ជាទូទៅ ការដាំស្រូវក្នុងតំបន់ដីសើមបានធ្វើឡើងជាបួនបែបៈ ធ្វើស្រូវវស្សា ស្រូវប្រដេញទឹក ស្រូវប្រាំង និងស្រូវឡើងទឹក។

ជាធម្មតា ដំណាំស្រូវវស្សាធ្វើឡើងនៅទីទួលខ្ពស់ដែលអាចលិចទឹកនៅពេលមានជំនន់ធម្មតា និងជំនន់ធំ។ ផលិតផលស្រូវបែបនេះអាស្រ័យជាចំបងលើវដ្ដនៃទឹកជំនន់ និងកំពស់ទឹកភ្លៀងប្រចាំឆ្នាំ ។ ដំណាំស្រូវវស្សាដែលជួនកាលគេហៅថា ស្រូវពឹងទឹកភ្លៀង លាតសន្ធឹងលើផ្ទៃដីប្រមាណ១.៧៤៦.៧០០ ហិកតា (MoE 1999)ដែលត្រូវជា ៩០% នៃផ្ទៃដីស្រែទាំងអស់។

គេស្ទូងស្រូវប្រដេញទឹកភ្លាម១ក្រោយពេលទឹកជំនន់ស្រកផុតពីស្រែ រីឯស្រូវប្រាំងត្រូវបានគេស្ទូងនៅពេលខុស១គ្នានៅក្នុងរដូវប្រាំង។ វាលស្រែទាំងនេះទទួលទឹកស្រោចស្រពពីអាងស្តុកទឹកសិប្បនិម្មិត ឬពីអាងទឹកធម្មជាតិ។ តំបន់ដីសើមដែលច្រើនតែស្ថិតនៅតាមទីទំនាបជាយជុំវិញទំនាបលិចទឹកប្រព័ន្ធបឹងទន្លេសាប ទន្លេបាសាក់ និងទន្លេមេគង្គ គឺជាទីតាំងសំខាន់សំរាប់ការធ្វើស្រូវប្រដេញទឹក។ ដោយហេតុថា ដីតំបន់ទាំងនោះប្រកបដោយជីជាតិ ដោយបានទទួលល្បាប់ចាក់បំពេញដោយសារទឹកជំនន់ប្រចាំឆ្នាំ តំបន់នេះត្រូវបានចាត់ទុកថា មានផលិតភាពខ្ពស់ និងរួមចំណែកប្រមាណ ៨.៦% នៃផលិតផលស្រូវសរុបក្នុងប្រទេសកម្ពុជា។ ជាទូទៅ ការអនុវត្តដាំដុះស្រូវក្នុងប្រទេសកម្ពុជាធ្វើឡើងតែម្ដងក្នុងមួយឆ្នាំ ប៉ុន្តែនៅលើដីស្រែសំរាប់ស្រូវប្រដេញទឹក និងដីស្រែប្រាំង ការដាំស្រូវអាចធ្វើឡើងច្រើនជាងម្ដងក្នុងមួយឆ្នាំ នៅតាមតំបន់ដែលមានប្រព័ន្ធស្រោចស្រព។ ប៉ុន្តែសក្ដានុពលបង្កើនមុខដំណាំលើដីតំបន់នេះមានកំរិតទាប ដោយហេតុថាមានផ្ទៃដីតិចជាង ៥% តែប៉ុណ្ណោះដែលមានដាំដំណាំផ្សេង១ទៀតប្រចាំឆ្នាំ ហើយលទ្ធភាពពង្រីកមុខដំណាំក៏មានកំរិតទាបដែរ ដោយសារឧបសគ្គខាងផ្នែកទីផ្សារ និងខាងផ្នែកផលិតកម្ម។ តារាងទី ៣ បង្ហាញអំពីផ្ទៃដីដាំដំណាំយុទ្ធសាស្ត្រចំបង១ប្រចាំរដូវ។

តារាងទី ៣: ផ្ទៃដីដាំដំណាំចំបងៗ (គិតជាពាន់ហិកតា)

| ប្រភេទដំណាំ | ១៩៩០ | ១៩៩១ | ១៩៩២ | ១៩៩៣ | ១៩៩៤ | ១៩៩៥ | ១៩៩៦ | ១៩៩៧ | ១៩៩៨ | ១៩៩៩ |
|---|---|---|---|---|---|---|---|---|---|---|
| ស្រូវ | ១.៨៩០ | ១.៩១០ | ១.៨៤៤ | ១.៨៩៧ | ១.៩២៤ | ២.០៨៦ | ២.១៥៣ | ២.០៧៦ | ២.១០៤ | ២.១៨ |
| ពោត | ៤៧ | ៥២ | ៥០ | ៤៣ | ៥២ | ៥២ | ៤៩ | ៤៩ | ៤៥ | ៦០ |
| ដំឡូងឈើ | ១១ | ១១ | ១០ | ១០ | ១១ | ១៤ | ១៤ | ១១ | ៩ | ១៤ |
| ដំឡូងផ្វា | ៨ | ៩ | ១០ | ៨ | ១១ | ១០ | ១១ | ៩ | ៩ | ៩ |
| បន្លែ | ៣០ | ៣៥ | ៣២ | ៣០ | ៣៥ | ៤២ | ៤៦ | ៣៦ | ២៣ | ៣១ |
| សណ្តែកបាយ | ២៨ | ៣០ | ២៨ | ២១ | ២៧ | ២៦ | ២៨ | ២៨ | ២៥ | ២៧ |
| អំពៅ | ៦ | ៦ | ៦ | ៧ | ៨ | ៩ | ៧ | ៨ | ៧ | ៨ |
| សណ្តែកសៀង | ១៥ | ១៤ | ១៦ | ២០ | ២៥ | ១៧ | ២៩ | ៣៣ | ៣១ | ៣៥ |
| សណ្តែកដី | ៤ | ៤ | ៤ | ៧ | ៨ | ១០ | ១២ | ១០ | ១០ | ១១ |
| ល្ង | ១០ | ១៦ | ១៤ | ១១ | ១១ | ៩ | ១២ | ១៦ | ១៥ | ១៦ |
| ថ្នាំជក់ | ១៦ | ១៧ | ១៨ | ៩ | ១៥ | ១៤ | ១៤ | ១៥ | ១៤ | ៨ |
| កៅស៊ូ | ៥៤ | ៥៣ | ៥២ | ៤៧ | ៤៣ | ៤៤ | ៤៤ | ៤៣ | ៤៣ | ៤០ |
| ក្រចៅ | ២ | ១ | ២ | ២ | ២ | ១ | ២ | ២ | ១ | ០ |
| សរុប | ២.១២១ | ២.១៥៨ | ២.០៨៦ | ២.០៧២ | ២.១៧២ | ២.៣៣៤ | ២.៤២១ | ២.៣៣៦ | ២.៣៣៦ | ២.៤៧ |

ប្រភព: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅក្នុងផែនការសេដ្ឋកិច្ចសង្គមប្រាំឆ្នាំលើកទីពីរ (RGC 2001)

ស្រូវឡើងទឹកមានដាំនៅទីទំនាបក្នុងតំបន់លិចទឹក។ មានផ្ទៃដីស្រែស្រូវឡើងទឹកទំហំប្រមាណ ១២០.០០០ ហិកតា ដែលតំណាងឱ្យ ៦.៦% នៃផ្ទៃដីស្រែក្នុងប្រទេសទាំងមូល។ ដំណាំស្រូវបែបនេះច្រើនតែមានធ្វើនៅក្នុងតំបន់ព្រៃលិចទឹកនៃតំបន់ទំនាបលិចទឹកបឹងទន្លេសាប។

ប្រាក់ចំណូលពីកសិកម្មមានកំរិតទាបខ្លាំងណាស់ សូម្បីតែកសិករដែលមានដីស្រែទំហំពីរហិកតាអាចទទួលប្រាក់ចំណេញដុលត្រឹមប្រមាណ ២៥០-៥០០ ដុល្លាប៉ុណ្ណោះក្នុងមួយឆ្នាំ[៣] (RGC 2001) ។ ប្រាក់ចំណេញនេះមានត្រឹមប្រមាណ ៣០ ទៅ ៦០% នៃប្រាក់ចំណូលចាំបាច់សំរាប់ទ្រទ្រង់តំរូវការជាមូលដ្ឋាននៃគ្រួសារនីមួយៗតែប៉ុណ្ណោះ។ សំរាប់មនុស្សម្នាក់ៗ អត្រាបរិភោគអង្ករត្រូវបានប៉ាន់ប្រមាណក្នុងកំរិត ១៦៥គ.ក/ឆ្នាំ (៤៣៨ក/ថ្ងៃ) (CIAP 1993) ។

[៣] ប្រាក់ចំណេញដុលស្មើនឹងប្រាក់ចំណូលដុល ដកប្រាក់ចំណាយ ដោយមិនគិតពីថ្លៃចំណាយកំលាំងពលកម្មដែលជាបន្ទុកក្នុងគ្រួសារ (RGC 2001)

ស្រូវរួមចំណែកត្រឹមតែ ៧៥% នៃថាមពលដែលមនុស្សម្នាក់ៗបានបរិភោគ (FAO 1994a) ហើយចំណែកក្រៅពីនេះ បានមកពី ពោត មើមឈើនានា ផ្លែឈើ និងបន្លែ ។

ការដាំដំណាំយុទ្ធសាស្ត្រច្រើនតែធ្វើឡើងនៅតាមច្រាំងទន្លេមេគង្គ លើកោះ និងក្នុងទំនាបលិចទឹកបឹងទន្លេសាប ជាកន្លែងមានដីល្បាប់ ជាពិសេសក្នុងខេត្តកំពង់ចាម និងខេត្តសៀមរាប។ វាលតូចៗជាច្រើនដែលកើតពីការរានឆ្ការព្រៃលិចទឹកតាមតំបន់នានាក្នុងទំនាបបឹងទន្លេសាប និងទន្លេមេគង្គ ក៏ត្រូវបានប្រើប្រាស់សំរាប់ដាំដំណាំយុទ្ធសាស្ត្រ និងធ្វើជាសួនបន្លែផងដែរ។

ដំណាំយុទ្ធសាស្ត្រក្នុងតំបន់ដីស្ងួតមានជាអាទិ៍ ពោត សណ្តែកបាយ សណ្តែកសៀង សណ្តែកដី ល្ង ថ្នាំជក់ អំពៅ ដំឡូងឈើ ដំឡូងជ្វា ល្ហុងប្រេង និងក្រចៅក្នុងបរិមាណតិចជាងគេ។ ដំណាំទាំងនេះត្រូវគេដាំនៅក្នុងទីវាលធំៗ ហៅថាចំការ ជាទូទៅក្រោមរូបភាពជាដំណាំឯកវប្បកម្ម។ ដំណាំផ្សេងទៀតដែលពុំសូវសំបូរ មានជាអាទិ៍ ល្ពៅ ត្រឡាច ត្រសក់ ឪឡឹក ប៉េងប៉ោះ ច្រើនតែមានដាំ នៅតាមចន្លោះដំណាំយុទ្ធសាស្ត្រខាងលើ ឬដាំនៅដោយឡែកតាមច្បារតូចៗ។ ដំណាំខ្លះៗប្រភេទនេះត្រូវការស្រោចទឹកជាដំបូងមុនពេលវាលូតលាស់ ចំណែកដំណាំខ្លះទៀតត្រូវការស្រោចទឹកត្រឹមម្តងតែប៉ុណ្ណោះ គឺនៅពេលដាក់ដាំ និងត្រូវការតែសំណើមដីតែប៉ុណ្ណោះដើម្បីដុះលូតលាស់បាន។ តារាងទី ៤ បង្ហាញពីផលិតផលដំណាំនានានៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០។

មានសារធាតុគីមីតិចតួចដែលត្រូវបានប្រើប្រាស់នៅក្នុងដំណាំស្រូវវស្សា ប៉ុន្តែមានការប្រើប្រាស់ជីគីមី និងថ្នាំសំលាប់សត្វល្អិតច្រើនជាងនៅក្នុងដំណាំស្រូវប្រាំង និងដំណាំផ្សេងទៀត ដើម្បីបង្កើនផលិតកម្ម និងដើម្បីទប់ស្កាត់ការបំផ្លិចបំផ្លាញដំណាំពីសំណាក់សត្វចង្រៃ។ Shams and Ahmed (1996) បានសង្កេតឃើញថា ការប្រើប្រាស់សារធាតុគីមីត្រឹមកំរិតតិចតួចក្នុងដំណាំស្រូវវស្សានៅក្នុងខេត្តពោធិសាត់ អាចឱ្យត្រី ក្តាម ខ្យង សិប្បិសត្វ និងកង្កែបអាចរស់នៅក្នុងស្រែបាន។ ទោះបីពុំទាន់ឃើញមានករណីបំពុលទឹកបណ្តាលពីការប្រើជីគីមី និង/ឬថ្នាំសំលាប់សត្វល្អិតក៏ដោយ មានសេចក្តីរាយការណ៍មួយចំនួនពីករណីពុលត្រីបានកើតឡើង ដែលអាចជាប់ទាក់ទងនឹងការប្រើប្រាស់ជីគីមីកសិកម្មមិនសមស្រប។ គំរោងរបស់វិទ្យាស្ថានអន្តរជាតិស្រាវជ្រាវដំណាំស្រូវកម្ពុជា-អូស្ត្រាលី បានសិក្សាអង្កេតកសិករធ្វើស្រែប្រាំងចំនួន ៤៨២គ្រួសារ និងបានរកឃើញថា៨០% នៃកសិករដែលបានសម្ភាស បានប្រើប្រាស់ថ្នាំសំលាប់សត្វចង្រៃ និង ៣៥% បានសង្កេតឃើញត្រីងាប់ក្រោយពីបានប្រើប្រាស់ថ្នាំទាំងនោះរួចមក (Gum 2001) ។ ថ្នាំគីមីកសិកម្មត្រូវបានគេរាយការណ៍ថាមានដាក់លក់ដោយគ្មានការត្រួតពិនិត្យនៅលើទីផ្សារក្នុងទីក្រុងភ្នំពេញ និងក្នុងខេត្តមួយចំនួន។ គេពុំឃើញមានរបាយការណ៍អំពីបរិមាណថ្នាំគីមីដែលកសិករបានប្រើប្រាស់ និងអំពីសំណល់ថ្នាំគីមីដែលបានបង្ហូរចោលពីដីកសិកម្មទៅក្នុងប្រព័ន្ធធម្មជាតិឡើយ ។ នេះជាប្រការអវិជ្ជមានបណ្តាលពីការប្រែប្រួលស្ថានភាពប្រើប្រាស់ដីដែលបានកើតឡើងនៅក្នុងរយៈពេលពីរ-បីឆ្នាំចុងក្រោយនេះ។

តារាងទី ៤: ផលិតផលប្រចាំឆ្នាំនៃដំណាំចំបងៗ (គិតជា ពាន់តោន)

| ប្រភេទដំណាំ | ១៩៩០ | ១៩៩១ | ១៩៩២ | ១៩៩៣ | ១៩៩៤ | ១៩៩៥ | ១៩៩៦ | ១៩៩៧ | ១៩៩៨ | ១៩៩៩ |
|---|---|---|---|---|---|---|---|---|---|---|
| ស្រូវ | ២.៥០០ | ២.៤០០ | ២.២២១ | ២.៣៨៣ | ២.២២៣ | ៣.៤៤៨ | ៣.៤៥៨ | ៣.៤១៥ | ៣.៥១០ | ៤.០៤១ |
| ពោត | ៨៨ | ៦០ | ៦០ | ៤៥ | ៤៥ | ៥៥ | ៦៥ | ៤២ | ៤៩ | ៩៥ |
| ដំឡូងឈើ | ៦០ | ៥៦ | ៨០ | ៥១ | ៦៥ | ៨២ | ៧០ | ៧៧ | ៦៧ | ២២៩ |
| ដំឡូងជ្វា | ៣១ | ៣៥ | ៦០ | ៤៨ | ៣៦ | ៣៩ | ៣៨ | ២៥ | ៣០ | ៣៣ |
| បន្លែ | ១៧០ | ២៤៥ | ២១០ | ២២១ | ១៩៧ | ១៩៣ | ២៥០ | ១៧៧ | ១២៨ | ១៨២ |
| សណ្ដែកបាយ | ១២ | ១៣ | ១៤ | ១១ | ១៧ | ២០ | ១៤ | ១៥ | ៩ | ១៦ |
| អំពៅ | ២៥៨ | ១៤៥ | ១៤២ | ១៤៥ | ២១៩ | ២០២ | ១៧១ | ១៨៨ | ១៣៣ | ១៦០ |
| សណ្ដែកសៀង | ២២ | ៣៥ | ៤០ | ៣៩ | ២៣ | ១៧ | ២៨ | ៥៦ | ២៨ | ៣៥ |
| សណ្ដែកដី | ៧ | ៨ | ៨ | ៩ | ៩ | ៧ | ៦ | ៧ | ៧ | ៩ |
| ល្ង | ៥ | ៨ | ៦ | ៥ | ៤ | ៤ | ៥ | ៣ | ៥ | ៧ |
| ថ្នាំជក់ | ៨ | ៩ | ៩ | ៥ | ១២ | ១១ | ១០ | ១០ | ១០ | ៦ |
| ក្រចៅ | ២ | ១ | ២ | ២ | ២ | ១ | ២ | ២ | ១ | ០ |

ប្រភព: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងផែនការសេដ្ឋកិច្ចសង្គមប្រាំឆ្នាំលើកទីពីរ (RGC 2001)

## ការនេសាទ និងផលនេសាទពីវាលស្រែ

ឧស្សាហកម្មនេសាទក្នុងដែននេសាទទឹកសាបគឺជាការប្រើប្រាស់តំបន់ដីសើមចំបងក្នុងប្រទេសកម្ពុជា ដោយសារវត្តមាននៃប្រព័ន្ធទន្លេ និងបឹងប្រកបដោយវិសាលភាពធំធេងដែលលិចទឹកជំនន់ជារៀងរាល់ឆ្នាំ។ ក្រៅពីដែននេសាទចំបង១គឺបឹងទន្លេសាប និងដងទន្លេមេគង្គ មានបឹងតូចធំជាច្រើនទៀតដែលស្ថិតនៅដាច់ដោយឡែកពីគ្នា ហើយក៏ជាកន្លែងនេសាទនៅរដូវប្រាំងផងដែរ។

បើប្រៀបធៀបនឹងដំណាំស្រូវ សកម្មភាពនេសាទបានការចូលរួមពីសំណាក់ក្រុមមនុស្សច្រើនជំពូកជាង។ ក្រុមទាំងនោះមានទាំងពពួកអ្នកមានជាងគេដែលកាន់កាប់ឡូតិ៍នេសាទ ក្រុមអ្នកមានបង្គួរដែលជួលដែននេសាទបន្តពីអ្នកកាន់កាប់ឡូតិ៍នេសាទ កសិករក្រដែលធ្វើនេសាទទៅតាមរដូវដើម្បីបំពេញបន្ថែមលើផលបានពីការធ្វើស្រែ និងក្រុមអ្នកក្រជាងគេដែលលក់កំលាំងពលកម្មទៅឱ្យក្រុមអ្នកមានជាងគេដើម្បីមានសិទ្ធិធ្វើនេសាទ។ ការពាក់ព័ន្ធនៃកំលាំងពលកម្មនៅក្នុងការនេសាទមានទ្រង់ទ្រាយធំធេងណាស់។ យោងតាម Ahmed et al. (1998) ៩២% នៃ ៥.១១៧ គ្រួសារដែលបានអង្កេតធ្វើនេសាទនៅក្នុងដែននេសាទសាធារណៈខាងក្រៅឡូតិ៍នេសាទ។ Thuok and Sina (1997) បានប៉ាន់ប្រមាណថា ៨៨% នៃប្រជាជនក្នុងភូមិចំនួន ១៧០នៅក្នុង និងជុំវិញទំនាបលិចទឹកបឹងទន្លេសាបពឹងផ្អែកលើការធ្វើនេសាទ និងសកម្មភាពពាក់ព័ន្ធ

និងការនេសាទ។ ក្នុងឃុំមួយនៅក្នុងនាទីព្រៃលិចទឹកនៃខេត្តសៀមរាប ដែលមានដីតិចតួចប៉ុណ្ណោះសំរាប់ធ្វើកសិកម្ម Thuok and Song (1999) បានប៉ាន់ប្រមាណថា ៦៧% នៃប្រជាជនទាំងអស់នៅទីនោះពឹងផ្អែកលើការនេសាទ។

ការនេសាទទ្រង់ទ្រាយធំ ឬតាមបែបពាណិជ្ជកម្មធ្វើឡើងនៅក្នុងឡូតិ៍នេសាទ ដោយជួលកំលាំងពលកម្ម ហើយតួលេខផ្លូវការបង្ហាញថាផលនេសាទជាមធ្យមបានពីការនេសាទជាលក្ខណៈពាណិជ្ជកម្មមាន ៧៣.០០០តោនក្នុងមួយឆ្នាំ។ ប៉ុន្តែផលនេសាទទឹកសាបសរុបត្រូវបានប៉ាន់ប្រមាណយ៉ាងហោចណាស់ពី ៣០០.០០០-៤៥០.០០០ តោនក្នុងមួយឆ្នាំ (Nao and Van Zalinge 2000)។ ការនេសាទឧស្សាហកម្មក្នុងឡូតិ៍នេសាទមានកាតព្វកិច្ចត្រូវបង់ថ្លៃឈ្នួលដែននេសាទ ចំណែកការនេសាទជាលក្ខណៈសិប្បកម្ម និងគ្រួសារអាចអនុវត្តដោយពុំបង់ថ្លៃឈ្នួលដែននេសាទឡើយ។

ទោះបីការនេសាទគឺជាសកម្មភាពសេដ្ឋកិច្ចនិងជាសកម្មភាពទ្រទ្រង់ជីវភាពរស់នៅសំខាន់បំផុតទីពីរ បន្ទាប់ពីវប្បកម្មស្រូវក៏ដោយ ប្រាក់ចំណូលបានពីមួយឯកត្តានៃកំលាំងពលកម្មក្នុងការធ្វើនេសាទមានកំរិតខ្ពស់ជាង។ ជាធម្មតា ការធ្វើនេសាទទ្រង់ទ្រាយតូចជាលក្ខណៈគ្រួសារគឺសំរាប់បរិភោគដោយខ្លួនឯង និងលក់ចំណែកដែលនៅសល់ ដើម្បីជួយបំពេញបន្ថែមលើប្រាក់ចំណូលបានពីការធ្វើកសិកម្ម។ អត្រាបរិភោគត្រីប្រចាំឆ្នាំត្រូវបានប៉ាន់ប្រមាណពី ៤៣.៥-៧៥.៦ គ.ក/ម្នាក់១ (Ahmed et al. 1999)។ ប្រជាជនប្រមាណ ២០.០០០ នាក់ដែលរស់នៅតាមដងទន្លេសេសានក្នុងខេត្តរតនគិរី ត្រូវបានរាយការណ៍ថាពឹងផ្អែកជាសំខាន់លើការនេសាទ និងប្រមូលពងសត្វស្លាប ល្ពៅ និងរុក្ខបន្លែនៅតាមដងទន្លេសំរាប់ធ្វើជាអាហារ និងឱសថ។ Azimi et al. (2000) បានកត់សំគាល់ថា ១៥% នៃចំនួនប្រជាជនកម្ពុជាទាំងអស់ពឹងផ្អែកលើផលនេសាទពីបឹងទន្លេសាបសំរាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេ។

ផលនេសាទក៏រួមវិភាគទានយ៉ាងសំខាន់នៅក្នុងប្រាក់ចំណូលជាថវិកាជាតិផងដែរ។ ដោយសន្មតថាផលនេសាទប្រចាំឆ្នាំមានពី ៣០០.០០០ ទៅ ៤៥០.០០០ តោន Degen et al. (2000)បានគណនាឃើញថា ប្រាក់ចំណូលពីផលនេសាទអាចបានពី១៥០លានទៅ២០០លានដុល្លាអាមេរិកក្នុងមួយឆ្នាំ។ Van Zalinge and Thuok (1999) បានសន្និដ្ឋានថាផលនេសាទសរុបដោយរួមទាំងផលពីការនេសាទជាលក្ខណៈពាណិជ្ជកម្ម និងពីការនេសាទជាលក្ខណៈគ្រួសារ សរុបមានច្រើនជាង ៥០០.០០០ តោនក្នុងមួយឆ្នាំ។ ដោយផ្អែកលើបរិមាណផលនេសាទ និងរបាយនៃផលនេសាទ ការនេសាទជាលក្ខណៈគ្រួសារក៏ត្រូវបានចាត់ទុកថាមានសារៈសំខាន់ដូចជាការនេសាទជាលក្ខណៈពាណិជ្ជកម្មដែរ។ មានការប៉ាន់ប្រមាណថា ៥០% នៃប្រជាជនទាំងអស់ក្នុងខេត្តស្ទឹងត្រែងពឹងផ្អែកលើត្រីសំរាប់ជាអាហារ និងប្រាក់ចំណូលបន្ថែមសំរាប់ទ្រទ្រង់ជីវភាពរស់នៅ (EWG 2000)។

ម្យ៉ាងវិញទៀត ផលនេសាទពីវាលស្រែបានផ្តល់ជាមធ្យោបាយទូទៅមួយសំរាប់បំពេញបន្ថែមលើរបបអាហាររបស់កសិករនៅជនបទ។ ប៉ុន្តែ គេពុំមានស្ថិតិអំពីទិន្នន័យទាំងនេះទេ ហើយការធ្វើសេចក្តីរាយការណ៍ជាលក្ខណៈប្រព័ន្ធអំពីផលនេសាទប្រចាំឆ្នាំបានពីវាលស្រែនានានៅទូទាំងប្រទេសក៏ជាប្រការលំបាកផងដែរ។ ការប្រមូលទិន្នន័យអំពីផលនេសាទពីវាលស្រែគឺជាការលំបាក។ ទិន្នន័យមួយចំនួនដែលមានបច្ចុប្បន្ននេះគឺបានមកពីគំរោងមួយចំនួន និងមានសំរាប់តែតំបន់មួយចំនួនតែប៉ុណ្ណោះ។ ទិន្នន័យទូទាំងប្រទេសអំពីផលនេសាទពីវាលស្រែបានតែពីការប៉ាន់ប្រមាណតែប៉ុណ្ណោះ។

ផ្អែកលើផ្ទៃដីស្រែសរុបទូទាំងប្រទេស ១.៨ លានហិកតា និងទិន្នផលនេសាទពីវាលស្រែប្រមាណ ៥០គ.កក្នុងមួយហិកតា ផលិតផលនេសាទសរុបប្រចាំឆ្នាំដែលអាចទទួលបានពីវាលស្រែអាចមានប្រមាណ ១០០.០០០ តោន។ តួលេខនេះខ្ពស់ជាងតួលេខផ្លូវការនៃផលនេសាទជាលក្ខណៈពាណិជ្ជកម្មដែលផ្តល់ដោយនាយកដ្ឋានជលផល (Gregory and Guttman 1999)។ ដោយសន្មតយកទិន្នន័យទាបបំផុតនៃផលនេសាទពីវាលស្រែត្រឹម ២៥គ.ក/ហិកតា/ឆ្នាំ ផលនេសាទសរុបពីប្រព័ន្ធវាលស្រែទៅទូទាំងប្រទេសអាចបានទទួលប្រមាណ ៤៣.៥០០តោនក្នុងមួយឆ្នាំ។ នេះជាបរិមាណដែលគ្រប់គ្រាន់សំរាប់បំពេញតំរូវការប្រូតេអ៊ីនប្រចាំឆ្នាំសំរាប់មនុស្ស ១.៣៥លាននាក់ (Gregory 1997) ។Gregory (1997) ក៏កត់សំគាល់ផងដែរថា ទោះបីត្រី និងវារីសត្វនានាមានសារៈសំខាន់ជាអាហារសំរាប់បណ្តាគ្រួសារកសិករក្តី អ្នកស្រាវជ្រាវនានាកំរធ្វើការសិក្សាអំពីសារៈសំខាន់នេះណាស់ ហើយបណ្តាក់រោងអភិវឌ្ឍន៍ជនបទនានាច្រើនតែមិនយកចិត្តទុកដាក់អំពីសារៈសំខាន់នេះ។ ទិន្នផលនេសាទពីវាលស្រែមានការប្រែប្រួលពីកន្លែងមួយទៅកន្លែងមួយ។ នៅក្នុងខេត្តកំពង់ធំ Shams and Hong (1998) បានសង្កេតឃើញថា ផលនេសាទពីវាលស្រែមានបរិមាណតិចឬច្រើន អាស្រ័យលើបរិមាណទឹកភ្លៀងធ្លាក់ និងទឹកជំនន់ ព្រមទាំងទទួលឥទ្ធិពលពីប្រភេទដី និងទំលាប់នៃការធ្វើស្រែផងដែរ។

ត្រីគឺជាផលិតផលចំបងនៃការនេសាទជាលក្ខណៈពាណិជ្ជកម្ម និងការនេសាទគ្រួសារ។ ប៉ុន្តែ វារីសត្វខ្លះៗមួយចំនួនដែលពុំសូវនេសាទបានចំនួនច្រើន និងដែលច្រើនតែនេសាទដោយអ្នកក្រ និងសំរាប់អ្នកក្រ មានជាអាទិ៍ សិប្បិសត្វ ក្តាម លេសពស់ អណ្តើក កំពិស អាពីង និងសត្វល្អិតដទៃទៀតផ្សេងៗទៀត។ មានសេចក្តីរាយការណ៍ថា មួយភាគបីនៃផលនេសាទពីវាលស្រែក្នុងខេត្តស្វាយរៀង ផ្សំដោយប្រភេទសត្វនានាក្រៅពីត្រី ដូចជា ក្តាម កំពិស និងកង្កែប (Gregory and Guttman, 1999) ។ បរិមាណផលនេសាទជាមធ្យមពីវាលស្រែមានប្រមាណ ៦៨១ គ.ក/គ្រួសារ/ឆ្នាំ ដែលក្នុងនោះ ១៨% ផ្សំដោយវារីសត្វក្រៅពីត្រី។ ផលនេសាទពីវាលស្រែមានតំលៃប្រមាណ ១០០ ដុល្លា/គ្រួសារ/ឆ្នាំ ដែលត្រូវជា ៤២% នៃតំលៃ មធ្យមសរុបនៃផលិតផលស្រូវក្នុងគ្រួសារនីមួយៗ ដែលបានសិក្សានៅក្នុងខេត្តស្វាយរៀង (Guttman 1999) ។

យោងតាម Gum (2001) ធនធានវារីជាតិដែលច្រើនតែជួបប្រទះនៅក្នុងវាលស្រែនិងប្រើប្រាស់ដោយគ្រួសារនានានៅជនបទ មានជាអាទិ៍ ត្រី ក្តាម ខ្យង អាពីង ត្រកួន ឈូក និងព្រលិត។ តារាងទី ៥ ខាងក្រោមបង្ហាញពីការប៉ាន់ប្រមាណអំពីការរួមវិភាគទាននៃផលនេសាទពីវាលស្រែ នៅក្នុងរបបអាហាររបស់ប្រជាពលរដ្ឋ។

**តារាងទី ៥: ការរួមវិភាគទាននៃផលនេសាទពីវាលស្រែនៅក្នុងរបបអាហារ**

| អត្រានៃការបរិភោគ (គ.ក/នាក់/ឆ្នាំ) | វិសាលភាព | ប្រភព (ដកស្រង់នៅក្នុង Touch Savy 1999) |
|---|---|---|
| ២០-២៥ | ទូទាំងប្រទេស | Largler 1976 |
| ១៣.៦-១៥.០ | ភាគអាគ្នេយ៍ | Tana 1993 |
| ៤២ | ភាគអាគ្នេយ៍ | Gregory et al. 1996 |
| ៤០ | ភាគទក្សិណ | CIAP Unpub. |
| ៣៨ | ភាគទក្សិណ | APHEDA 1997 |
| ៧៦ | សហគមន៍អ្នកនេសាទ | Ahmed et al. 1998 |

ប្រភព: (Touch Savy 1999)

## វារីវប្បកម្ម

ការច្រោះ និងបំប៉នត្រីមុនពេលលក់ ជាពិសេសនៅក្នុងរដូវបិទនេសាទគឺជាប្រពៃណីជាយូរអង្វែងក្នុងប្រទេសកម្ពុជា។ ប៉ុន្តែនៅពេលដែលធនធានក្នុងធម្មជាតិកាន់តែតិច និងខ្សត់ទៅ និងដោយសារវត្តមានបច្ចេកវិទ្យាវារីវប្បកម្ម ការធ្វើវារីវប្បកម្មក៏បានកើនឡើងគួរឱ្យកត់សំគាល់ផងដែរ។ Thuok and Sina (1997) បានកត់សំគាល់ថា ប្រមាណ ១០% នៃផលិតផលត្រីក្នុងប្រទេសកម្ពុជា បានទទួលពីវារីវប្បកម្ម ក្នុងនោះភាគច្រើនបានពីការចិញ្ចឹមក្នុងបែរនៅក្នុងបឹងទន្លេសាប។ អ្នកខ្លះទៀតចិញ្ចឹមវារីសត្វ ជាអាទិ៍ ក្រពើ អន្ទង់ កង្កែប បង្កង និងពស់ព្រលឹត។ វារីវប្បកម្មមានធ្វើឡើងនៅ ក្នុងអាងទឹកធម្មជាតិ ក្រោមរូបភាពជាបែរ ស៊ង ឬក្នុងស្រះ។ មានតែប្រភេទមួយចំនួនដែលមានតំលៃពាណិជ្ជកម្មតែប៉ុណ្ណោះ ដែលក្នុងនោះមានទាំងប្រភេទក្នុងស្រុក និងប្រភេទនាំចូលពីក្រៅប្រទេស ត្រូវបានដាក់ចិញ្ចឹមក្នុងបែរ រីឯប្រភេទក្នុងស្រុកដែលមិនសូវមានតំលៃពាណិជ្ជកម្មខ្ពស់ តែជាប្រភេទលូតលាស់រហ័សត្រូវបានជំរុញឱ្យចិញ្ចឹមនៅក្នុងស្រះ។

ប្រភេទក្នុងស្រុកដូចជា ត្រីរស់ និងត្រីឆ្តោ ព្រមទាំងប្រភេទត្រីមួយចំនួនផ្សេងទៀត ច្រើនតែមានដាក់ចិញ្ចឹមនៅក្នុងបែរ នៅតាមកន្លែងដែលមានទឹកហូរ។ នៅក្នុងការចិញ្ចឹមបែបនេះ ការដាក់ចិញ្ចឹមមានដង់ស៊ីតេខ្ពស់ និងផ្តល់ចំណីយ៉ាងច្រើនដែលមានប្រភពពីរុក្ខជាតិ និងពីសាច់។ ប្រជាជនមូលដ្ឋានបានកត់សំគាល់ អំពីការបំពុលទឹកមួយចំនួន និងកំនើនសារធាតុចិញ្ចឹមច្រើនហួសហេតុនៅតាមកន្លែងនានាមួយចំនួន តែពុំមានការផ្ទៀងផ្ទាត់ថាការបំពុលនោះកើតឡើងពីការប្រើប្រាស់ចំណីច្រើនហួសហេតុនៅក្នុងការចិញ្ចឹមត្រីក្នុងបែរឬយ៉ាងណានោះឡើយ។ ភាគច្រើននៃប្រព័ន្ធចិញ្ចឹមត្រីក្នុងបែរក្នុងបឹងទន្លេសាបបានបង្ហាញថាបានផ្តល់ផលចំណេញ។

ការចិញ្ចឹមត្រីក្នុងស្រះមានធ្វើឡើងនៅក្នុងស្រះជីក ភាគច្រើនស្ថិតនៅក្នុងខេត្តកណ្តាល និងក្នុងបណ្តាខេត្តមួយចំនួនផ្សេងទៀត ដែលស្ថិតនៅឆ្ងាយពីបឹងទន្លេសាប។ កាលពីប៉ុន្មានឆ្នាំកន្លងទៅមានការជំរុញការចិញ្ចឹមត្រីក្នុងស្រះជាទ្រង់ទ្រាយតូច ជាពិសេសក្នុងខេត្តស្វាយរៀង និងខេត្តតាកែវ តាមរយៈកិច្ចប្រឹងប្រែងរួមគ្នារវាងស្ថាប័នរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីធានាសិន្តិសុខស្បៀងនៃក្រុមជនក្រីក្រក្នុងមូលដ្ឋាន។ វារីវប្បកម្មក្នុងស្រះដោយប្រើប្រាស់ពូជប្លែកៗដែលមានតំលៃសេដ្ឋកិច្ចខ្ពស់ ដូចជាត្រីប្រា ត្រីអណ្តែងអាព្រិក និងត្រីកាប ច្រើនតែធ្វើឡើងដោយអ្នកជំនួញ រីឯប្រព័ន្ធវប្បកម្មច្រើនតែប្រើប្រាស់ត្រីប្រភេទក្នុងស្រុកដែលមានការលូតលាស់រហ័ស និងត្រូវការផ្តល់ចំណីតិចតួចត្រូវបានជំរុញក្នុងចំណោមប្រជាជនក្រីក្រនៅមូលដ្ឋាន។ ភាគច្រើននៃការចិញ្ចឹមត្រីក្នុងស្រះបានទទួលជោគជ័យនៅក្នុង តំបន់ដែលមិនសូវសំបូរដែននេសាទសាធារណៈ ដែលជាទូទៅប្រភេទត្រីចិញ្ចឹមទាំងនោះមានជាអាទិ៍ ត្រីទីឡាព្យា ត្រីកាប និង ត្រីប្រា។ ជាទូទៅ ស្រះត្រីត្រូវបានជីកនៅជិតប្រភពទឹក ឬនៅក្នុងតំបន់ដីសើម។ មិនដូចស្រះចិញ្ចឹមបង្គាដែលជីកនៅក្នុងព្រៃកោងកាងនៃតំបន់ឆ្នេរឡើយ គេមិនឃើញមានសេចក្តីរាយការណ៍អំពីកំនើនអត្រាសារធាតុចិញ្ចឹមហួសហេតុ និងការបំពុលទឹកក្នុងស្រះចិញ្ចឹមត្រីនៅក្នុងដែនទឹកសាបឡើយ។ តារាងទី៦ បង្ហាញពីផលិតផលវារីវប្បកម្មត្រី និងក្រពើប្រចាំឆ្នាំ នៅក្នុងតំបន់ សំខាន់ចំនួនបួនក្នុងប្រទេសកម្ពុជា។

តារាងទី ៦: ផលិតផលវារីវប្បកម្មទឹកសាប (ត្រីគិតជាតោន និងក្រពើគិតជាក្បាល)

| ឆ្នាំ | បឹងទន្លេសាប | | ទន្លេសាប | | ទន្លេមេគង្គខាងលើ | | ដីសណ្តទន្លេមេគង្គ |
|---|---|---|---|---|---|---|---|
| | ត្រី | ក្រពើ | ត្រី | ក្រពើ | ត្រី | ក្រពើ | ត្រី |
| ១៩៨៤ | ១៨១ | - | ១.១២៩ | - | ១២៤ | - | ១៤៨ |
| ១៩៨៥ | ១.៤៤៥ | - | ១.២៣៥ | - | ១៥១ | - | ៦៩ |
| ១៩៨៦ | ៧៥៨ | - | ១.២២៩ | - | ១៦០ | - | ៥៣ |
| ១៩៨៧ | ៨៨៦ | - | ១.៣៥២ | - | ២១០ | - | ៥១ |
| ១៩៨៨ | ១.៥០៥ | - | ២.១៣០ | - | ៣៤០ | - | ១២៥ |
| ១៩៨៩ | ២.៨៨៦ | ៤.៣៧២ | ២.០១៥ | - | ៣៣៨ | - | ១៨៩ |
| ១៩៩០ | ៣.៦៩៧ | ៥.៤៥៩ | ១.៩០៦ | ១៨៨ | ៤៣៩ | - | ២៦៥ |
| ១៩៩១ | ៣.៧៧៨ | ៥.៥៣០ | ១.៩៨៧ | ១៦៣ | ៥០៨ | - | ៣៩៧ |
| ១៩៩២ | ៤.៧៨៣ | ៣.៦០៧ | ៣.០០៦ | ៥០ | ១.០៣៣ | - | ២០៨ |
| ១៩៩៣ | ៤.៨៣៤ | ៤.៩៧៤ | ១.៧៥០ | ២៣៥ | ៤៦៣ | - | ៣០៨ |
| ១៩៩៤ | ៤.៦៩៩ | ៩.៨៨៤ | ២.២៨៦ | ២៣៥ | ៣២៥ | ៧៥ | ២៨០ |
| ១៩៩៥ | ៥.៣២២ | ១១.៤៨៦ | ២.១៤៨ | ៣.២០០ | ៦៣១ | - | ៥៥៨ |
| ១៩៩៦ | ៥.៣០៧ | ១៩.២៦៧ | ១.៤៥៩ | ៩៣៣ | ៥៨៩ | - | ៥៣៤ |
| ១៩៩៧ | ៧.៧៨៩ | ១៥.៩៧៦ | ២.៩០០ | ១.១៦៥ | ៥២៥ | ១២៩ | ៥៩០ |
| ១៩៩៨ | ៧.៦២០ | ៣៩.៩៤១ | ៣.៥៨៥ | ១.១០០ | ៥៧០ | ១០៩ | ៦៧៥ |
| ១៩៩៩ | ៨.៣៣០ | ២៣.២៦៧ | ៣.៨៣០ | ១.៤៥៣ | ៧៦៧ | ១១០ | ១.២១០ |
| ២០០០ | ៧.២៦៦ | ២៣.៣៨៤ | ៤.៤៣១ | ២.២៦១ | ១.០៥០ | ១១០ | ១.១៥៣ |
| ២០០១ | ៦.៩៦០ | ៣១.០០០ | ៤.០០០ | ៣.៤២០ | ១.៣៧០ | ១១០ | ១.៤៦០ |
| ២០០២ | ៦.៣៧៥ | ៤២.៤៦៨ | ៤.៩៥០ | ៦.៩០២ | ១.០៨០ | ១០ | ១.៨៨០ |

ប្រភព: ស្ថិតិនាយកដ្ឋានជលផល

## ការផ្គត់ផ្គង់ទឹក

ទឹកគឺជាធនធានដ៏សំខាន់ទាំងខាងផ្នែកសេដ្ឋកិច្ច និងសំរាប់ទ្រទ្រង់ជីវភាពគ្រួសារ។ ទីប្រជុំជនចំបង១ភាគច្រើនក្នុងប្រទេសកម្ពុជា ស្ថិតនៅតាមដងទន្លេ ឬនៅជិតអាងទឹក។ ក្រៅពីការប្រើប្រាស់សំរាប់ស្រោចស្រព និងសំរាប់ឧស្សាហកម្ម ទឹកត្រូវបានប្រើប្រាស់សំរាប់ផឹក លាងសំអាត និងងូត ក៏ដូចជាសំរាប់ការកំសាន្តផងដែរ។ ទឹកប្រើប្រាស់មានប្រភពពីអាងទឹកធម្មជាតិ អាងសិប្បនិម្មិត ស្រះ និងពីអណ្តូង។

ភាគច្រើននៃប្រជាជនដែលរស់នៅក្នុងភូមិបណ្តែតទឹកក្នុងបឹងទន្លេសាបប្រើប្រាស់ទឹកពីបឹងដោយផ្ទាល់ ចំណែកអ្នកដែលរស់នៅតាមដងទន្លេមេគង្គ និងទន្លេបាសាក់ប្រើប្រាស់ទឹកអណ្តូង ឬទឹកទន្លេ។ គ្រួសារជាច្រើននៅភាគអាគ្នេយ៍នៃប្រទេសកម្ពុជាតំកល់ទឹកទុកក្នុងស្រះ ឬអាងសំរាប់ប្រើប្រាស់ប្រចាំគ្រួសារនៅរដូវប្រាំង។ តារាងទី ៧ បង្ហាញពីវិសាលភាពនៃផ្ទៃដីស្រែស្រោចស្រពនៅតាមបណ្តាខេត្តជុំវិញបឹងទន្លេសាប។ យោងតាមក្រសួងធនធានទឹក និងឧតុនិយម(២០០២)ធនធានទឹកក្រោមដីក្នុងប្រទេសកម្ពុជាមាន ១៧.៦x១០$^{៩}$ ម$^{៣}$។ ដោយសារការពង្រីកប្រព័ន្ធស្រោចស្រពនៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ លទ្ធភាពប្រើប្រាស់ទឹកមានសភាពទូលំទូលាយជាងមុន។

**តារាងទី ៧: ផ្ទៃដីស្រែស្រោចស្រពក្នុងខេត្តមួយចំនួននៅជុំវិញបឹងទន្លេសាប**

| ខេត្ត | ផ្ទៃដីស្រោចស្រព (ហ.ត) |
|---|---|
| បន្ទាយមានជ័យ | ៣១.០០០ |
| បាត់ដំបង | ៤៦.០០០ |
| កំពង់ឆ្នាំង | ១៦.០០០ |
| កំពង់ធំ | ៣៧.០០០ |
| សៀមរាប | ១៣.៥០០ |

ប្រភព: MAFF, 1993 និង FAO, 1994a

## ការប្រមូលផល និងអនុផលព្រៃឈើ

តំបន់ដីសើមគឺជាប្រភពនៃផលិតផលរុក្ខជាតិជាច្រើនបែប គិតចាប់ពីផលិតផលឈើ ដល់អនុផលព្រៃឈើ។ ទោះបីព្រៃលិចទឹកមិនផ្តល់ឈើប្រកបដោយគុណភាពខ្ពស់ដូចប្រភេទឈើនៅលើដែនដីគោកក្តី ផលិតផលទាំងនោះត្រូវបានប្រើប្រាស់សំរាប់ការសាងសង់នៅមូលដ្ឋាន ជារោង និងផ្ទះតូច១។ ឈើត្រូវបានគេប្រើប្រាស់ជារចនាសម្ព័ន្ធសំរាប់ទ្រ ដូចជាសសរជន្ទល់ ចំណែកអនុផលព្រៃឈើ មានជាអាទិ៍ ឫស្សីត្រូវបានប្រើប្រាស់សំរាប់ជាក្បូន និងត្រែង ស្បូវ និងស្លឹកឈើដែលត្រូវបានប្រើប្រាស់សំរាប់ប្រក់ជាដំបូល។ រុក្ខជាតិពីព្រៃលិចទឹកត្រូវបានប្រើប្រាស់ដើម្បីផលិតឧបករណ៍នេសាទ និងជាសំភារសំរាប់ទាក់ទាញត្រី។ កំប្លោកក៏ត្រូវបានយកមកកែច្នៃជាអង្រឹង និងសំរាប់ជាថ្នាលសំរាប់បណ្តុះផ្សិត។ ប៉ុន្តែ គេនៅខ្វះទិន្នន័យអំពីបរិមាណផលិតផលទាំងនេះ និងអំពីអនុផលព្រៃឈើ ដូចជា ស្បូវ ត្រកួន ឈូក ព្រលិត អាពីង និង កន្ទាទូក។

ប្រជាជននៅជនបទក្នុងប្រទេសកម្ពុជាប្រើប្រាស់ឈើពីព្រៃលិចទឹកសំរាប់ដុតកំដៅ និងសំរាប់ដាំស្ល ជាពិសេសសំរាប់កែច្នៃត្រី (ឆ្អើរ)។ ជាសរុប ៨៦% នៃគ្រួសារនានានៅជនបទក្នុងប្រទេសកម្ពុជាប្រើប្រាស់អុស (NIS 1996 ដកស្រង់ដោយ

Nedeco and Midas 1998a)។ ក្នុងភូមិនានានៅបឹងទន្លេឆ្មារ អត្រានៃចំនួនគ្រួសារដែលឆ្អើរត្រីមានពី ២០% ទៅជិត ១០០%។ នៅបាឡុត មានសេចក្ដីរាយការណ៍ថា ការប្រើប្រាស់អុសពីព្រៃលិចទឹកជាមធ្យមសំរាប់គ្រួសារនីមួយៗមានរវាង ៣០-៤០ម[៣] (Mam and Sok 2001)។ ពួកគាត់ក៏បានកត់សំគាល់ផងដែរថា ប្រជាពលរដ្ឋក្នុងបឹងទន្លេសាបក៏ទិញអុសសំរាប់ឆ្អើរត្រីផងដែរ ដោយតំលៃ ២.៥០ – ៣.០០ ដុល្លា/ម[៣]។ Gum (1997) រាយការណ៍ថា ៧០-៨០% នៃអ្នកភូមិនៅតាមសីមា ខេត្តបាត់ដំបងកាប់អុសសំរាប់លក់ដោយអត្រាប្រមាណ០.៧ – ១.០ ម[៣]/ម្នាក់/ ថ្ងៃ។ គ្រួសារនីមួយៗក៏ត្រូវបានរាយការណ៍ផងដែរថា ប្រើប្រាស់អុសសំរាប់ការដាំស្ល អស់រវាង ៧ – ៨ម[៣] ក្នុងមួយឆ្នាំ។

ប្រជាជនពីតំបន់នានា ក្នុងប្រទេស ក៏ដូចជានៅក្នុងបណ្ដាប្រទេសជិតខាងដែរ ប្រើប្រាស់រុក្ខជាតិ និង សត្វពីតំបន់ដីសើម ក្នុងគិរិតផ្សេងៗ សំរាប់ប្រើប្រាស់ជាឱសថ។ អត្រានៃការប្រើប្រាស់បែបនោះអាស្រ័យជាបឋមលើលទ្ធភាពនៃការប្រើប្រាស់ ឱសថសម័យ និងទំលាប់ជាប្រពៃណីនៃការប្រើប្រាស់ឱសថបុរាណ។ ប្រជាជននៅតំបន់ដាច់ស្រយាលនៃផ្ទៃប្រទេសច្រើនតែពឹងផ្អែកលើឱសថបានពីរុក្ខជាតិ និងបំណែកសត្វព្រៃ (ពីតំបន់ដីសើមឬពីប្រព័ន្ធអេកូឡូស៊ីតំបន់ដីគោក)។ ឧទាហរណ៍: នៅខេត្តស្ទឹងត្រែង មានសេចក្ដីរាយការណ៍ថា មានការប្រើប្រាស់យ៉ាងទូលំទូលាយនូវរុក្ខជាតិពីតំបន់ដីសើមសំរាប់ជាឱសថ (Kuy Sea, personal comm.)។ នៅខេត្តតាកែវ អ្នកប្រើប្រាស់ចំបងនូវរុក្ខជាតិពីតំបន់ដីសើមសំរាប់គោលដៅជាឱសថគឺជនជាតិវៀតណាម។ ជាមធ្យម មានទូកចំនួន ១០០-១៥០ បានឆ្លងព្រំប្រទល់ដែនពីប្រទេសវៀតណាមមកក្នុងខេត្តតាកែវ ដែលភាគច្រើនមកប្រមូលផលិតផលពីតំបន់ដីសើម (Hang Try, pers. comm.)។

<u>ទេសចរណ៍ និងការកំសាន្ត</u>

ទីតាំងប្រកបដោយសក្ដានុពលជាតំបន់អេកូទេសចរណ៍ក្នុងបឹងទន្លេសាបមានជាអាទិ៍ ព្រែកទាល់ កំពង់ឃ្លាំង បឹងទន្លេឆ្មា ស្ទឹងសែន និងតំបន់នានានៅតាមដងទន្លេមេគង្គ ដូចជា ទីតាំងទស្សនាសត្វផ្សោតនៅកាំពីក្នុងខេត្តក្រចេះ និងនៅអន្លង់ឈើទាលក្នុងខេត្តស្ទឹងត្រែង (សូមអានប្រអប់ ៥)។ បច្ចុប្បន្ន បានប្រែក្លាយតំបន់ព្រែកទាល់ទៅជាគោលដៅទេសចរណ៍តំបន់ដីសើម ដែលនៅទីនោះអ្នកទេសចរអាចទស្សនាសត្វស្លាបទឹក ការចិញ្ចឹមក្រពើ និងការនេសាទរបស់ប្រជាជនមូលដ្ឋាន។

**ប្រអប់ទី ៥. សក្ដានុពលអេកូទេសចរណ៍ផ្សោតនៅអន្លង់ឈើទាល ខេត្តស្ទឹងត្រែង**

(ដោយ លោក គុយ ស៊ា និង ម៉ៅ ចាន់សាម៉ន)

នៅអន្លង់ឈើទាល មានអន្លង់មួយជំរៅប្រមាណ ២១ ម (នៅរដូវប្រាំង) ដែលមានទំហំប្រមាណ ១ ហ.ត។ នៅទីនោះមានសត្វផ្សោតប្រមាណ ៧-១៤ ក្បាលរស់នៅ។ កន្លែងនោះស្ថិតនៅក្នុងទន្លេមេគង្គភាគខាងក្នុងប្រទេសកម្ពុជាជាប់ព្រំដែនជាមួយប្រទេសឡាវ។ ភ្ញៀវទេសចរជាច្រើនពីប្រទេសឡាវ និងប្រទេសដទៃផ្សេងទៀត ឆ្លងកាត់ព្រំប្រទល់ប្រទេសឡាវចូលមកទស្សនាកន្លែងនោះ។ ភ្ញៀវទេសចរជិះទូកតូចៗឆ្លងកាត់ទន្លេ ហើយឈរនៅលើផ្ទាំងថ្ម ឬលើទូក រង់ចាំសង្កេតមើលសត្វផ្សោត ដែលភាគច្រើនអាចមើលឃើញក្នុងរវាងខែវិច្ឆិកា ដល់ខែ ឧសភា។ ជារៀងរាល់ថ្ងៃមានភ្ញៀវទេសចរប្រមាណ ១០ នាក់ជាមធ្យម ទស្សនាកន្លែងនោះ។ គេពុំដឹងទេថាតើភ្ញៀវទេសចរត្រូវបង់ថ្លៃដើម្បីចូលទស្សនាពីខាងប្រទេសឡាវឬទេ។ ប៉ុន្តែ ប៉ូលីសព្រំដែនក្នុងប្រទេសកម្ពុជាបានយកថ្លៃចូលទស្សនាក្រៅផ្លូវការក្នុងអត្រា ២០.០០០

រៀល (ប្រមាណ ៥ដុល្លារអាមេរិក) ក្នុងទូកនីមួយៗ។ ដោយសារផ្លូវចេញចូលលំបាក មានតែអ្នកស្រាវជ្រាវ និងមន្ត្រីរដ្ឋាភិបាល ដែលជាអ្នកភ្ញៀវចំបងចូលពីខាងប្រទេសកម្ពុជាមកទស្សនាកន្លែងនោះ ។

មានទីកំសាន្តនានាជាច្រើនផ្សេងទៀតក្នុងប្រទេសកម្ពុជា ដែលអាចពាក់ព័ន្ធ ឬ មិនពាក់ព័ន្ធជាមួយប្រាសាទបុរាណ ដែលជាសម្បត្តិវប្បធម៌ដ៏ល្បីល្បាញនៃប្រទេសកម្ពុជា។ នៅក្នុងដំណើរកំសាន្តពិចនិច ប្រជាពលរដ្ឋមូលដ្ឋានទំនងជាប្រើប្រាស់កាន់តែច្រើនឡើងនូវទីតាំងកំសាន្តដែលជាប់ពាក់ព័ន្ធជាមួយទឹក។ មាត់បឹង និងកន្លែងទឹកធ្លាក់ស្ថិតក្នុងចំណោមកន្លែងកំសាន្តពេញនិយមសម្រាប់អ្នកដើរកំសាន្តនៅចុងសប្តាហ៍។ ប្រជាពលរដ្ឋមូលដ្ឋានដែលអាចរកកំរៃបានពីទីកំសាន្ត និងពីសកម្មភាពអេកូទេសចរណ៍ក្នុងតំបន់ដីសើម មានជាអាទិ៍ អ្នកបើកបរទូក និងកាណូត អ្នកនាំភ្ញៀវក្នុងមូលដ្ឋាន អ្នកការពារ អ្នកលក់សំភារៈសិប្បកម្ម ភេសជ្ជៈ និងអាហារ។ ផលកំរៃផ្សេងទៀតអាចរកបានពីការសំដែងសិល្បៈ និងតន្ត្រីតាមបែបបុរាណ ការផ្តល់កន្លែងស្នាក់នៅដោយតំលៃទាប ប្រាក់កំរៃចូលទស្សនា និងថ្លៃរដ្ឋបាល និងប្រាក់ថ្លៃឈ្នួលផ្ទះសំណាក់ឯកជន។ Nedeco and Midas (1998) បានប៉ាន់ប្រមាណថ្លៃវិនិយោគដំបូង ១៦០.០០០ ដុល្លារអាមេរិក សំរាប់អភិវឌ្ឍន៍ទេសចរណ៍នៅព្រែកទាល់ ជាពិសេសសំរាប់ទូក និងការសាងសង់។ ផ្អែកលើនិន្នាការនៃចំនួនភ្ញៀវទេសចរបច្ចុប្បន្ន (ឆ្នាំ ១៩៩៨) នៅសៀមរាប និងសក្តានុពលនៅព្រែកទាល់ ពួកគេបានប្រមាណថាអាចរកប្រាក់ចំណូលដុលបាន ១ – ២ លានដុល្លារអាមេរិក នៅពេលគំរោងបែបនោះដំណើរការពេញលេញដែលក្នុងនោះអត្ថប្រយោជន៍សរុបជាចំណូលសំរាប់សហគមន៍មូលដ្ឋានមាន ក្នុងរវាង ១០០.០០០–២០០.០០០ ដុល្លារអាមេរិក ក្នុងមួយឆ្នាំ ។

មានសក្តានុពលជាច្រើនក្នុងផ្នែកទេសចរណ៍ធម្មជាតិ ជាពិសេសនៅតាមកន្លែងទឹកធ្លាក់។ នៅក្នុងខេត្តជាច្រើននៃប្រទេសកម្ពុជា មានតំបន់ដីសើមដែលគ្រប់គ្រងដោយឯកជនសំរាប់ជាកន្លែងសំរាប់កំសាន្ត។ ប្រការទាក់ទាញនៃតំបន់ដីសើមមានជាអាទិ៍ ការដើរស្វែងយល់ពីទីជនបទ ការសង្កេតសត្វព្រៃ ការនេសាទ ភូមិបណ្តែតទឹក ទីតាំងដែលមានព្រះវិហារនិងបុរាណវត្ថុ ទេសចរណ៍តាមដងទន្លេ ការសង្កេតសត្វស្លាប និងជិះក្បូន/ទូកកំសាន្តតាមកន្លែងមានទឹកជ្រៅ។ តំបន់ឆ្នេរភាគខាងកើត មានជាអាទិ៍ក្នុងក្រុងព្រះសីហនុ ខេត្តកំពត និងក្រុងកែប និងទីទាំងឡាយនៅជុំវិញនោះ សុទ្ធតែមានសក្តានុពលសំរាប់អភិវឌ្ឍន៍ជាឆ្នេរកំសាន្ត ការជិះទូកកំសាន្តទៅកោះនានា និងទេសចរណ៍ធម្មជាតិ។

## ការដឹកជញ្ជូនតាមផ្លូវទឹក និងការតាំងទីលំនៅ

ប្រព័ន្ធទន្លេខ្វាត់ខ្វែងនៅទូទាំងផ្ទៃប្រទេសផ្តល់ជាផ្លូវដឹកជញ្ជូនដ៏សំខាន់ សំរាប់បំពេញបន្ថែមចំពោះហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដែលភាគច្រើនខូចខាត និង/ឬមិនបានថែទាំជិតដល់។ ផ្លូវទឹកទាំងនោះមានសារៈសំខាន់ជាពិសេសសំរាប់កន្លែងណាដែលពុំមានការចេញចូលបានស្រួលតាមផ្លូវថ្នល់។ ការដឹកជញ្ជូនតាមផ្លូវទឹកមានសារៈសំខាន់ជាពិសេសនៅក្នុងតំបន់ខាងជើង និងឦសាននៃប្រទេសកម្ពុជា។ ទន្លេមេគង្គ និងទន្លេសាប (ទាំងដងទន្លេសាប និងបឹងទន្លេសាប) គឺជាផ្លូវទឹកពីរខ្សែចំបងក្នុងប្រទេសកម្ពុជា ដែលអាចផ្តល់ការធ្វើដំណើរពីទីក្រុងភ្នំពេញទៅបណ្តាខេត្តនៅឆ្ងាយៗ ដូចជា ខេត្តស្ទឹងត្រែង និងសៀមរាប។ ទឹកជំនន់ប្រចាំឆ្នាំក្នុងរដូវវស្សាអាចពង្រីកវិសាលភាពធ្វើដំណើរតាមផ្លូវទឹក។ យោងតាមក្រសួងសាធារណការ និងដឹកជញ្ជូន ប្រវែងផ្លូវទឹកដែលអាចដឹកជញ្ជូនបានមាន ៨៩៥គ.ម នៅរដូវប្រាំង និង ១.៥៤៤ គ.ម នៅរដូវប្រាំង។ ក្រៅពីផ្លូវដឹកជញ្ជូនពាណិជ្ជកម្មទាំងនេះ មានផ្ទៃទឹកខ្វាត់ខ្វែង និងផ្លូវទឹកតូចៗជាច្រើនទៀតដែលអាចឱ្យប្រជាពលរដ្ឋក្នុងមូលដ្ឋាន ប្រើប្រាស់ទូក

តូចៗ និងបរិក្ខារបណ្ដែតទឹកជាច្រើនបែប សំរាប់ធ្វើដំណើររវាងសហគមន៍នានា។ តារាងទី ៨ បង្ហាញពីចំនួន នាវាដែលបានចុះក្នុងបញ្ជី និងដែលប្រើប្រាស់ផ្លូវទឹកក្នុងប្រទេសកម្ពុជា។

តារាងទី ៨: ចំនួនទូក និងនាវាដែលបានចុះបញ្ជី និងធ្វើដំណើរក្នុងផ្លូវទឹកសាប

| *ប្រភេទនាវា* | ១៩៩៣ | ១៩៩៤ | ១៩៩៥ | ១៩៩៦ | ១៩៩៧ | ១៩៩៨ | ១៩៩៩ | ២០០០ |
|---|---|---|---|---|---|---|---|---|
| នាវាដឹកទំនិញស្ងួត | ២ | ១៨ | ៣៣ | ២៦ | ២៦ | ៤ | ៧ | ៧ |
| នាវាដឹកអ្នកដំណើរ ទំនិញ នាវាល្បឿន និងទេសចរ | ៣០ | ៣៩ | ៦៦ | ១៦ | ២៨ | ១២ | ១៣ | ១៥ |
| នាវាដឹកប្រេង | - | ៣ | ៩ | ១ | ៤ | ១ | - | ៣ |
| សាឡង់ | ១៥ | ៦ | ២៣ | ៧ | ១៩ | ៥ | ១៥ | ២ |
| ទូកសំរាប់ជាស្ពានចម្លង | ២០ | ១២ | ១៣ | ៧ | ១១ | ១៨ | ៥ | ២ |
| សាឡាង | ១ | ១ | ២ | ២ | ២ | - | - | - |
| ទូកសំរាប់សេវានានា | ៣ | ២ | ៥ | - | ២ | ៩ | ៤ | - |
| ទូកនេសាទ | ២៨.៤៨២ | ៣៧.៥២៨ | ៣៣.៤៧៦ | ៣៣.០៨៩ | ៣០.០៥៤ | ២៧.៦៣៧ | ២៥.៥៥៤ | ២៩.៨៨៨ |
| នាវាបរទេស | ៨៣ | ៣៧ | ១១ | ៣៣ | ១៥ | ១៤ | ១ | - |

ប្រភព: ទាំងអស់ ពីក្រសួងសាធារណការ និងដឹកជញ្ជូន (២០០០) លើកលែងទូកនេសាទ ពីស្ថិតិប្រចាំឆ្នាំរបស់នាយកដ្ឋានជលផល ។

ក្រៅពីការដឹកជញ្ជូន ទឹកក៏ជាកន្លែងសំរាប់ការតាំងទីលំនៅផងដែរ។ ទំលាប់បែបនេះមានឃើញជាទូទៅជាក្រុមនៅក្នុងបឹងទន្លេសាប ដែលនៅទីនោះប្រជាពលរដ្ឋកសាងលំនៅស្ថានរបស់ខ្លួនលើសសរជន្ទល់ដ៏ខ្ពស់ ឬនៅលើក្បូនបណ្ដែត រីឯបណ្ដុំតូចៗនៃផ្ទះបែបនេះក៏ឃើញមានផងដែរនៅតាមដងទន្លេមេគង្គ និងទន្លេបាសាក់។ ការតាំងទីលំនៅលើផ្ទៃទឹក អាចជាការតាំងលំនៅអចិន្ត្រៃយ៍ ឬប្រចាំរដូវ។ ប្រជាពលរដ្ឋខ្លះរស់នៅលើទូកតែមួយរយៈ ជាពិសេសនៅរដូវនេសាទ រហូតដល់ផុតរដូវនេសាទ។ នៅលើដងទន្លេមេគង្គ ការរស់នៅលើផ្ទៃទឹកមិនសូវមានជាទូទៅដូចនៅក្នុងបឹងទន្លេសាបទេ។

**<u>ការអភិរក្ស</u>**

យោងតាមព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើត និងកំនត់ប្រព័ន្ធតំបន់ការពារធម្មជាតិ បឹងទន្លេសាប និងទំនាបលិចទឹកជុំវិញបឹងនេះ (ទំហំ ៣១៦.២៥០ហ.ត) ត្រូវបានកំនត់ជាតំបន់ប្រើប្រាស់ច្រើនយ៉ាង ចំណែកតំបន់ភាគខាងលើនៃស្ទឹងសែន (ទំហំ ៤០២.៥០០ហ.ត) ត្រូវបានកំនត់ជាដែនជំរកសត្វព្រៃភ្នំគូលេន។ តំបន់រ៉ាមសារចំនួនបីកន្លែងត្រូវបានកំនត់ មានជាអាទិ៍ មួយកន្លែងនៅភាគខាងលើនៃដងទន្លេមេគង្គក្នុងខេត្តស្ទឹងត្រែង មួយកន្លែងក្នុងបឹងទន្លេសាប និងមួយកន្លែងផ្សេងទៀតនៅក្នុងតំបន់ឆ្នេរ។ អាងត្រពាំងថ្លុកជាកន្លែងដែលបានកំនត់នៅពេលថ្មីៗចុងក្រោយនេះជាដែនជំរកសត្វក្រៀល។

ព្រៃលិចទឹកក្នុងបឹងទន្លេសាប និងប្រព័ន្ធទំនាបលិចទឹកបឹងនេះបានត្រូវកំនត់ជាព្រៃដែលត្រូវការពារ និងជាបរិស្ថានជីវមណ្ឌល។ ការប្រើប្រាស់បែបនេះគឺដើម្បីការពារជីវចំរុះតំលៃខ្ពស់នៅក្នុងតំបន់នេះ សំរាប់ធានាផលិតភាព ថែរក្សាចំនួនសត្វក្នុងកំរិតដែលអាចបន្តពូជបាន និងធានាកិច្ចការពារទីជំរកនៅក្នុង និងក្រៅតំបន់ការពារធម្មជាតិនានា។ លើសពីនេះ មានត្រីលើសពី ៥០០ប្រភេទដែលបានកត់ត្រានៅក្នុងទន្លេមេគង្គនៃប្រទេសកម្ពុជា ក្នុងនោះត្រី ២១៥ប្រភេទ (FAO, 1994b) សត្វស្លាប ២២៥ ប្រភេទ និង សត្វល្មូនប្រមាណ ៤០ ប្រភេទ ត្រូវបានកត់ត្រាពីបឹងទន្លេសាប (NEDECO and MIDAS, 1998a) ។ មានរុក្ខជាតិព្រៃលិចទឹកប្រមាណ ២០០ ប្រភេទដែលបានកត់ត្រានៅក្នុងការអង្កេតរុក្ខជាតិដំបូងក្នុងបឹងទន្លេសាប (McDonald 1997) ។ ប្រអប់ទី ១០ បង្ហាញពីប្រភេទសត្វជិតផុតពូជដែលមានវត្តមាននៅក្នុងតំបន់ដីសើមប្រទេសកម្ពុជា និងដែលអាចទទួលប្រយោជន៍ពីកិច្ចប្រឹងប្រែងអភិរក្សក្នុងតំបន់នេះ។

**ប្រអប់ ទី ១០: ប្រភេទសត្វជិតផុតពូជក្នុងតំបន់ដីសើមប្រទេសកម្ពុជា (ប្រភព: MoE 1999)**

<u>ប្រភេទវារីសត្វ:</u>

| | |
|---|---|
| ផ្សោតទន្លេ Irrawaddy dolphin | (Orcaella brevirostris) |
| ផ្សោត Chinese white dolphin | (Sousa chinensis) |
| ក្រពើត្រី Siamese crocodile | (Crocodylus siamensis) |
| ត្រីរាជ Giant catfish | (Pangasianodon gigas) |
| ត្រីត្រសក់ Seven-line barb | (Probarbus jullieni) |

<u>សត្វស្លាបទឹក:</u>

| | |
|---|---|
| ទាព្រៃស្លាបស | (Cairina scutulata) |
| ក្រៀល | (Grus antigone) |
| ត្រយ៉ង | (Pseudibis gigantea) |
| ត្រយ៉ងខ្មៅ | (Pseudibis davisonii) |
| ត្រដក់ធំ | (Leptoptilos dubius) |
| ត្រដក់តូច | (Leptoptilos javanicus) |
| រនាលស | (Mycteria cinerea) |
| ទុងប្រផេះ | (Pelecanus philippensis) |

### *៥.២.២ មុខងារ និងតួនាទីផ្សេងៗទៀតនៃតំបន់ដីសើម*

<u>ការចិញ្ចឹមសត្វ</u>

ការចិញ្ចឹមសត្វគឺជាចំណែកដ៏សំខាន់នៃប្រព័ន្ធផលិតកម្មទ្រទ្រង់ដោយតំបន់ដីសើម។ សត្វគោ និងក្របីត្រូវបានចិញ្ចឹមសំរាប់ជាជំនួយកំលាំងពលកម្ម ដោយផ្តល់ស្មៅ ព្រមទាំងរុក្ខជាតិផ្សេងៗដែលដុះនៅក្នុងតំបន់ដីសើមជាអាហារ។ ទា និងក្ងានច្រើនតែត្រូវគេចិញ្ចឹមលែងនៅក្នុងវាលស្រែ។ ជ្រូក និងសត្វស្លាបផ្សេងទៀតស៊ីចំណីជាអនុផលកសិកម្ម ដែលដុះនៅក្នុងតំបន់ដីសើមដូចជា ត្រកួន ស្មៅ និងស្រូវ។ តារាងទី ៩ បង្ហាញពីផលិតផលប្រចាំឆ្នាំនៃសត្វចិញ្ចឹមនៅទសវត្សរ៍ឆ្នាំ ១៩៩០។ ប៉ុន្តែតារាងនេះពុំបានបង្ហាញថាតើសត្វទាំងនោះពឹងផ្អែកកំរិតណាលើធនធានពីតំបន់ដីសើម ឬពីតំបន់ដីគោកឡើយ។

តារាងទី ៩: ផលិតផលប្រចាំឆ្នាំនៃសត្វចិញ្ចឹម (គិតជាលានក្បាល)

| សត្វចិញ្ចឹម | ១៩៩០ | ១៩៩១ | ១៩៩២ | ១៩៩៣ | ១៩៩៤ | ១៩៩៥ | ១៩៩៦ | ១៩៩៧ | ១៩៩៨ | ១៩៩៩ |
|---|---|---|---|---|---|---|---|---|---|---|
| គោ | ២.២ | ២.៣ | ២.៥ | ២.៥ | ២.៦ | ២.៨ | ២.៨ | ២.៨ | ២.៧ | ២.៨ |
| ក្របី | ០.៧ | ០.៨ | ០.៨ | ០.៨ | ០.៨ | ០.៨ | ០.៧ | ០.៧ | ០.៧ | ០.៧ |
| ជ្រូក | ១.៥ | ១.៦ | ២.០ | ២.១ | ២.០ | ២.០ | ២.២ | ២.៤ | ២.៣ | ២.២ |
| សត្វស្លាប | ៨.២ | ៨.៨ | ៩.៩ | ១០.៧ | ១០.០ | ១០.១ | ១១.៤ | ១២.១ | ១៣.១ | ១៣.៤ |

ប្រភព: ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ 1990 - 2000

## ការរំលាយ និងប្រព្រឹត្តកម្មសំអាតសំណល់

ការប្រើប្រាស់តំបន់ដីសើមមួយបែបទៀតគឺសំរាប់រំលាយសារធាតុបំពុល និងរំលាយសំណល់មកពីប្រភពផ្សេងៗ ។ តំបន់ដីសើមផ្តល់ទឹកលើ និងក្រោមដីសំរាប់ការប្រើប្រាស់ដោយផ្ទាល់ផងដែរ ។ ក្នុងករណីដែលសំណល់ត្រូវបានបញ្ចេញចោលដោយគ្មានធ្វើប្រព្រឹត្តកម្មសំអាតជាមុន ដែលជាករណីក្នុងប្រទេសកម្ពុជា តំបន់ដីសើមដើរតួយ៉ាងសំខាន់ក្នុងការរំលាយ និងបំបាត់សារធាតុកខ្វក់ ។ ដោយសារប្រទេសកម្ពុជាស្ថិតនៅភាគខាងក្រោមនៃទន្លេមេគង្គ ប្រកបដោយទីប្រជុំជនភាគច្រើនតាំងនៅក្នុងទំនាបលិចទឹក និងពុំមានហេដ្ឋារចនាសម្ព័ន្ធសំរាប់សំអាតសំណល់រាវផងនោះ ការបង្ហូរសំណល់រាវត្រូវបានបញ្ចេញទៅទន្លេ ឬតំបន់ដីសើមដោយផ្ទាល់ ។ ឧទាហរណ៍: ភាគច្រើននៃសំណល់រាវពីទីក្រុងភ្នំពេញ និងពីទីរួមខេត្តតាកែវត្រូវបង្ហូរចោលទៅតំបន់ដីសើម ចំណែកទីរួមខេត្តសៀមរាបត្រូវបង្ហូរទៅក្នុងស្ទឹងសៀមរាប និងសំណល់ពីទីរួមខេត្តស្ទឹងត្រែងបង្ហូរចោលទៅក្នុងទន្លេសេកុង ។

លូទឹកសំអុយពីឧស្សាហកម្ម និងពីទីក្រុងគឺជាប្រភពចំបងនៃការបំពុល ហើយដោយសារពុំមានការធ្វើប្រព្រឹត្តកម្មសំអាតជាមុន មុនពេលសំណល់ទាំងនោះត្រូវបានបង្ហូរចោលទៅក្នុងអាងទឹកនានា ហើយតំបន់ដីសើមក៏ក្លាយជាមធ្យោបាយតែមួយគត់សំរាប់ធ្វើប្រព្រឹត្តកម្មសំអាតទឹកទាំងនោះ ។ ចំពោះភូមិបណ្តែតទឹកនានា ទាំងសំណល់រាវនិងសំណល់រឹងត្រូវបានបង្ហូរចោលនិង/ឬចាក់ចោលដោយផ្ទាល់ទៅក្នុងអាងទឹកនានាដោយពុំមានការជ្រើស ឬធ្វើប្រព្រឹត្តកម្មសំអាតជាមុនឡើយ ។ ជីគីមី និងថ្នាំសំលាប់សត្វចង្រៃដែលកំពុងត្រូវបានប្រើប្រាស់កាន់តែច្រើនឡើង ច្រើនតែបញ្ចប់នៅក្នុងតំបន់ដីសើមដែលនៅទីនោះបរិមាណមួយចំនួនត្រូវបានស្រូបដោយរុក្ខជាតិ និងផ្នែកដែលនៅសល់ពីនោះហូរតាមទឹកជំនន់ទៅទីនានា ។

## និយ័តកម្មលំហូរ និងទឹកជំនន់

អាងទឹកតូចៗជាច្រើននៅតាមទីនានាក៏ជួយធ្វើនិយ័តកម្មលំហូរទឹក ជាពិសេសទឹកបានពីភ្លៀង ។ នៅរដូវវស្សា បឹងទន្លេសាបស្រូបទឹកជំនន់ក្នុងបរិមាណដ៏ច្រើនដែលបានពីស្ទឹងនានានៅក្នុងទីជំរាលនៃបឹងនេះ និងពីទន្លេមេគង្គ ។ យោងតាម Carbonnel and Guiscafre (1962-63) ដែលបានដកស្រង់ក្នុង ORSTOM and BCEOM (1993) បរិមាណទឹកហូរប្រចាំឆ្នាំពីទីជំរាលបឹងទន្លេសាបមាន២៨.០x១០$^{៩}$ ម$^{៣}$ និងពីទន្លេមេគង្គមាន២៧.៩x១០$^{៩}$ ម$^{៣}$ ។ ជារៀងរាល់ឆ្នាំ មានទឹកប្រមាណ ៧៥x១០$^{៩}$ ម$^{៣}$ ហូរចេញពីអាងទន្លេមេគង្គនៃប្រទេសកម្ពុជាចូលទៅក្នុងស្ទឹងនានា និងតំបន់ដីសើមជាច្រើនប្រភេទ ។ អាងទឹកតូចជាច្រើន និងប្រព័ន្ធស្ទឹងនៅទូទាំងប្រទេសកម្ពុជាដើរតួក្នុងការជួយកាត់បន្ថយទឹកជំនន់នៅក្នុងមូលដ្ឋាន ដែលកើតឡើងបណ្តាលពីភ្លៀងធ្លាក់ខ្លាំងក្នុងប្រទេសនៅរដូវវស្សា ។

## របាំងខ្យល់ព្យុះ

ប្រជាពលរដ្ឋរស់នៅជុំវិញបឹងទន្លេសាប និងនៅតាមតំបន់ឆ្នេរតែងកោតសរសើរតួនាទីព្រៃលិចទឹក និងព្រៃកោងកាងក្នុងកិច្ចការពារលំនៅស្ថានរបស់ពួកគេ ពីខ្យល់ព្យុះ និងរលក ក៏ដូចជាក្នុងការរក្សាស្ថេរភាពខ្សែឆ្នេរផងដែរ។ ស្ថិតនៅក្រោមកំលាំងខ្យល់ព្យុះខ្លាំង ជាពិសេសនៅរដូវវស្សា ប្រជាពលរដ្ឋទាំងនេះតែងចល័តផ្ទះបណ្តែតទឹករបស់ខ្លួនទៅទីនៅជិតព្រៃលិចទឹកនៅក្នុងរដូវវស្សា ដើម្បីជៀសវាងពីខ្យល់ព្យុះ និងរលកធំៗ។

## ការផលិតថាមពល

ទោះបីមានកំនើននៃក្តីសង្ឃឹមលើសក្តានុពលនៃការផលិតថាមពលពីតំបន់ដីសើមក្នុងប្រទេសកម្ពុជាក្តី ភាគច្រើននៃប្រភពថាមពលពីតំបន់ដីសើមដែលកំពុងប្រើប្រាស់ក្នុងប្រទេសនេះ ច្រើនតែបានពីធនធានកើតឡើងវិញ ក្រោមរូបភាពជាអុស និងធ្យូង។ មានតែស្ថានីយ៍វារីអគ្គិសនីខ្នាតតូចមួយចំនួនតូចតែប៉ុណ្ណោះដែលបានកសាងរួចមកហើយនៅក្នុងប្រទេសនេះ។ សក្តានុពលសរុបនៃការអភិវឌ្ឍន៍ថាមពលក្នុងប្រទេសនេះមានប្រមាណ១០.០០០MW ក្នុងនោះមានសមត្ថភាពផលិតត្រឹមតែ ១៣MW តែប៉ុណ្ណោះដែលបានកសាងរួចមកហើយ។ សមត្ថភាពផលិតនេះមានជាអាទិ៍ នៅអូជុំ II (1MW) និងនៅគិរីរម្យ (12MW) ចំណែកសំណើវារីអគ្គិសនីនៅកំចាយកំពុងស្ថិតនៅក្នុងការសិក្សានៅឡើយ (MOWRAM, 2002)។

ប៉ុន្តែ ផលប៉ះពាល់ដែលអាចកើតឡើងធ្ងន់ធ្ងរ មិនអាចស្តារឡើងវិញបាន និងដែលកើតមានជាទូទៅបណ្តាលពីវារីអគ្គិសនីកំពុងក្លាយជាកង្វល់ដ៏សំខាន់។ ឧទាហរណ៍: ប្រជាពលរដ្ឋមូលដ្ឋាននៅតាមដងទន្លេសេសានក្នុងខេត្តរតនគិរី និងខេត្តស្ទឹងត្រែងបានរងគ្រោះដោយសារផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងសង្គមបណ្តាលពីការអភិវឌ្ឍន៍ និងការដាក់ឱ្យដំណើរការទំនប់វារីអគ្គិសនីទៅយ៉ាលីក្នុងប្រទេសវៀតណាម (សូមអានឯកសារនានា ដូចជា The Fisheries Office, Ratanakiri and NTFP, 2000)។

## ទិដ្ឋភាពសង្គម-វប្បធម៌នៃការប្រើប្រាស់តំបន់ដីសើម

ចំនងទាក់ទងរវាងវប្បធម៌-សង្គមនៃប្រជាពលរដ្ឋកម្ពុជាជាមួយតំបន់ដីសើម ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងពិធីបុណ្យប្រពៃណីខ្លះៗ។ ប្រជាពលរដ្ឋជាច្រើនមានទំនាក់ទំនងជិតស្និទ្ធជាមួយតំបន់ដីសើម ដោយសារការរស់នៅរបស់ខ្លួន ពឹងផ្អែកលើទឹក និងធនធានពីក្នុងទឹកសំរាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ខ្លួន។ ប្រជាពលរដ្ឋទាំងនេះបានផ្ទេរមរតកនៃជំនាញ និងទំលាប់ជាប្រពៃណីទាំងនេះជាបន្តបន្ទាប់ ឧទាហរណ៍ ពីរបៀបតស៊ូនិងការរស់នៅដោយការធ្វើនេសាទ រស់នៅលើផ្ទះបណ្តែតទឹកគ្រប់រដូវ និងដាំដំណាំនៅតាមមាត់ទឹក។ ពិធីជាប្រពៃណីខ្លះៗដែលបានរៀបចំឡើងមានជាអាទិ៍ បុណ្យអុំទូក ពិធីសែនព្រេននៅដើមរដូវនេសាទ និងនៅក្រោយពេលប្រមូលផល។

## ៥.៣ ការប្រើប្រាស់ និងតួនាទីតំបន់ដីសើមដែលមានសារៈសំខាន់បំផុតសំរាប់ជីវភាពរស់នៅរបស់ជនក្រីក្រ

ជនក្រីក្រ មានជាអាទិ៍បណ្តាអ្នកដែលពឹងផ្អែកជាបឋមលើតំបន់ដីសើម និងធនធានតំបន់ដីសើមសំរាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន។ ពួកគេច្រើនតែជាកសិករ ដែលធ្វើនេសាទផងដែរទៅតាមរដូវ ក្រោយពីប្រមូលផលដំណាំរួច និងពពួកអ្នកដែលរស់នៅជាអចិន្ត្រៃយ៍លើផ្ទៃទឹក និងដែលពឹងផ្អែកជាបឋមលើការនេសាទសំរាប់ទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ ដោយសារការយល់ដឹងនិងសមត្ថភាពខាងហិរញ្ញវត្ថុមានកំរិតទាបដើម្បីធ្វើការវិនិយោគលើការនេសាទ ក្រុមទាំងនេះ

ច្រើនតែមានលទ្ធភាពទាបនៅក្នុងការប្រើប្រាស់ធនធានភាគច្រើននៃតំបន់ដីសើម និងអាចទទួលប្រយោជន៍តែពីតួនាទីខ្លះៗនៃតំបន់ដីសើមតែប៉ុណ្ណោះ។ ប៉ុន្តែ តួនាទីខ្លះនៃតំបន់ដីសើម ដូចជា និយ័តកម្មទឹក រាំងការពារខ្យល់ព្យុះ ទីកសំរាប់ការចិញ្ចឹមត្រី និងការដឹកជញ្ជូនតាមផ្លូវទឹក អាចផ្តល់ប្រយោជន៍សំរាប់ប្រជាពលរដ្ឋទាំងអស់ដែលរស់នៅក្នុងស្ថានភាពបរិស្ថានដូចគ្នា។

ការប្រើប្រាស់ និងតួនាទីខ្លះៗដែលមានសារៈសំខាន់ចំពោះជនក្រីក្រ គឺបណ្តាការប្រើប្រាស់ និងតួនាទីដែលមានចំណងទាក់ទងដោយផ្ទាល់ជាមួយជីវភាពរស់នៅរបស់ពួកជនក្រីក្រ មានជាអាទិ៍ ការដាំដំណាំ ការនេសាទ និងការចិញ្ចឹមត្រី ការប្រមូលអនុផលព្រៃឈើ ការប្រើប្រាស់ទឹកក្នុងគ្រួសារ និងសំរាប់ស្រោចស្រព ការដឹកជញ្ជូនតាមផ្លូវទឹកក្នុងមូលដ្ឋាន ការតាំងទីលំនៅលើផ្ទៃទឹក និងការរំលាយសារធាតុបំពុល។

កសិករទទួលប្រយោជន៍ពីដីប្រកបដោយជីជាតិនៃតំបន់ដីសើមសំរាប់ការដាំស្រូវ និងសំរាប់ការធ្វើសួនបន្លែ។ ដោយសារផលិតផលកសិកម្មរបស់ពួកគេពុំគ្រប់គ្រាន់សំរាប់ការទទួលទានក្នុងគ្រួសារ ពួកគេច្រើនតែប្រកបរបរផ្សេងទៀតជាបន្ថែម ជាអាទិ៍ នេសាទ ចិញ្ចឹមត្រី បរបាញ់វារីសត្វ និងប្រមូលអនុផលព្រៃឈើ ដូចជាអុស និងបន្លែ សំរាប់បរិភោគដោយខ្លួនឯង និងសំរាប់លក់ផ្នែកដែលនៅសល់ដើម្បីយកប្រាក់ចំណូលបន្ថែមប្រចាំថ្ងៃ។

កសិករដែលដាំដំណាំនៅរដូវប្រាំងទទួលប្រយោជន៍ជាពិសេសពីការប្រើប្រាស់ទឹក និងសំណើមដីក្នុងតំបន់ដីសើម។ ជាធម្មតា ប្រជាពលរដ្ឋទាំងនេះមានចំណែកដីរបស់ខ្លួនស្ថិតនៅជិតមាត់ទឹក និងប្រើប្រាស់ទឹកដែលហូរលើផ្ទៃដី និងទឹកបូមសំរាប់ស្រោចស្រពដំណាំរបស់ពួកគេ។ តួនាទីតំបន់ដីសើម និងវារីរុក្ខជាតិនៅក្នុងការរំលាយ និងស្រូបសារធាតុបំពុលក៏មានសារៈសំខាន់ផងដែរចំពោះប្រជាពលរដ្ឋក្រីក្រ ដែលប្រើប្រាស់ទឹកដែលមិនបានធ្វើប្រព្រឹត្តកម្មសំអាតជាមុនសំរាប់ផឹក លាងសំអាត និងសំរាប់សកម្មភាពផ្សេងៗទៀតក្នុងគ្រួសារ។

ទោះបីការរស់នៅលើផ្ទៃទឹកត្រូវចំណាយខ្ពស់ជាងការរស់នៅលើដីគោកក៏ដោយ ជាទូទៅប្រជាពលរដ្ឋអាចតាំងទីលំនៅលើផ្ទៃទឹកដោយពុំចាំបាច់បង់ថ្លៃឡើយ។ ដោយប្រើប្រាស់ទូករបស់ខ្លួន និងសំភារៈបណ្តែតទឹកផ្សេងទៀត ជាទូទៅប្រជាពលរដ្ឋអាចប្តូរទីតាំងរបស់ខ្លួនដោយពុំចាំបាច់បង់ប្រាក់ឈ្នួលសំរាប់ទីតាំងដែលពួកគេតាំងលំនៅស្ថានឡើយ។ ទោះបីការតាំងលំនៅស្ថានបណ្តែតទឹកអាចងាយរងគ្រោះ ជាពិសេសនៅរដូវវស្សា ពេលដែលមានព្យុះភ្លៀងជាញឹកញាប់ក៏ដោយ ព្រៃលិចទឹកមាននាទីជារបាំងដ៏សំខាន់សំរាប់ការពារពួកគេពីគ្រោះមហន្តរាយទាំងនេះដែលគំរាមកំហែងដល់អាយុជីវិត។ តារាងទី ១០ បង្ហាញពីទស្សនៈចំពោះតំលៃនៃធនធានតំបន់ដីសើមនៅកន្លែងបីគឺ ព្រះរំកិលក្នុងខេត្តស្ទឹងត្រែង ចុងឃ្នាស ក្នុងខេត្តសៀមរាប និងអង្គរបុរីក្នុងខេត្តតាកែវ។

តារាងទី ១០: តំលៃនៃធនធានតំបន់ដីសើមក្នុងឃុំព្រះរំកិល ចុងឃ្នាស និងអង្គរបុរី

| ប្រភេទធនធាន | បរិមាណផលិតផល | | | តំលៃនៃការប្រើប្រាស់ដោយផ្ទាល់ | | | ចំនួនអ្នកប្រើប្រាស់ | | |
|---|---|---|---|---|---|---|---|---|---|
| | ព្រះរំកិល | ចុងឃ្នាស | អង្គរបុរី | ព្រះរំកិល | ចុងឃ្នាស | អង្គរបុរី | ព្រះរំកិល | ចុងឃ្នាស | អង្គរបុរី |
| ត្រីមានតំលៃមធ្យម | **** | **** | **** | **** | ** | **** | *** | **** | **** |
| ត្រីមានតំលៃទាប | **** | **** | ***** | **** | * | **** | **** | **** | **** |
| ខ្យង | **** | ** | *** | *** | * | *** | *** | *** | ** |
| ពស់ព្រលិត | ** | ** | * | ** | ** | **** | ** | * | ** |
| អណ្តើកទឹកសាប | ** | ** | * | *** | **** | **** | ** | * | ** |
| លាស | ** | ** | - | ** | * | - | * | *** | - |
| កំពិស | ** | *** | ** | * | *** | *** | ** | **** | *** |
| ក្តាម | **** | ** | ** | ** | ** | *** | *** | *** | *** |
| កង្កែប | **** | ** | - | ** | *** | - | ** | *** | - |
| អាពីង | - | ** | - | - | * | - | - | *** | - |
| សត្វស្លាបទឹក | ** | ** | * | - | *** | *** | - | ** | ** |
| ព្រលឹត | - | ** | *** | - | * | *** | - | * | ** |
| ត្រកួន | - | ** | *** | - | * | *** | - | * | ** |
| កំប្លោក | - | ** | - | - | * | - | - | * | - |
| ផ្លែព្រលិចទឹក និងបន្លែ | *** | **** | ** | ** | ** | *** | ** | **** | **** |
| ឫស្សី | - | * | - | - | *** | - | - | ** | - |

កំណត់សំគាល់ : ***** = ខ្ពស់ខ្លាំងណាស់ **** = ខ្ពស់ *** = មធ្យម ** = ទាប * = ទាបបំផុត - = មិនទាក់ទង

### ៥.៣.១ *តំលៃតំបន់ដីសើមដែលមានសារៈសំខាន់ចំពោះអ្នកប្រើប្រាស់ក្នុងមូលដ្ឋាន ប៉ុន្តែលំបាកសំដែងជាតំលៃសេដ្ឋកិច្ច និងមិនសូវមានការកោតសរសើរ*

តំលៃតំបន់ដីសើមដែលមានសារៈសំខាន់បំផុតចំពោះអ្នកប្រើប្រាស់ក្នុងមូលដ្ឋាន គឺបណ្តាតំលៃដែលពាក់ព័ន្ធនឹងជីវភាពរស់នៅ ការផ្តល់ប្រាក់ចំណូល និងសុខុមាលភាពរបស់ពួកគាត់ ។ ផ្នែកនានាខាងក្រោមនេះពិពិណនាអំពី តំលៃខ្លះៗដែលមានសារៈសំខាន់បំផុត និងដែលលំបាកបង្ហាញជាតំលៃសេដ្ឋកិច្ច ឬដែលមិនបានទទួលការកោតសរសើរពីបណ្តាអ្នកមានធនធាន និងបណ្តាអ្នកដែលមិនរស់នៅក្នុងតំបន់ដីសើម ។

<u>ផលិតផលសំរាប់ជីវភាពរស់នៅប្រចាំថ្ងៃ</u>

ប្រជាពលរដ្ឋជាច្រើននៅតាមជនបទក្នុងប្រទេសកម្ពុជារស់នៅដោយពឹងផ្អែកលើផលិតផលដែលពួកគេរកបាន ឬផលិតបានដោយខ្លួនឯង ។ ពួកអ្នកក្រីក្រច្រើនតែបរិភោគអ្វីដែលពួកគេរកបាននៅក្នុងថ្ងៃដដែលនោះ ។ ប្រជាពលរដ្ឋនៅជនបទក៏មានទំលាប់ចែករំលែកអាហាររវាងគ្នាផងដែរ ។ ជាលទ្ធផលយន្តការទីផ្សារមិនសូវតែមានដំណើរការល្អនោះទេ ដោយហេតុថាគេច្រើនតែពុំប្រើប្រាស់ទីផ្សារសំរាប់ធ្វើការផ្លាស់ប្តូរវត្ថុតូចតាចដែលមានតំលៃថោក និងដែលអាចរកបានដោយងាយនៅក្នុងមូលដ្ឋាននោះឡើយ ។ ជាញឹកញាប់ ប្រជាពលរដ្ឋជនបទចែករំលែកត្រី ឬបន្លែសំរាប់ការដាំស្លប្រចាំថ្ងៃ ដែលនេះជាទំលាប់មិនសូវកើតមានឡើយនៅក្នុងទីក្រុង ។ ជាធម្មតា ប្រជាពលរដ្ឋទិញគ្រឿងទេស ខ្លះៗ ដូចជាប៊ីចេង ស្ករ និងអំបិល ដែលជាវត្ថុលក់រាយនាំយកមកពីក្រៅសហគមន៍របស់ខ្លួនសំរាប់លក់ ប៉ុន្តែពួកគេពុំទំលាប់ទិញរបស់ដែលរកបាននៅក្នុងមូលដ្ឋានឡើយ ។ គ្រឿងទេសដែលពួកគេទិញអាចមានភាពខុសគ្នាខ្លះៗ ប៉ុន្តែមិនសូវតែមានតំលៃខ្ពស់ ឬមានកាឡូរី ឬបរិមាណប្រសើរជាងនៅក្នុងមុខម្ហូបដែលប្រជាពលរដ្ឋតែងតែចែករំលែករវាងគ្នានៅក្នុងសហគមន៍នោះឡើយ ។ ដោយសារបរិមាណសំរាប់ការបរិភោគប្រចាំថ្ងៃមានចំនួនតិច និងងាយរកបាន ការចែករំលែករវាងគ្នាមិនទំនងជានាំឱ្យមានបញ្ហាឡើយនៅក្នុងសហគមន៍បែបនេះ ។ ជួនកាលគ្រឿងទេសត្រូវបានគេដូរគ្នាជាមួយមុខម្ហូបដែលរកបាននៅក្នុងមូលដ្ឋាន ដែលច្រើនតែសមមូលនឹងបរិមាណដ៏ច្រើនជាងនៃវត្ថុរកបានក្នុងមូលដ្ឋាន ។

ហេតុនេះកត្តាចំបងដែលមានឥទ្ធិពលលើការឆ្លុះបញ្ចាំង ឬ កោតសរសើរអំពីតំលៃសេដ្ឋកិច្ចនៃផលិតផលពីតំបន់ដីសើមស្ថិតនៅត្រង់ប្រភេទ និងបរិមាណនៃវត្ថុទាំងនោះដែលអាចរកបាននៅក្នុងមូលដ្ឋាន ។ ដោយសារវត្ថុទាំងនេះជាច្រើនមិនធ្វើចរាចរចូលទៅក្នុងទីផ្សារ ជាញឹកញាប់គេពុំដឹងថ្លៃរបស់វាឡើយ ហេតុនេះប្រជាពលរដ្ឋមូលដ្ឋានពុំមើលឃើញវត្ថុទាំងនោះជាទឹកប្រាក់ឡើយ ។

<u>ការដឹកជញ្ជូនតាមផ្លូវទឹកក្នុងមូលដ្ឋាន</u>

គេពុំដឹងថាមានទូកតូចៗ និងទូកទំហំមធ្យមចំនួនប៉ុន្មានឡើយដែលមានប្រើប្រាស់នៅក្នុងមូលដ្ឋាន និងថាតើក្នុងមួយថ្ងៃទូកទាំងនោះធ្វើដំណើរបានចំងាយប៉ុន្មាននោះឡើយ ។ ដោយសារសំរាប់ប្រជាពលរដ្ឋក្រីក្រនៅជនបទ ការរស់នៅលើផ្ទៃទឹកបានក្លាយជាចំណែកមួយនៃជីវិតរបស់ពួកគេទៅហើយនោះ និងដោយហេតុថាស្ទើរតែរាល់ពេល កាលណាគេចេញពីផ្ទះ ពួកគេត្រូវប្រើប្រាស់ទូកជានិច្ច ប្រជាពលរដ្ឋមានទំលាប់បែបនេះ និងមិនយកចិត្តទុកដាក់ចំពោះការប្រើប្រាស់ទូកប្រចាំថ្ងៃនោះឡើយ ។

ដោយសារទូកភាគច្រើនត្រូវបានប្រើប្រាស់សំរាប់គោលដៅច្រើនយ៉ាង វាជាការឥតប្រយោជន៍ក្នុងការកត់ត្រាពីចំនួនផងដែលទូកនីមួយៗត្រូវបានប្រើប្រាស់នៅក្នុងសកម្មភាពសំរាប់គោលដៅទីទៃពីគ្នា។ ប្រជាពលរដ្ឋមានចំណាប់អារម្មណ៍ជាងលើការប្រើប្រាស់ទូករបស់ពួកគេដើម្បីចាប់ត្រីឱ្យបានច្រើន ឬដើម្បីដឹកសំណាបទៅស្រែឱ្យបានឆាប់តែប៉ុណ្ណោះ ជាងក្នុងការកត់ត្រាថាតើពួកគេបានប្រើប្រាស់ទូកប៉ុន្មានដងសំរាប់គោលបំណងខុសគ្នាណាមួយ។ ម្យ៉ាងវិញទៀត អ្នកបើកបរទូកដឹកអ្នកដំណើរ ឬដឹកអ្នកទេសចរអាចដឹងយ៉ាងច្បាស់ពីចំងាយ និងទីកន្លែងដែលពួកគេបានធ្វើដំណើរនៅក្នុងថ្ងៃនីមួយៗ ក៏ដូចជាពីចំនួនប្រាក់ដែលពួកគេរកបាន ឬចំណាយក្នុងការប្រើប្រាស់ទូក។ ប៉ុន្តែពួកគេកំរធ្វើការកត់ត្រាពីការធ្វើដំណើរទាំងនោះណាស់។

## ការតាំងលំនៅ

ទិដ្ឋភាពមួយផ្សេងទៀតនៃការប្រើប្រាស់តំបន់ដីសើមគឺសំរាប់ការតាំងទីលំនៅ។ ក្នុងពេលដែលតំបន់ដីសើមត្រូវបានចាត់ទុកថាជាសម្បត្តិរដ្ឋ ជាក់ស្តែងមានការប្រើប្រាស់ជាសាធារណៈដោយសេរី ព្រោះថាពុំមានការកំណត់ថ្លៃ ឬទីផ្សារសំរាប់តំបន់ដីសើមឡើយ។ លើកលែងតែក្នុងតំបន់ដែលគ្រប់គ្រងដោយឯកជនក្រោមរូបភាពជា ដីឯកជនរបស់រដ្ឋ ឬទីប្រជុំជនធំៗជាទូទៅការតាំងទីលំនៅក្នុងតំបន់ដីសើមមិនមានការបង់ថ្លៃឡើយ។ ទោះបី ជាទូទៅប្រជាពលរដ្ឋចល័តប្រចាំរដូវទៅកាន់ទីកន្លែងនានានៅក្នុងរង្វង់សហគមន៍របស់ខ្លួនក្តី អ្នកខ្លះតែងវិលត្រលប់មកកាន់កន្លែងដើមរបស់ខ្លួនវិញ ពួកគេគ្មានបំណងបង់ថ្លៃដើម្បីទទួលបានទីតាំងដដែលរបស់ខ្លួនវិញនោះឡើយ។ ប៉ុន្តែអ្នកជំនួញផលត្រី និងអ្នកលក់គ្រឿងទេសច្រើនតែមានបំណងក្នុងការបង់ថ្លៃដើម្បីទទួលបានទីតាំងយុទ្ធសាស្ត្រ សំរាប់តាំងលំនៅបណ្តោតទឹករបស់ខ្លួន ដើម្បីពួកគេមានលទ្ធភាពងាយស្រួលក្នុងការប្រកបមុខជំនួញរបស់ពួកគេ។ ហេតុនេះ លើកលែកតែប្រជាពលរដ្ឋអាចទទួលអត្ថប្រយោជន៍ដោយផ្ទាល់ពីការតាំងលំនៅក្នុងទីតាំងណាមួយជាក់លាក់ក្នុងតំបន់ដីសើម និងក្នុងពេលដែលមានការលំបាកដើម្បីចូលទៅកាន់កាប់ទីតាំងនោះ (ពោលគឺនៅពេលដែលពួកគេត្រូវបង់ថ្លៃដើម្បីមានសិទ្ធិកាន់កាប់) បើពុំនោះទេមនុស្សភាគច្រើនពុំទទួលស្គាល់ឬកោតសរសើរចំពោះតំលៃបែបនេះឡើយ ដែលនេះជាហេតុនាំឱ្យមានការលំបាកក្នុងការឆ្លុះបញ្ចាំង និងកំនត់បរិមាណនៃតំលៃទាំងនោះ។

## ការប្រើប្រាស់សំរាប់សួនបន្លែ និងការចិញ្ចឹមសត្វទ្រង់ទ្រាយតូច

ប្រជាពលរដ្ឋនៅជនបទភាគច្រើនមានសួនបន្លែមួយប្រចាំគ្រួសារសំរាប់ផ្គត់ផ្គង់ការហូបចុកក្នុងគ្រួសារ និងសំរាប់លក់យកប្រាក់បន្ថែមបន្តិចបន្តួច។ ដោយសារទីផ្សារក្នុងមូលដ្ឋានគ្មានដំណើរការល្អ និងគ្មានការគិតគូរ អំពីការចំណាយលើកំលាំងពលកម្ម គេមានការលំបាកដើម្បីឆ្លុះបញ្ចាំងអំពីតំលៃពិតប្រាកដនៃការប្រើប្រាស់បែបនេះគិតជាប្រាក់ តាមរយៈផលិតផលដែលពួកគេទទួលបាន។ ប៉ុន្តែជាទូទៅគ្រួសារនៅជនបទតែងមានសួនបន្លែដែលរួមវិភាគច្រើនយ៉ាងសំខាន់ចំពោះការហូបចុកក្នុងមូលដ្ឋាន។

ការបង្ហាញឱ្យឃើញតំលៃសេដ្ឋកិច្ចនៃតំបន់ដីសើមដែលបានពីការចិញ្ចឹមសត្វជាទ្រង់ទ្រាយតូច អាចពើបប្រទះនឹងការលំបាកខ្លាំងណាស់ដែរ ឧទាហរណ៍ នៅពេលដែលចាំបាច់ត្រូវបែងចែកឱ្យដាច់គ្នារវាងថាតើសត្វចិញ្ចឹមពឹងផ្អែក គឺរតណាលើតំបន់ដីសើម ឬលើបរិស្ថាននៃតំបន់ដីគោក។ កត្តាផ្សេងទៀតមានជាអាទិ៍ បរិមាណតិចតួចនៃផលិតផល និងកង្វះទីផ្សារដែលមានដំណើរការល្អ។

### ការផ្ដល់ជំរកសំរាប់វារីសត្វរកចំណី និងបន្តពូជ

តួនាទីសំខាន់មួយក្នុងចំណោមតួនាទីរបស់ព្រៃលិចទឹកគឺការផ្ដល់ទីជំរកសំរាប់ត្រី និងវារីសារពាង្គកាយនានារកចំណី និងបន្តពូជ។ ជាទូទៅ អ្នកនេសាទក្នុងមូលដ្ឋានអាចយល់ដឹងពីទំនាក់ទំនងរវាងវិសាលភាព និងគុណភាពព្រៃលិចទឹក ជាមួយផលិតភាពនៃដែនទឹក។ ពួកគេដឹងថាកាលពីមុនពួកគេធ្វើនេសាទបានទិន្នផលច្រើនជាង កាលដែលព្រៃលិចទឹកមិនសូវរិចរិល និងនៅមានវិសាលភាពធំធេងនៅឡើយ។

ប៉ុន្តែ ការវាស់វែងបញ្ជាក់ ឬកោតសរសើរអំពីតំលៃបែបនេះជាទិដ្ឋភាពសេដ្ឋកិច្ចពិតជាមានការលំបាក។ បច្ចុប្បន្ន នៅមានកង្វះការយល់ដឹងអំពីថាតើ នៅក្នុងប្រព័ន្ធមួយដែលរងឥទ្ធិពលពីកត្តាច្រើនខុសៗគ្នា ធម្មជាតិអាចផ្ដល់ផលិតភាពប៉ុន្មាន។ ការចល័តចុះឡើងនៃធនធានខ្លះៗនៅក្នុងទឹកគឺជាហេតុផលមួយផ្សេងទៀត ដែលនាំឱ្យមានការលំបាកបែងចែកដាច់គ្នារវាងអត្ថប្រយោជន៍នៅកន្លែងដើម និងអត្ថប្រយោជន៍នៅក្រៅកន្លែងដើម។

### របាំងការពារព្យុះ

ទោះបីឥទ្ធិពលនៃខ្យល់ព្យុះក្នុងប្រទេសកម្ពុជាគ្មានការិតធ្ងន់ធ្ងរដូចជាឥទ្ធិពលនៃទឹកជំនន់ក្ដី វាជាហានិភ័យការិតខ្ពស់សំរាប់ប្រជាពលរដ្ឋមូលដ្ឋាន ដែលរស់នៅក្នុងផ្ទះតូចៗដែលមិនរឹងមាំ សង់នៅក្នុងបឹងទន្លេសាប និងនៅតំបន់ឆ្នេរ។ តំបន់ដីសើមផ្ដល់កិច្ចការពារដ៏សំខាន់ចំពោះប្រជាពលរដ្ឋទាំងនោះ ដោយកាត់បន្ថយកំលាំងខ្យល់ព្យុះ និងរាំងស្កាត់សំណើកខ្សែឆ្នេរ។ អត្ថប្រយោជន៍បែបនេះក៏លំបាកវាយតំលៃខ្លាំងណាស់ដែរ ដោយហេតុថាបច្ចុប្បន្ន ពុំមានទីផ្សារសំរាប់កំនត់តំលៃសេវាបែបនេះឡើយ។

### ការរក្សានិរន្តរភាពជីជាតិដី

ទឹកជំនន់តែងនាំមកនូវកំណកកំទេចជាច្រើន ដែលធ្លាក់ចុះនៅក្នុងតំបន់ដីសើម ហើយដែលច្រើនតែត្រូវបានចាត់ទុកថាជាឥទ្ធិពលអវិជ្ជមាន។ ប៉ុន្តែ ការធ្លាក់ចុះនៃដីល្បាប់នៅក្នុងវាលស្រែត្រូវបានចាត់ទុកថាមានសារៈសំខាន់ណាស់ ដូចដែលបានឃើញតាមរយៈប្រឡាយទឹកជាច្រើន[៤] ដែលប្រជាពលរដ្ឋបានជីកនៅតាមដងទន្លេមេគង្គ និងទន្លេបាសាក់។ ឥទ្ធិពលនៃប្រឡាយនេះចំពោះកសិករមានទាំងវិជ្ជមាននិងអវិជ្ជមាន។ នៅពេលដែលកំណកកំទេច ជះឥទ្ធិពលនាំឱ្យសមត្ថភាពផ្ទុកទឹកនៅក្នុងអាងនានាសំរាប់ការស្រោចស្រពនៅរដូវប្រាំងត្រូវថយចុះ ការធ្លាក់ចុះនៃកំណកកំទេចទាំងនោះនៅក្នុងស្រែអាចជួយរក្សាជីជាតិដីស្រែ ដូច្នេះវាបង្កើនទិន្នផលស្រូវ និងកាត់បន្ថយការចំណាយទិញជី។

### តំលៃវប្បធម៌

ទំលាប់ជាប្រពៃណីខ្លះៗ ដូចជាបុណ្យអុំទូក និងការសែនព្រេននានានៅពេលចាប់ផ្ដើមរដូវនេសាទ ឬនៅក្រោយពេលប្រមូលផលរួច ត្រូវបានចាត់ទុកថាមានសារៈសំខាន់ និងមិនគួរមើលរំលងនោះឡើយ។ ទោះបីទំលាប់ទាំងនេះមានជាប់ពាក់ព័ន្ធជាមួយវដ្ដនៃការបង្កបង្កើនផលក្នុងតំបន់ដីសើមក្ដី គេលំបាកវាយតំលៃទំលាប់ទាំងនេះណាស់ ដោយសារពិបាកបង្ហាញឱ្យឃើញថាមានទំនាក់ទំនងជាក់ស្ដែងជាមួយកំនើនផលិតភាព។

---

[៤] ប្រឡាយទាំងនេះត្រូវបានជីកសំរាប់ជាផ្លូវទឹកនាំល្បាប់ទៅក្នុងដីស្រែរបស់ពួកគេនៅរដូវវស្សា។

*៥.៣.២ វិធីសាស្ត្រគួរទុកចិត្តបានសំរាប់វាយតំលៃសារៈសំខាន់នៃធនធានតំបន់ដីសើមចំពោះជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ*

វិធីសាស្ត្រវាយតំលៃដ៏ប្រសើរមួយគួរតែមានលទ្ធភាពឆ្លុះបញ្ចាំង និងកំនត់តំលៃនៃការប្រើប្រាស់ និងតួនាទីទាំងអស់ជាពិសេសការប្រើប្រាស់ និងតួនាទីដែលផ្តល់អត្ថប្រយោជន៍ចំពោះប្រជាពលរដ្ឋក្រីក្រ ដែលលំបាកឆ្លុះបញ្ចាំងជាតំលៃសេដ្ឋកិច្ច និងដែលមិនសូវបានទទួលការកោតសរសើរពីសំណាក់អ្នកប្រើប្រាស់នានា។ វិធីវាយតំលៃដែលប្រសើរអាចមិនចាំបាច់ទាមទារឱ្យមានការសំដែងតំលៃនៃការប្រើប្រាស់ និងតួនាទីទាំងអស់ជាទឹកប្រាក់ ប៉ុន្តែអាចជំនួសដោយតួលេខជាភាគរយនៃការរួមវិភាគទាននៃការប្រើប្រាស់ ឬតួនាទីទាំងនោះទៅក្នុងជីវភាពរស់នៅ ការរស់រានមានជីវិតឬសុខុមាលភាពនៃក្រុមអ្នកប្រើប្រាស់នៅមូលដ្ឋាន ឬក្រុមដ៏ធំនៃសង្គមមនុស្សទាំងមូល។ លើសពីនេះអាចកំនត់ជាមេគុណដើម្បីបំលែងប្រភេទនានានៃតំលៃទៅជាកត្តារួម ដើម្បីអាចធ្វើឱ្យចុះសំរុងគ្នានូវតំលៃនានាសំរាប់នៅថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ និងពិភពលោក។ ម្យ៉ាងវិញទៀតវិធីសាស្ត្រវាយតំលៃគួរតែអាចឆ្លុះបញ្ចាំងនូវតំលៃនៃធាតុនីមួយៗនៅក្នុងប្រព័ន្ធមួយ រួមទាំងធនធានចល័ត ក៏ដូចជាមានលទ្ធភាពសំដែងតំលៃនៃប្រព័ន្ធនោះជាតួលេខរួមមួយ ដោយពិចារណាផងដែរអំពីវិសាលភាពនៃប្រព័ន្ធនោះ ឧទាហរណ៍: នៅលំដាប់ទីជំរក ប្រព័ន្ធអេកូឡូស៊ី និងទីជំរាល។

## ៦. សេចក្តីសន្និដ្ឋានអំពីគោលនយោបាយ និងអនុសាសន៍

### ៦.១ សេចក្តីសន្និដ្ឋាន

*៦.១.១ ក្របខ័ណ្ឌស្ថាប័ន និងច្បាប់*

ភាពស្មុគស្មាញនៃការចាត់ចែងស្ថាប័នសំរាប់គ្រប់គ្រងតំបន់ដីសើមបានក្លាយជាឧបសគ្គក្នុងការសំរបសំរួលរវាងស្ថាប័ននានាដែលទទួលខុសត្រូវលើទិដ្ឋភាពផ្សេងៗនៃការគ្រប់គ្រងតំបន់ដីសើម។ កង្វះបទប្បញ្ញត្តិ និងការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាពបែបនេះបាននាំឱ្យមានទំនាស់រវាងអ្នកប្រើប្រាស់ធនធាន រវាងស្ថាប័នគ្រប់គ្រង និងរវាងប្រទេសនានា។

បច្ចុប្បន្ន ប្រទេសកម្ពុជានៅពុំទាន់មានយន្តការអន្តរស្ថាប័នក្នុងសំរបសំរួលក្នុងការកសាងផែនការ និងគ្រប់គ្រងតំបន់ដីសើមនៅថ្នាក់ជាតិនៅឡើយទេ។ ករណីលើកលែងតែមួយគឺ សំរាប់បរិវេណជីវៈមណ្ឌលបឹងទន្លេសាប ប៉ុន្តែយន្តការនេះមានសកម្មភាពសំរាប់តែតំបន់នេះមួយប៉ុណ្ណោះ។ ការសំរបសំរួលនៅថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋានរឹតតែនៅមានកំរិតទាបជាងនេះទៅទៀត ទោះបីនៅទីនោះមានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនកំពុងធ្វើការនៅទីនោះដើម្បីជំរុញការសំរបសំរួលអន្តរវិស័យនៅថ្នាក់ខេត្តក៏ដោយ។

ទោះបីមានកិច្ចប្រឹងប្រែងដើម្បីធ្វើវិមជ្ឈការអំណាចសំរាប់គ្រប់គ្រងតំបន់ដីសើមនៅថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋានក៏ដោយ ការសំរេចជាច្រើននៅតែធ្វើឡើងនៅតែថ្នាក់ជាតិនៅឡើយ។ ប្រការនេះនាំឱ្យមានការយឺតយ៉ាវ និងភាពមិនអាចបត់បែនបាននៅក្នុងចំណាត់វិធានការក្នុងការដោះស្រាយបញ្ហានៅថ្នាក់មូលដ្ឋាន។ ទោះបីសហគមន៍មូលដ្ឋានកំពុងត្រូវបានលើកទឹកចិត្តឱ្យចូលរួមច្រើនជាងមុន នៅក្នុងការគ្រប់គ្រងធនធានក្តី ពួកគាត់នៅតែពុំមានអំណាចនៅឡើយ ដោយសារពុំមានច្បាប់សំរាប់គាំទ្រសិទ្ធិអំណាចដើម្បីចូលរួមក្នុងការធ្វើសេចក្តីសំរេចពាក់ព័ន្ធនិងជីវភាពរស់នៅរបស់ពួកគាត់ ។

ក្របខ័ណ្ឌច្បាប់ទាក់ទងនឹងការគ្រប់គ្រងតំបន់ដីសើម មានមូលដ្ឋានលើច្បាប់នានាជាច្រើន ដែលចែងអំពីការប្រើប្រាស់ធនធាន (ច្បាប់ជលផលឆ្នាំ 1987) ការកសាងផែនការប្រើប្រាស់ដី (ច្បាប់ភូមិបាលឆ្នាំ 2001) និងការអភិរក្ស បរិស្ថាន (ច្បាប់បរិស្ថានឆ្នាំ 1996 ព្រះរាជក្រឹត្យស្តីពីការកំណត់តំបន់ការពារធម្មជាតិឆ្នាំ 1993) ។ វិធានការច្បាប់ដាច់ដោយឡែកពីគ្នាបែបនេះ ឆ្លុះបញ្ចាំងអំពីក្របខ័ណ្ឌស្ថាប័នស្មុគស្មាញ និងពុំបានផ្តល់មូលដ្ឋានច្បាប់ច្បាស់លាស់សំរាប់ការគ្រប់គ្រងតំបន់ដីសើមឱ្យបានពេញលេញ និងមានលក្ខណៈចំរុះឡើយ ។ ស្ថានភាពបែបនេះនាំឱ្យមានទំនាស់លើការប្រើប្រាស់ធនធាន ព្រមទាំងនាំឱ្យមូលដ្ឋានធនធានវិចរិល ។

សេចក្តីព្រាងផែនការសកម្មភាពតំបន់ដីសើម លើកឡើងអំពីចំណុចខ្វះខាតខាងផ្នែកស្ថាប័ន និងច្បាប់ទាំងនេះ ។ ប៉ុន្តែឯកសារនេះ ដែលបានឆ្លងកាត់ដំណាក់កាលជាច្រើននៃការពិនិត្យនិងកែសំរួលហើយក្តី គណៈរដ្ឋមន្ត្រីនៅតែពុំទាន់ផ្តល់ការអនុម័តលើឯកសារនេះនៅឡើយទេ ។

### ៦.១.២ *ការវាយតំលៃសេដ្ឋកិច្ចនៃតំបន់ដីសើម*

តំបន់ដីសើមផ្តល់នូវតំលៃជាច្រើនបែប ដែលតំលៃមួយចំនួនអាចឆ្លុះបញ្ចាំងយ៉ាងច្បាស់ជាងតំលៃដទៃទៀត ។ ការឱ្យតំលៃតំបន់ដីសើមមានលក្ខណៈលំបាក ដោយសារអ្នកពាក់ពន្ធ័នានា យល់ឃើញនិងចាប់អារម្មណ៍ខុសគ្នា អំពីតំបន់ដីសើម។ លើសពីនេះ ការយល់ដឹងអំពីមុខនាទីអេកូឡូស៊ីជាច្រើនរបស់តំបន់ដីសើម នៅមានកំរិតទាបនៅឡើយ ដូច្នេះនៅពេលធ្វើការវាយតំលៃ គេមិនអាចរាប់បញ្ចូលនូវតួនាទីសំខាន់ៗមួយចំនួនឡើយ ។ ការកំណត់មិនបានច្បាស់លាស់អំពីសិទ្ធិលើកម្មសិទ្ធិនិងក្របខ័ណ្ឌច្បាប់ ក៏ជះឥទ្ធិពលលើអាកប្បកិរិយារបស់មនុស្សចំពោះតំបន់ដីសើមផងដែរ និងចំពោះរបៀបនៃការឱ្យតំលៃតំបន់ដីសើម។ អាស្រ័យហេតុនេះ អ្នកធ្វើសេចក្តីសំរេចតែងមាននិន្នាការឱ្យតំលៃសេដ្ឋកិច្ចសរុបនៃតំបន់ដីសើមក្នុងកំរិតទាប ។

ភាគច្រើននៃទិន្នន័យមានស្រាប់ទាក់ទងការវាយតំលៃតំបន់ដីសើម ច្រើនមានតែអំពីការប្រើប្រាស់តំបន់ដីសើមដោយផ្ទាល់ ។ វិស័យនានាដែលពាក់ព័ន្ធជាងគេក្នុងការប្រើប្រាស់តំបន់ដីសើមនៅកម្ពុជា គឺវិស័យរកចំណូលសេដ្ឋកិច្ច រួមមានកសិកម្ម ជលផល វារីវប្បកម្ម ការផ្គត់ផ្គង់ទឹក ការប្រមូលផល និងអនុផលពីព្រៃឈើ ទេសចរណ៍ ការដឹកជញ្ជូនតាមផ្លូវទឹក និងការតាំងទីលំនៅ ព្រមទាំងការអភិរក្ស ។ ការប្រើប្រាស់និងមុខងារផ្សេងទៀតរបស់តំបន់ដីសើមមានជាអាទិ៍ វប្បកម្មសត្វពាហនៈ ការរំលាយនិងប្រព្រឹត្តកម្មសំអាតសំណល់ លំហូរ និងនិយ័តកម្មទឹកជំនន់ ការពារទល់និងខ្យល់ព្យុះ ផលិតកម្មថាមពល និងការប្រើប្រាស់ខាងផ្នែកសង្គម និងវប្បធម៌ ។

តំលៃនៃតំបន់ដីសើមដែលទាក់ទងនឹងជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសុខមាលភាពរបស់ជនក្រីក្រ ជាតំលៃដែលមានសារៈសំខាន់ជាពិសេស ព្រោះថាប្រជាពលរដ្ឋក្រីក្រជាច្រើនរស់នៅក្នុង និងជុំវិញតំបន់ដីសើម ហើយពឹងផ្អែកយ៉ាងខ្លាំងលើធនធានតំបន់ដីសើម សំរាប់ការចិញ្ចឹមជីវិតរបស់ពួកគាត់ ។ ប៉ុន្តែដោយសារហេតុផលមួយចំនួន តំលៃទាំងនេះច្រើនតែពុំសូវបានរាប់បញ្ចូលនៅក្នុងការវិភាគសេដ្ឋកិច្ចឡើយ ហេតុនេះគោលនយោបាយជាច្រើន ច្រើនតែមើលរំលងចំណុចទាំងនេះ។ ជាបឋម ធនធានជាច្រើនដែលប្រមូលពីតំបន់ដីសើម ពុំសូវបានចូលក្នុងចរន្តនៃសេដ្ឋកិច្ចទីផ្សារឡើយ ហេតុនេះវាជាការលំបាកដើម្បីកំណត់តំលៃជាទឹកប្រាក់ ។ ទីពីរ មុខងារជាច្រើនរបស់តំបន់ដីសើមមានភាពជិតស្និទ្ធបំផុត ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ហេតុនេះពួកគាត់ពុំសូវឱ្យតំលៃអំពីសារៈសំខាន់របស់វាឡើយ សូម្បីតែអ្នកដែលទទួលផលច្រើនបំផុតពី

មុខងារទាំងនោះក្តី ។ ទីបំផុត ការយល់ដឹងកំរិតទាប អំពីដំណើរការនៃមុខនាទីរបស់តំបន់ដីសើម គឺជាឧបសគ្គក្នុងការទទួលស្គាល់ពេញលេញនូវតំលៃរបស់តំបន់ដីសើម ។

ទិសដៅដែលគួរឱ្យទុកចិត្តបានមួយ ឈានរកទៅកំណត់វិធីសាស្ត្រ វាយតំលៃតំបន់ដីសើមឱ្យបានទូលំទូលាយជាងមុន គឺការសំដែងឱ្យឃើញនូវតំលៃទាំងនោះ ដោយមិនផ្អែកលើឯកត្តាជាទឹកប្រាក់នោះឡើយ ប៉ុន្តែ គឺការគិតជាភាគរយនៃការរួមវិភាគទានរបស់តំបន់ដីសើមចំពោះការចិញ្ចឹមជីវិតនៃក្រុមអ្នកប្រើប្រាស់ធនធាននៅក្នុងមូលដ្ឋាន ។ វិធីសាស្ត្រមួយសំរាប់វាយតំលៃគួរផ្តល់លទ្ធភាពបង្ហាញរាល់តំលៃនានា ដែលមាននៅក្នុងប្រព័ន្ធតំបន់ដីសើម ដោយរួមបញ្ចូលទាំងធនធានចល័ត និងនៅក្នុងកំរិតមាត្រដ្ឋានខុសគ្នា ។

## ៦.២ អនុសាសន៍

### *៦.២.១ ប្រកាន់យកយុទ្ធសាស្ត្រជាតិស៊ីសង្វាក់គ្នាសំរាប់គ្រប់គ្រងតំបន់ដីសើម*

- ផែនការសកម្មភាពតំបន់ដីសើមជាតិ គួរត្រូវបានអនុម័ត និងបានទទួលការឯកភាពពីស្ថានប័នទទួលខុសត្រូវនានា ដើម្បីឱ្យការគ្រប់គ្រងតំបន់ដីសើមប្រព្រឹត្តទៅប្រកបដោយការសម្របសម្រួល និងស៊ីសង្វាក់គ្នា ដែលទទួលស្គាល់តួនាទីសំខាន់របស់ស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងផ្នែកឯកជន ។ សកម្មភាពមួយដែលមានចែងនៅក្នុងផែនការនេះ គឺការតំរូវឱ្យបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងតំបន់ដីសើមដែលមានភារៈណែនាំការគ្រប់គ្រងធនធានតំបន់ដីសើម ទាំងនៅក្នុងតំបន់ឆ្នេរ និងដែនទឹកសាប និងដើម្បីកែលំអក្របខ័ណ្ឌច្បាប់ ។ ឯកសារផែនការសកម្មភាពនេះ ត្រូវបានរៀបចំជាសេចក្តីព្រាងជាច្រើនឆ្នាំរួចមកហើយ ប៉ុន្តែនៅពុំទាន់បានទទួលការអនុម័តដោយគណៈរដ្ឋមន្ត្រីនៅឡើយទេ។ កម្មវិធីអភិរក្សនិងប្រើប្រាស់ដោយនិរន្តភាពជីវចំរុះតំបន់ដីសើម ក្នុងអាងទន្លេមេគង្គ ក្រោមកិច្ចសហការជាមួយក្រសួងបរិស្ថាន កំពុងពិនិត្យនិងកែសំរួលសេចក្តីព្រាងផែនការនេះឡើងវិញ បន្ទាប់ពីនេះឯកសារនឹងត្រូវបញ្ជូនជាថ្មីម្តងទៀត ដើម្បីសុំការអនុម័តពីគណៈរដ្ឋមន្ត្រី ។ ប៉ុន្តែដោយសារសកម្មភាពជាច្រើនដែលចែងនៅក្នុងសេចក្តីព្រាងផែនការបច្ចុប្បន្នត្រូវបានអនុវត្តរួចមកហើយ ហេតុនេះចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពឯកសារនេះឡើងវិញ ។ បណ្តាសកម្មភាពទាំងនេះ ត្រូវលើកឡើងសំរាប់ការអនុវត្តដោយក្រសួងពាក់ព័ន្ធ ។ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធដទៃទៀត ត្រូវធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធ ដើម្បីដោះស្រាយបញ្ហានៃការប្រើប្រាស់ដោយនិរន្តរភាព និងការគ្រប់គ្រងធនធានតំបន់ដីសើមឱ្យបានប្រសើរជាងមុន ។

### *៦.២.២កែលំអក្របខ័ណ្ឌច្បាប់សំរាប់គាំទ្រវិធានការចំរុះគ្រប់គ្រងធនធានតំបន់ដីសើម*

- គោលការណ៍ណែនាំស្តីពីការអនុវត្តច្បាប់ គឺជាប្រការដែលត្រូវការចាំបាច់ដើម្បីលើកកំពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ។ ការយល់ដឹងសាធារណៈ គឺជាបញ្ហាគន្លឹះសំរាប់ជំរុញការយល់ដឹងអំពីច្បាប់ដែលដាក់ឱ្យប្រើថ្មីៗ នៅថ្នាក់ខេត្ត ស្រុក និងមូលដ្ឋាន ។ គោលការណ៍ណែនាំស្តីការបកស្រាយ និងការអនុវត្តមានសារៈសំខាន់ជាពិសេស សំរាប់ថ្នាក់មូលដ្ឋាន ដោយសហគមន៍មូលដ្ឋានច្រើនតែពុំសូវយល់អំពីរបៀបអនុវត្តច្បាប់ថ្មីៗ លើសពីនេះត្រូវរៀបចំផងដែរ នូវគោលការណ៍ណែនាំនៅថ្នាក់ជាតិ តាមរយៈការពិគ្រោះយោបល់ឱ្យបានទូលំទូលាយ

នៅក្នុង និងរវាងស្ថាប័នរដ្ឋាភិបាល ។ គោលការណ៍ណែនាំនេះ ត្រូវការជាចាំបាច់ដើម្បីបកស្រាយច្បាប់ស្តីពីជលផល និងជាពិសេសអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ដើម្បីជួយសហគមន៍មូលដ្ឋានអនុវត្តច្បាប់ទាំងនេះ។ គោលការណ៍ណែនាំនេះ គួរមានដាក់បញ្ចូលប្រការនានាដូចជា ការកំណត់ព្រំប្រទល់រវាងសហគមន៍នេសាទ និងឡូត៍នេសាទ ការសម្របសម្រួលនិងពិគ្រោះយោបល់រវាងអ្នកនេសាទពាណិជ្ជកម្ម និងអ្នកនេសាទខ្នាតតូច ឧបករណ៍នេសាទតូចតាចនៅក្នុងទីតាំងដាក់ឈ្លោក់ ផែនការគ្រប់គ្រងសំរាប់សហគមន៍នេសាទ និងសំរាប់ឡូត៍នេសាទ ។

- **វិមជ្ឈការ:** នៅឆ្នាំ១៩៩៦ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យអនុវត្តកម្មវិធីកែលំអសង្គម (សីលា) ដើម្បីណែនាំឱ្យអនុវត្តប្រព័ន្ធមួយទាក់ទងនឹងការកសាងផែនការ ហិរញ្ញប្បទាន ការគ្រប់គ្រងនិងអនុវត្ត ការងារអភិវឌ្ឍន៍មូលដ្ឋាននៅក្នុងខេត្ត។ ចាប់ពីពេលនោះមក កម្មវិធីសីលាត្រូវបានពង្រីកទៅតំបន់ជាច្រើនក្នុងផ្ទៃប្រទេស។ រដ្ឋាភិបាលបានប្តេជ្ញាប្រើប្រាស់វិធានការវិមជ្ឈការ និងវិសហមជ្ឈការដែលជំរុញឱ្យប្រជាជនចូលរួមក្នុងការរៀបចំ និងគ្រប់គ្រងធនធានធម្មជាតិ និងអភិវឌ្ឍន៍គំរោង ។ ការចូលរួមកើតមានឡើងតាមរយៈការផ្ទេរអំណាចទៅអាជ្ញាធរថ្នាក់ខេត្ត និងស្រុក និងទៅក្រុមប្រឹក្សាឃុំ ដែលស្ថិតនៅជិតប្រជាជនបំផុត ។ ដំណើរការបែបនេះអនុញ្ញាតឱ្យប្រជាជនមូលដ្ឋានធ្វើសេចក្តីសំរេចលើបញ្ហាពាក់ព័ន្ធនឹងការរស់នៅប្រចាំថ្ងៃរបស់ខ្លួន។ រដ្ឋាភិបាលសង្ឃឹមថានឹងដោះស្រាយបញ្ហានិងការគ្រប់គ្រងជលផលដោយ (i) កសាងគ្របខ័ណ្ឌច្បាប់ទូលំទូលាយដែលធានាការអភិរក្ស និងអភិវឌ្ឍន៍ដោយចីរភាព (ii) កសាងសមត្ថភាព និងពង្រឹងប្រសិទ្ធភាពរបស់នាយកដ្ឋានជលផល (iii) កាត់បន្ថយការធ្វើអាជីវកម្មធនធានហួសកំរិត និង (iv) កាត់បន្ថយទំនាស់ក្នុងការប្រើប្រាស់ធនធាន។ តាមរយៈការធ្វើវិមជ្ឈការ រដ្ឋាភិបាលអាចបង្កើនការយល់ដឹងអំពីតំបន់ដីសើមក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំ និងដាក់បញ្ចូលផែនការតំបន់ដីសើមទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ។ គណៈកម្មាធិការអភិវឌ្ឍន៍ឃុំ និងភូមិ គឺជាស្ថាប័នដែលមានស្រាប់ និងដែលអាចជួយបង្កើតសហគមន៍នេសាទបាន ។ វិមជ្ឈការបែបនេះនឹងជួយសំរួលឱ្យមានកិច្ចសហប្រតិបត្តិការជិតស្និទ្ធក្នុងចំណោមអាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាលនៅមូលដ្ឋាននិងកម្មវិធីសីលា ព្រមទាំងរួមចំណែកក្នុងការគ្រប់គ្រងធនធានតំបន់ដីសើមឱ្យបានប្រសើរជាងមុន និងកាត់បន្ថយទំនាស់នៃការប្រើប្រាស់ធនធានតំបន់ដីសើម ។

- **ការវាយតំលៃឥទ្ធិពលនៃកំណែទំរង់ក្នុងវិស័យជលផលដើម្បីកែលំអការអនុវត្តគោលនយោបាយ:** នាយកដ្ឋានជលផលបាននិងកំពុងពិនិត្យឡើងវិញអំពីឥទ្ធិពលនៃកំណែទំរង់គោលនយោបាយក្នុងប្រទេសកម្ពុជា ។ គំរោងនេះបានទទួលការគាំទ្រពីនាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិរបស់ចក្រភពអង់គ្លេស (DFID) និងអង្គការអុកស្វាម។ លទ្ធផលនៃការពិនិត្យឡើងវិញនេះ អាចយកទៅប្រើប្រាស់ដើម្បីកែលំអសេចក្តីព្រាងច្បាប់ស្តីពីជលផល និងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ។ អនុសាសន៍នានាបានពីការពិនិត្យឡើងវិញនេះ អាចយកទៅដាក់បញ្ចូលនៅក្នុងគោលនយោបាយ ដើម្បីពង្រឹងឱកាសអនុវត្តការប្រើប្រាស់ធនធានតំបន់ដីសើមឱ្យមាននិរន្តរភាព ។

- ទទួលស្គាល់និងការពារសិទ្ធិជាលក្ខណៈប្រពៃណីរបស់សហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់ធនធានតំបន់ដីសើម លើកលែងតែឡូត៍នេសាទ រាល់ការផ្តល់ព្រៃសម្បទាន និងដីសម្បទានស្ថិតនៅក្រោមអំណាចនៃការធ្វើសេចក្តីសំរេចតាមបែបបញ្ជាពីលើចុះក្រោម ។ សេចក្តីសំរេចបែបនេះ ធ្វើឡើងដោយពុំមានការពិគ្រោះយោបល់ជាមួយអាជ្ញាធរ និងសហគមន៍មូលដ្ឋានឡើយ ទោះបីផលប៉ះពាល់ចំពោះជីវភាពរស់នៅក្នុងមូលដ្ឋាន និងចំពោះសិទ្ធិតាមបែបប្រពៃណីនៃការប្រើប្រាស់ធនធានទាំងនេះ មានកំរិតធ្ងន់ធ្ងរក៏ដោយ ។ ឧទាហរណ៍ ការសាងសង់ទំនប់វារីអគ្គិសនីនៅលើទន្លេសេសាន បានធ្វើឱ្យការប្រែប្រួលជីវភាពរស់នៅសព្វថ្ងៃ របស់ជនជាតិដើមភាគតិចនៅតាមដងទន្លេសេសាន ដោយសារទំនប់នេះបានធ្វើឱ្យផ្លាស់ប្តូររបបទឹក។ ការបំលែងព្រៃលិចទឹកទៅជាដីកសិកម្ម ក៏នាំឱ្យមានផលប៉ះពាល់លើទំលាប់ប្រើប្រាស់ធនធានតំបន់ដីសើមជាលក្ខណៈប្រពៃណីផងដែរ។ ឧទាហរណ៍ នៅខេត្តស្វាយរៀង នៅកន្លែងដែលមានការកាប់ឆ្ការព្រៃស្មាច់ដើម្បីធ្វើស្រែ ប្រជាជនពុំអាចចាប់កង្កែប ខ្យង រកបន្លែ និងផ្សិត សំរាប់ធ្វើជាអាហារ ដូចដែលគេធ្លាប់ប្រព្រឹត្តពីមុននោះឡើយ ហើយលទ្ធភាពនៃការរកប្រាក់ចំណូលជាតិឱសថក៏ត្រូវបាត់បង់ដែរ ។ វប្បធម៌នៃការប្រមូលផលទាំងនេះ ក៏លែងមានតទៅទៀតដែរ ។

- ការរួមបញ្ចូលអំពីការវាយតំលៃសេដ្ឋកិច្ចនៃធនធានតំបន់ដីសើមទៅក្នុងគោលនយោបាយ លទ្ធផលនៃការវាយតំលៃសេដ្ឋកិច្ចនៃធនធានតំបន់ដីសើម ធ្វើឡើងដោយកម្មវិធីអភិរក្ស និងប្រើប្រាស់ជីវចំរុះតំបន់ដីសើមក្នុងអាងទន្លេមេគង្គ អាចរួមចំណែកកសាងចំណេះដឹងរបស់អ្នករៀបចំគោលនយោបាយ និងរួមវិភាគទានក្នុងការកសាងគោលនយោបាយ ។ ទង្វើបែបនេះ នឹងផ្តល់ការលើកទឹកចិត្ត ឱ្យមានការផ្លាស់ប្តូរពីរបៀបប្រើប្រាស់ដែលគ្មាននិរន្តរភាព ឆ្ពោះទៅការប្រើប្រាស់ធនធានតំបន់ដីសើមដោយឈ្លាសវៃនិងអាចរួមវិភាគទានក្នុងការសំរេចគោលដៅរួមនៃគោលនយោបាយកាត់បន្ថយភាពក្រីក្រ ។

### ៦.២.៣ កែលំអការចែករំលែកការទទួលខុសត្រូវក្នុងចំណោមស្ថាប័នរដ្ឋាភិបាល

- យន្តការសម្របសម្រួលអន្តរក្រសួង នៅថ្នាក់ជាតិគួរត្រូវបានកែលំអ និងសំរួលឱ្យមានការពិគ្រោះយោបល់រវាងក្រសួងនានា ស្តីពីការអភិវឌ្ឍន៍ និងការអនុវត្តគោលនយោបាយ និងបទប្បញ្ញត្តិទាក់ទងនឹងតំបន់ដីសើម។

- គណៈកម្មការជាន់ខ្ពស់មួយ គួរធ្វើការវាយតំលៃនិងដោះស្រាយភាពត្រួតគ្នានៃអាណត្តិរបស់ស្ថាប័ននានា ក្នុងរដ្ឋាភិបាល ។ គណៈរដ្ឋមន្ត្រី គឺជាស្ថាប័នសមស្របបំផុត ដើម្បីចាត់ចែងឱ្យមានការជជែកវែកញែកអន្តរក្រសួងអំពីសេចក្តីព្រាងច្បាប់ និងអនុក្រឹត្យដែលជាប់ពាក់ព័ន្ធជាមួយបញ្ហាត្រួតគ្នានៃតួនាទី និងការទទួលខុសត្រូវ ។ គោលដៅនេះ គឺជំរុញការសម្របសម្រួលរវាងភាពទទួលខុសត្រូវសំរាប់គ្រប់គ្រង និងប្រើប្រាស់ធនធានតំបន់ដីសើមឱ្យមាននិរន្តរភាព ។ សព្វថ្ងៃនេះ និងក្នុងករណីជាច្រើន ដំណើរការពិគ្រោះយោបល់បានធ្វើឡើងគ្រាន់តែដើម្បីបំពេញទំរង់ជាផ្លូវការតែប៉ុណ្ណោះ ហើយយោបល់និងសំណូមពរនានា មិនបានទទួលការពិចារណាហ្មត់ចត់ឡើយមុនពេលបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ ។ ការផ្លាស់ប្តូរទំលាប់បែបនេះ គឺជាការចាំបាច់ ។

ការបង្កើតគណៈកម្មការច្បាប់ជាន់ខ្ពស់មួយនៅក្នុងក្រសួងពាក់ព័ន្ធអាចជាប្រការចាំបាច់ ដើម្បីដោះស្រាយបញ្ហាត្រួតគ្នា និងទំនាស់នៃអាណត្តិរបស់ស្ថាប័ន ។

- ផែនការគ្រប់គ្រង គួរត្រូវបានរៀបចំឡើង សំរាប់ទីតាំងតំបន់ដីសើមសំខាន់ៗនៅក្នុងប្រទេស ។ ផែនការទាំងនោះគួរមានចែងឱ្យច្បាស់អំពីការទទួលខុសត្រូវ និងចំណុចដែលត្រូវឱ្យមានការសហការរវាងស្ថាប័ននានា ។ បទពិសោធន៍អំពីការសម្របសម្រួល ដែលទទួលបាននៅក្នុងពេលកសាងផែនការគ្រប់គ្រងរបស់ស្ថាប័ននានារបស់រដ្ឋាភិបាល និងជួយនៅក្នុងដំណើរការដោះស្រាយទំនាស់ ។

### *៦.២.៤ កែលំអយន្តការនានាដើម្បីគ្រប់គ្រងឱ្យបានល្អជាងមុននូវភាពប្រកួតប្រជែង និងការប្រើប្រាស់តំបន់ដីសើមប្រកបដោយការសំរបសំរួលរវាងអ្នកពាក់ព័ន្ធ*

- ការសម្របសម្រួលអ្នកពាក់ព័ន្ធនៅថ្នាក់តំបន់ គណៈកម្មការទន្លេមេគង្គ គួរមាននាទីក្នុងការចាត់វិធានការដែលប្រុងប្រយ័ត្នជាមុនដើម្បីសម្របសម្រួលឱ្យមានការចរចាគ្នារវាងអ្នកពាក់ព័ន្ធទាំងអស់ក្នុងអាងទន្លេមេគង្គ ។ ទង្វើបែបនេះមានសារៈសំខាន់ណាស់ ពិសេស ក្នុងការអភិវឌ្ឍន៍ និងគ្រប់គ្រងករណីដែលមានឥទ្ធិពលឆ្លងដែន ដូចជាការសាងសង់ទំនប់ ។

- ការគ្រប់គ្រងដោយសហគមន៍ ត្រូវមានការគាំទ្រខាងផ្នែកច្បាប់ និងស្ថាប័នពីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ។ គោលបំណងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលប់ចោលឡូតិ៍នេសាទមួយចំនួនដើម្បីដាក់ឱ្យសហគមន៍អ្នកនេសាទប្រើប្រាស់ គឺដើម្បីកាត់បន្ថយទំនាស់ក្នុងការប្រើប្រាស់ធនធានជលផល និងដើម្បីកែលំអជីវភាពរស់នៅរបស់ប្រជាជនដែលពឹងផ្អែកលើធនធានទាំងនោះ ។ នេះជាផ្នែកមួយនៃគោលនយោបាយរបស់រដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។ ច្បាប់ស្តីពីជលផលស្ថិតនៅជាសេចក្តីព្រាងនៅឡើយ ហើយមុនពេលដែលសភាអនុម័តច្បាប់នេះ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទអាចត្រូវបានអនុម័តរួច ។ បទពិសោធន៍បានពីការអនុវត្តសហគមន៍នេសាទនៅក្នុងប្រទេសដែលបានចាត់ចែងឡើងដោយអង្គការមិនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិអាចជួយសំរួលឱ្យមានការពង្រីកវិធីនេះសំរាប់គ្រប់គ្រងការនេសាទ ។ ទោះបីជំនួយហិរញ្ញវត្ថុពីអង្គការរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិបានផ្តល់ប្រយោជន៍យ៉ាងច្រើនដល់ទាយកដ្ឋានជលផល ក្នុងការរៀបចំសហគមន៍នេសាទក្តី បទពិសោធន៍ផ្នែកនេះ នៅមានតិចតួចនៅឡើយ ។ ការពង្រឹងសមត្ថភាពក្នុងផ្នែក អភិវឌ្ឍន៍សហគមន៍នេសាទឱ្យបានខ្លាំងក្លាថែមទៀត គឺជាការចាំបាច់ ហើយការធ្វើបែបនេះអាចត្រូវការឱ្យមានសកម្មភាពនានា ដូចជាទស្សនៈកិច្ចសិក្សាដើម្បីដកស្រង់បទពិសោធន៍ល្អៗពីប្រទេសជិតខាង និងវគ្គបណ្តុះបណ្តាលរយៈពេលខ្លី។ ការបណ្តុះបណ្តាលគ្រូបង្គោល គឺជាជំហានដ៏សំខាន់មួយឆ្ពោះទៅបណ្តុះបណ្តាលអ្នកសម្របសម្រួលសហគមន៍នេសាទនៅក្នុងមូលដ្ឋាន។ បទប្បញ្ញត្តិ និងលក្ខន្តិកៈដែលមានស្រាប់សំរាប់សហគមន៍នេសាទ ត្រូវការឱ្យមានការកែលំអជាបន្ថែមទៀត ដែលជាការប្រសើរត្រូវតែធ្វើឡើងតាមរយៈការចូលរួមយ៉ាងសកម្មពីសំណាក់សហគមន៍ នៅក្នុងដំណើរពិនិត្យឡើងវិញនេះ។ សេវាផ្សព្វផ្សាយអំពីការនេសាទក៏ត្រូវការផងដែរ ដើម្បីជំរុញការយល់ដឹងសាធារណៈអំពី តំលៃនៃធនធានតំបន់សើមចំពោះ

ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ។ បទពិសោធន៍ពីកិច្ចផ្តួចផ្តើមគ្រប់ គ្រងដោយសហគមន៍ដែលសំរបសំរួលដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិអាចយកទៅប្រើប្រាស់ដើម្បីកែលំអដំណើរការរៀបចំអនុក្រិត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ។

- **កែលំអដំណើរការកសាងផែនការ និងការធ្វើសេចក្តីសំរេច** សំរាប់ការធ្វើសេចក្តីសំរេចអំពីការចាត់ចែងធនធានដែលមានឥទ្ធិពលដល់តំបន់ដីសើម ។ សេចក្តីសំរេចនានាអំពីការធ្វើសម្បទានដី និងការចាត់ចែងតំបន់ដីសើម គួរធ្វើឡើងដោយមានការជូនដំណឹងជាមុន និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ។ សព្វថ្ងៃសេចក្តីសំរេចពាក់ព័ន្ធនឹងការធ្វើសម្បទានដីធ្លី និងធនធានធ្វើឡើងនៅថ្នាក់លើតែប៉ុណ្ណោះ ។ ក្រុមតស៊ូមតិរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិអាចបង្កើនការយល់ដឹងដល់អ្នកធ្វើសេចក្តីសំរេចអំពីផលប៉ះពាល់នៃសេចក្តីសំរេចទាំងនោះចំពោះជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន ដោយធ្វើការបង្ហាញពីរបៀបដែលជួនកាល ផលប៉ះពាល់ទាំងនោះបង្កជាសកម្មភាពផ្ទុយនឹងគោលនយោបាយរបស់រដ្ឋាភិបាល។ ការវាយតំលៃហេតុប៉ះពាល់បរិស្ថានគួរតែធ្វើឡើងសំរាប់គ្រប់សំណើគំរោងអភិវឌ្ឍន៍ ជាពិសេសគំរោងសាងសង់ទំនប់វារីអគ្គិសនី ប្រព័ន្ធស្រោចស្រព ទំនប់ការពារទឹកជំនន់ និងការកំណត់ព្រៃសម្បទាន និងឡូត៍នេសាទ មុនពេលធ្វើសេចក្តីសំរេចអនុវត្តគំរោងទាំងនោះ។

- **ត្រូវឱ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញសំរាប់គំរោងអភិវឌ្ឍន៍ដែលអាចមានផលប៉ះពាល់ដល់តំបន់ដីសើម** អនុក្រិត្យស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន គឺជាបរិធានច្បាប់ដែលក្រសួងបរិស្ថានអាចប្រើប្រាស់ដើម្បីកាត់បន្ថយផលប៉ះពាល់នៃគំរោងអភិវឌ្ឍន៍ចំពោះបរិស្ថាន។ ជាទូទៅ ទោះបីការវាយតំលៃហេតុប៉ះពាល់បរិស្ថានមានការពាក់ព័ន្ធជាមួយវិស័យទាំងអស់ក្តី មានតែក្រសួងបរិស្ថានមួយប៉ុណ្ណោះដែលមាននាយកដ្ឋានមួយមានភារៈទទួលខុសត្រូវក្នុងការអនុវត្តកិច្ចការនេះ។ ប៉ុន្តែមានគំរោងជាច្រើន ដូចជាគំរោងសាងសង់ផ្លូវជាតិលេខ១ ដែលបានអនុវត្ត ដោយពុំមានការពិគ្រោះយោបល់ជាមួយក្រសួងបរិស្ថានឡើយ (ICEM 2003)។

### ៦.២.៥ *ការគាំទ្រដើម្បីប្រមូល និងផ្សព្វផ្សាយព័ត៌មានឱ្យបានប្រសើរជាងមុនអំពីតំលៃប្រើប្រាស់ច្រើនយ៉ាងនៃតំបន់ដីសើម*

- **ការធ្វើសារពើភ័ណ្ឌតំបន់ដីសើម** និងមូលដ្ឋានទិន្នន័យអំពីតំបន់ដីសើមមានសារៈសំខាន់ណាស់ សំរាប់កសាងផែនការ និងការធ្វើសេចក្តីសំរេចឱ្យបានប្រសើរជាងមុន។ យន្តការមួយសំរាប់ការចែករំលែកព័ត៌មានរវាងអ្នកប្រើប្រាស់ និងអ្នកគ្រប់គ្រងធនធានក៏ជាប្រការចាំបាច់ផងដែរ។ គណៈកម្មការទន្លេមេគង្គមានតួនាទីចំបងក្នុងការចាត់ថ្នាក់តំបន់ដីសើមក្នុងអាងទន្លេមេគង្គ។ មានការរៀបចំសិក្ខាសាលាថ្នាក់តំបន់ និងថ្នាក់ជាតិ ដើម្បីរៀបចំដំណើរការចាត់ថ្នាក់តំបន់ដីសើម រីឯសេចក្តីណែនាំសំរាប់ការធ្វើចំណាត់ថ្នាក់បានទទួលការអនុម័តគាំទ្រពីគណៈកម្មាធិការទន្លេមេគង្គជាតិទាំងបួនប្រទេសរួចមកហើយ។ វិធាននៃចំណាត់ថ្នាក់ដែលមានលក្ខណៈជាស្តង់ដា គឺជាយន្តការមួយសំរាប់សំរបសំរួលឱ្យមានការចែងបានប្រសើរអំពីរបបគ្រប់គ្រងដែលមានលក្ខណៈ

ស្តង់ដារសំរាប់តំបន់ដីសើមប្រភេទនានា។ សេចក្តីណែនាំ សំរាប់ការធ្វើសារពើភ័ណ្ឌតំបន់ដីសើមអាស៊ីដែលបានរៀបចំដោយអង្គការតំបន់ដីសើមអន្តរជាតិ គឺជាឧបករណ៍ដែលមានសារៈប្រយោជន៍សំរាប់គោលដៅនេះ។

- ការបង្កើនការយល់ដឹង គួរត្រូវអនុវត្តនៅគ្រប់លំដាប់ថ្នាក់ ដើម្បីជំរុញឱ្យមានការចូលរួមជាសាធារណៈ។ ក្រសួងបរិស្ថានដែលជាហត្ថលេខីនៃអនុសញ្ញារ៉ាមសារ បានប្រើប្រាស់ឯកសារបោះពុម្ពផ្សាយ និងបណ្តាញការងារ ដើម្បីបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃធនធានតំបន់ដីសើម។

- កែលំអការប្រមូលទិន្នន័យដែលធ្វើឡើងដោយរដ្ឋាភិបាល ដោយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងរបាយការណ៍ក្រិតទាបអំពីផលនេសាទ។ ការកែលំអនេះរួមមាន (i) ដោះស្រាយបញ្ហាប្រមូលព័ត៌មានជាផ្នែកមួយនៃតំពែងនានា (ii) បង្កើតយន្តការជ្រើសរើសទីតាំងសំរាប់ផ្ទៀងផ្ទាត់ផលនេសាទ និង (iii) កែលំអវិធីសាស្ត្រប្រមូលនិងវិភាគទិន្នន័យ។

- ការកសាងសមត្ថភាព គួរតែត្រូវបានជំរុញសំរាប់នាយកដ្ឋានបច្ចេកទេសនានា អំពីការធ្វើសារពើភ័ណ្ឌ និងស្រាវជ្រាវអំពីតំបន់ដីសើម។ ជាពិសេស គួរតែមានការចងក្រងជាបញ្ជីក្រហមរបស់ជាតិស្តីពី សត្វ និងរុក្ខជាតិក្នុងប្រទេសកម្ពុជា ដោយបញ្ជាក់ពីប្រភេទដែលរងការគំរាមកំហែង។ តំរូវការកសាងសមត្ថភាពផ្សេងៗទៀតរួមមាន ការបណ្តុះបណ្តាលមន្ត្រីទេសក៍ក្មៀវទេសចរអំពីបញ្ហា ដូចជា ការធ្វើអត្តសញ្ញាណសត្វស្លាប អេកូឡូស៊ីព្រៃលិចទឹក និងវប្បធម៌របស់អ្នកភូមិបណ្តែតទឹក។ តំបន់ដែលមានសក្តានុពលសំរាប់ការកសាងសមត្ថភាពគឺតំបន់បឹងទន្លេសាប តំបន់នៅជុំវិញទីក្រុងភ្នំពេញ និងតំបន់ឆ្នេរ។

- ត្រូវកសាង និងដាក់ឱ្យដំណើរការនូវយន្តការប្រាស្រ័យទាក់ទង និងការចែករំលែកព័ត៌មាននៅគ្រប់លំដាប់ថ្នាក់នៃស្ថាប័ន រួមទាំងនៅថ្នាក់តំបន់ និងអ្នកពាក់ព័ន្ធទាំងអស់។ គួរពង្រឹងស្ថាប័នជាតិទទួលបន្ទុកអនុសញ្ញារ៉ាមសារ នៅក្នុងក្រសួងបរិស្ថានឱ្យទៅជាការិយាល័យកណ្តាលសំរាប់ផ្សព្វផ្សាយទិន្នន័យជាតិ និងអន្តរជាតិអំពីការគ្រប់គ្រងតំបន់ដីសើម។

- ជំរុញកម្មវិធីផ្លាស់ប្តូរនៅថ្នាក់តំបន់ និងការពិភាក្សាអំពីវិធីសាស្ត្រដែលបានសាកល្បងរួចហើយសំរាប់ការវាយតំលៃសេដ្ឋកិច្ចតំបន់ដីសើមឱ្យបានសមស្រប និងមានប្រសិទ្ធភាព។

Gregory, R and H. Guttman. 1999. A diverse monoculture: Aquatic animal production from rice fields in southeat Asia, *Catch and Culture Mekong Fishery Network Newletter*5(1): 2-5

Gum, W. 1997. Fisheries development in northwest Cambodia, May 1996 to February 1997. Consultancy report for Cambodia Rehabilitation and Regeneration (CARERE)/UNDP/RGC.

Gum, W. 2001. *Inland aquatic resource and livelihoods in Cambodia: A guide to the literature, legislation, institutional framework and recommendations.* Consultancy report for Oxfam GB Cambodia Land study Project, November 2000. Oxfam GB, Phnom Penh.

Guttman, H. 1999. Ricefield fisheries – a resource for Cambodia. *Naga, The ICLARM Quarterly* 22(2): 11-15

Howe, C.P., G. F. Claridge, R. Hughes and Zuwendra. 1991. *Draft report of manual of guidelines for scoping EIA in tropical wetlands.* PHPA/AWI Sumatra wetland project No. 5 (Draft), Indonesia.

ICEM. 2003. *Cambodia National Report on Protected Areas and Development. Review of Protected Areas and Development in the Lower Mekong River Region.* Indooroopilly, Queensland, Australia. 148 pp.

Mam, K. and V. Sok. 2001. *Local Livelihood and Biodiversity Protection in the Boeng Chhmar and Stung Sen Core Areas.* Consultancy report for UNDP Tonle Sap Conservation Project. Wetlands International, Phnom Penh, Cambodia.

MAFF. 1993. Bulletin of Agriculture and Statistics of Ministry of Agriculture, Forestry and Fishery. No. 1-4, Phnom Penh, Cambodia.

McDonald, A., B. Pech, V. Phauk and B. Leev. 1997. *Plant communities of the Tonle Sap flood plain.* Contribution to the nomination of the Tonle Sap as a Biosphere Reserve for UNESCO's "Man in the Biosphere Program". UNESCO, Phnom Penh, Cambodia.

Mekong Secretariat. 1994. *Cambodia Land Cover Atlas 1985/87 - 1992/93.* Remote Sensing and Mapping Unit, Mekong Secretariat, United Nations Development Programme; Food and Agriculture Organisation, Cambodia. 124pp.

MoE. 1999. *National Wetland Action Plan*, Draft January 1999. Ministry of Environment and Wetlands International, Phnom Penh, Cambodia.

MOWRAM. 2002. *Draft National Water Resources Policy for the Kingdom of Cambodia.* Ministry of Water Resources and Meteorology, Phnom Penh, Cambodia.

NEDECO and MIDAS. 1998a. *Draft natural resources-based development strategy for the Tonle Sap area, Cambodia.* Final Report. Sectoral Studies: Environment in the Tonle Sap area. Cambodia National Mekong Committee, Phnom Penh, Cambodia.

NEDECO and MIDAS. 1998b. *Potential for Eco-tourism in the Tonle Sap Area, Cambodia.* Mekong River Commission Secretariat/UNDP.

ORSTOM & BCEOM. 1993. *Development Plan for Tonle Sap and Chakdomuk, Phase I*, Draft Final, The Mekong Secretariat, Phnom Penh, Cambodia.

Rees, C. 1990. *A Guide to Development in Urban and Coastal Areas.* Asian Wetland Bureau, Kuala Lumpur, Malaysia.

RGC (Royal Government of Cambodia). 2000. *Wetland classification system for Cambodia.* A report of the Inventory and Mangement of Cambodia Wetland Project (MRC-DANIDA). Phnom Penh, Cambodia.

RGC (Royal Government of Cambodia). 2001. *Second Five Year Socio-economic Development Plan (SEDP II: 2001-2005).* Phnom Penh, Cambodia.

Said, I.M., O. Mohd. Shahwahid, and N. Khan. 1992. *The Economic Value of the Wetland Plant Species and Recommendations to Improve Wetland Conservation in Peninsular Malaysia.* Asian Wetland Bureau Publication No. 80. Asian Wetland Bureau, Kuala Lumpur, Malaysia.

Savy, T. 1999. Aquaculture and ricefield fisheries development for 1998 in southeast Cambodia. in *Proceedings of the Workshop on Legal and Institutional Frameworks, and Economic Valuation of Resources and Environment in the Mekong River Region - A Wetland Approach,* 22-24 March 1999. Department of Fisheries, Phnom Penh, Cambodia.

Shams, N. and M. Ahmed. 1996. *Common and private property linkage for sustainable livelihood in low-land forest-fishery-farming systems of northwest Cambodia.* Paper presented at "Voices of the Commons" 6th Annual Conference of International Association for the Study of Common Property (IASCP), University of California at Berkeley, California, June 5-6 1996.

Shams, N and T. Hong. 1998. *Cambodia's Rice Field Ecosystem Biodiversity: Resources and Benefits.* Deutsche Gesellschaft Fur Technische Zusammenarbeit (GTZ), Cambodia.

Thuok, N. and L. Sina. 1997. *Review of the fisheries and aquaculture sector in Cambodia* (Draft), prepared for the natural resources based development strategy for the Tonle Sap area project, Department of Fisheries, Phnom Penh.

Thuok, N. and S.L. Song. 1999. *Report on Field Survey Work of Fishing Lot No. 6, Kampong Khleang Commune, Sotr Nikum District, Siem Reap Province, Cambodia,* Department of Fisheries, Supported by Project GCP/CMB/002/BEL: Participatory management of the natural resources in the Tonle Sap region, FAO, Siem Reap, May 1999.

Thuok, N. and N. van Zalinge. 2000. *Management aspects of Cambodia's freshwater capture fisheries.* Eleven presentations given at the annual meeting of the Department of Fisheries, Ministry of Agriculture, Forestry and Fishery, 27-28 January 2000. Mekong River Commission and Department of Fisheries, Phnom Penh.. 170 pp.

van Zalinge, N. and N. Thuok. 1999. Summary of project findings. In *Present Status of Cambodia's Freshwater Capture Fisheries and Management Implications,* Mekong River Commission/DoF/DANIDA Project on the Management of Freshwater Capture Fisheries in Cambodia.

van Zalinge, N.P., N. Thuok, T. S. Tana and D. Loeung. 2000. Where there is water, there is fish? Cambodian fisheries issues in a Lower Mekong Basin perspective, p. 37-48 In: M. Ahmed and P. Hirsch (eds.). *Common property in the Mekong: issues of sustainability and subsistence.* ICLARM Studies and Reviews 26. 67 pp.

UNESCO 1994. *Convention on Wetlands of International Importance especially as Waterfowl Habitat (Ramsar, Iran 2.2.1971), as amended by the Protocol of 3 December 1982 and the Amendments of 28 May 1987, as of July 1994.* Office of International Standards and Legal Affairs, UNESCO. [Online]. Available: http://www.iucn.org/themes/ramsar/key_conv_e.html.



## TITLES OF RELATED INTEREST

Wetlands Governance in the Mekong Region: Country Reports on the Legal-institutional Framework and Economic Valuation of Aquatic Resources. Oh, E., Ratner, B., Bush, S., Kolandai, K., and Too, T. (eds.). 2005. WorldFish Center, Penang, Malaysia

Cambodian Inland Fisheries: Facts, Figures and Context. Baran, E. 2005. WorldFish Center, Penang, and Inland Fisheries Research and Development Institute, Phnom Penh, Cambodia. 49 p.

Undervalued and Overlooked: Sustaining Rural Livelihoods through Better Governance of Wetlands. Ratner, B.D., Dang Thanh Ha, Mam Kosal, Ayut Nissapa and Somphanh Chanphengxay. 2004. WorldFish Center Studies and Reviews 28, 24 p.

Wetlands Management in Cambodia: Socioeconomic, Ecological, and Policy Perspectives. M. Torell, A.M. Salamanca, B.D. Ratner (eds.). 2004. WorldFish Center Technical Report 64, 55 p.

Wetlands Management in Vietnam: Issues and Perspectives. M. Torell, A.M. Salamanca, B.D. Ratner (eds.). 2003. WorldFish Center Technical Report 61, 89 p.

Fish to 2020: Supply and Demand in Changing Global Markets. C.L. Delgado, N. Wada, M.W. Rosegrant, S. Meijer, and M. Ahmed. 2003. WorldFish Center Technical Report 62, 240 p.

Fisheries Co-management Policy Brief: Findings from a Worldwide Study. K.K. Viswanathan, J.R. Nielsen, P. Degnbol, M. Ahmed, M. Hara and N.M. Raja Abdullah. 2003. WorldFish Center Policy Brief 2, 26 p.

Institutional Issues and Perspectives in the Management of Fisheries and Coastal Resources in Southeast Asia. M. Torell and A.M. Salamanca (eds.). 2002. ICLARM - The World Fish Center Technical Report 60, 212 p.

Common Property in the Mekong: Issues of Sustainability and Subsistence. M. Ahmed and P. Hirsch (eds.). 2000. ICLARM Studies and Reviews 26, 67 p.

*All the above publications are also available online for download as pdf files at* www.worldfishcenter.org

*To order and for more information on WorldFish Center publications, please contact:*

**The Communications Unit**
**WorldFish Center**
P.O. Box 500, GPO, 10670 Penang, Malaysia
Tel: (+60-4) 626 1606
Fax: (+60-4) 626 5530
Email: worldfishcenter@cgiar.org

**WorldFish Center**
**Mekong Regional Office** ***(Visiting address from September 2005):***
No. 35 Street 71 (corner with Mao Tse Tong Blvd)
Sangkat Bang Keng Kang I, Khan Chamcarmon
PO Box 1135
Phnom Penh, Cambodia

# ឆ្ពោះទៅវិធានគ្រប់ជ្រុងជ្រោយនៃអភិបាលកិច្ចតំបន់ដីសើម

# ក្របខណ្ឌច្បាប់ និងស្ថាប័ន និងការវាយតំលៃសេដ្ឋកិច្ច នៃធនធានតំបន់ដីសើមក្នុងប្រទេសកម្ពុជា

លោក នៅ ធឿក លោក ម៉ម កុសល លោក ម៉ៅ កុសល លោក គីម សួ និង លោក ស្រ៊ុន លឹមសុង



សម្របសម្រួលបកប្រែ និង បោះពុម្ពផ្សាយដោយ
វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍ជលផលទឹកសាប
២០០៥